# ការសិក្សាក្នុងវិសាលភាពមួយអំពីការអនុវត្តថ្នាក់ជាតិ
# នៅកម្ពុជា

## របាយការណ៍សង្ខេប

ខែ កក្កដា ឆ្នាំ ២០១០

ADAPTATION
KNOWLEDGE
PLATFORM



វេទិកាចំណេះដឹងអំពីការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុថ្នាក់តំបន់
សំរាប់ទ្វីបអាស៊ី

## សេចក្តីថ្លែងអំណរគុណ

ការស្រាវជ្រាវសង្ខេប អំពីការប៉ាន់ប្រមាណក្នុងវិសាលភាពមួយសំរាប់ការអនុវត្តថ្នាក់ជាតិនៅកម្ពុជា ចាប់អនុវត្ត និងចងក្រងជារបាយការណ៏នៅពាក់កណ្តាលឆ្នាំ ២០១០ ។

ការសិក្សាក្នុងវិសាលភាពមួយអំពីការប្រែប្រួលអាកាសធាតុនៅកម្ពុជា ធ្វើឡើងដោយទាញចេញពីស្នាដៃការងារទាំងឡាយដែលកំពុងបន្តអនុវត្ត ដោយវេទិកាចំណេះដឹងអំពីការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ ក្នុងគោលបំណងចែកចាយ និងផ្លាស់ប្តូរចំណេះដឹងអំពីការបន្សាំឲ្យបានដល់អ្នកប្រើប្រាស់ឲ្យទូលំទូលាយបន្ថែមទៀត។ យើងខ្ញុំសូមថ្លែងអំណរគុណ ដល់បណ្តាស្ថាប័ន អង្គការ និងបុគ្គលយ៉ាងច្រើនឥតគណនា ដែលបានផ្តល់នូវទស្សនៈ និងមតិយោបល់សំខាន់ៗជាច្រើនដល់ការស្រាវជ្រាវនេះ។ ការស្រាវជ្រាវនេះ ទទួលបាននូវមតិយោបល់ និងអនុសាសន៏ដ៏មានតំលៃអំពីស្ថានភាពនៃការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុនៅកម្ពុជា។ អរគុណដល់អ្នកនិពន្ធសំខាន់ៗនៃការស្រាវជ្រាវនេះ មានដូចជា Robert W.Solar, Toby Carson nig Marona Srey, នៃវិទ្យាស្ថានគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួមពីសហគមន៏ សំរាប់ពេលវេលាយ៉ាងច្រើនមិនអាចគណនា ដែលពួកគាត់បានចំណាយលើការសំរបសំរួល និងដឹកនាំការចូលរួមរបស់បណ្តាអ្នកពាក់ព័ន្ធទាំងឡាយរួមទាំងក្រុមតំណាងមកពីវេទិការចំណេះដឹងបន្សាំទៅនឹងការប្រែ ប្រួលអាកាសធាតុថ្នាក់តំបន់_អាស៊ី (វេទិកាចំណេះដឹងបន្សាំ) ដែលមានការិយាល័យស្ថិតនៅទីក្រុងបាងកក ប្រទេសថៃ ឲ្យសំរេចបានគោលដៅដ៏មានសារៈសំខាន់នេះ។

រក្សាសិទ្ធិដោយ © AIT-UNEP RRC.AP ២០១០
ទីក្រុងបាងកក ប្រទេសថៃ
ខែ តុលា ឆ្នាំ ២០១០

### របៀបស្នើសុំរបាយការណ៍ជាសំណៅ ឌីជីថល

ការស្រាវជ្រាវសង្ខេប អំពីការប៉ាន់ប្រមាណក្នុងវិសាលភាពមួយសំរាប់ការអនុវត្តថ្នាក់ជាតិនៅកម្ពុជា អាចរកបានជាសំណៅអេឡិកត្រូនិច ដោយការទាញចេញពីគេហទំព័រ www.asiapacificadapt.net.

ការបោះពុម្ពផ្សាយជា ឌីជីថល អាចផលិតឡើងវិញទាំងស្រុង ឬជាចំណែកក្នុងទំរង់ណាមួយ ដែលមានគោលបំណងអប់រំ ឬគោលបំណងមិនរកកំរៃ ដោយពុំចាំបាច់មានសេចក្តីអនុញ្ញាតិពិសេសណាមួយពីម្ចាស់កម្មសិទ្ធិទេដោយគេគ្រាន់តែផ្តល់នូវសេចក្តីអរគុណដល់ប្រភពនៃឯកសារនេះប៉ុណ្ណោះ។ វេទិកាចំណេះដឹងបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុថ្នាក់តំបន់_អាស៊ី មានក្តីរីករាយនឹងទទួលនូវសំណៅចំឡងនៃការបោះពុម្ពផ្សាយទាំងឡាយណា ដែលបានប្រើប្រាស់របាយការណ៏នេះជាប្រភពសំអាង។

# ការសិក្សាក្នុងវិសាលភាពមួយអំពីការអនុវត្តថ្នាក់ជាតិ នៅកម្ពុជា

## របាយការណ៍សង្ខេប

## ខែ កក្កដា ឆ្នាំ ២០១០

# មាតិកា


តារាងពាក្យបំព្រួញ i

**សេចក្តីសង្ខេបប្រតិបត្តិ** vii

**ការសិក្សាក្នុងវិសាលភាពមួយអំពីការអនុវត្តថ្នាក់ជាតិ នៅប្រទេសកម្ពុជា** 7

**ប្រវត្តិនៃការសិក្សា** 7

**ការឆ្លើយតបជាស្ថាប័នចំពោះការបន្សុំាទៅនឹងការប្រែប្រួលអាកាសធាតុ** 8

ស្ថាប័នសំរបសំរួលថ្នាក់ជាតិសំខាន់ៗដែលពាក់ព័ន្ធក្នុងការបន្សុំាទៅ នឹងការប្រែប្រួលអាកាសធាតុ 8

ក្រុមបង្គោល និងអង្គការមិនមែនរដ្ឋាភិបាលដែលរួមចំណែកក្នុងការបន្សុំាទៅនឹងការប្រែប្រួលអាកាសធាតុ 9

ស្ថាប័នថ្នាក់ក្រសួងសំខាន់ៗដែលរួមចំណែកដលការបន្សុំាទៅនឹងការ ប្រែប្រួល អាកាសធាតុ 12

ផែនការសកម្មភាពយុទ្ធសាស្ត្រគាំទ្រដល់ការបន្សុំាទៅនឹងការប្រែប្រួលអាកាសធាតុ 16

សង្ខេបនូវគោលនយោបាយ និងការរៀបចំផ្សេងៗសំដៅគាំទ្រដល់ការបន្សុំាទៅនឹងការប្រែប្រួលអាកាសធាតុ 21

**ការឆ្លើយតបចំពោះការបន្សុំាទៅនឹងការប្រែប្រួលអាកាសធាតុ ចំណេះដឹង ប្រព័ន្ធ និងរចនាសម្ព័ន្ធ** 23

ការឆ្លើយតបរបស់សហគមន៍ទៅនឹងការប្រែប្រួលអាកាសធាតុ 23

វិស័យសំខាន់ៗដែលបានឆ្លើយតបចំពោះការប្រែប្រួលអាកាសធាតុ 25

**ចំណេះដឹងអំពីការប្រែប្រួលអាកាសធាតុ ការស្រាវជ្រាវ និងគំរូការសកម្មភាព** 44

ចំណេះដឹងមានស្រាប់ និងការស្រាវជ្រាវដែលអាចរកបាន 44

ការពង្រឹងគំរូការបន្សុំាទៅនឹងការប្រែប្រួលអាកាសធាតុ 51

**យុទ្ធសាស្ត្រកសាងសមត្ថភាព** 59

ការកំណត់កង្វះខាតសមត្ថភាព និងអាទិភាព 59

យុទ្ធសាស្ត្រសំរាប់កសាងសមត្ថភាពបន្សុាំ ទៅនឹងការប្រែប្រួលអាកាសធាតុ 67

**សេចក្តីសន្និដ្ឋានបញ្ចប់ និងជំហានបន្ទាប់** 83

**តារាងឧបសម្ព័ន្ធ** 94

# តារាងពាក្យបំព្រួញ

**ADB** ធនាគារអភិវឌ្ឍន៍អាស៊ី

**ADPC** មជ្ឈមណ្ឌលបង្ការគ្រោះ មហន្តរាយ អាស៊ី

**AIACC** ការប៉ាន់ប្រមាណផលប៉ះពាល់ និង ការបន្សាំទៅនឹងការប្រែប្រួល អាកាសធាតុ

**ACIAR** មជ្ឈមណ្ឌលអូស្ត្រាលីសំរាប់ការ ស្រាវជ្រាវកសិកម្មអន្តរជាតិ

**ATI** វិទ្យាស្ថានបច្ចេកវិទ្យាអាស៊ី

**AUSAID** ភ្នាក់ងារអូស្ត្រាលីសំរាប់ការ អភិវឌ្ឍអន្តរជាតិ

**CBDP** ការត្រៀមបង្ការគ្រោះមហន្តរាយ ដោយមានការចូលរួមពីសហគមន

**CBDRM** ការគ្រប់គ្រងគ្រោះមហន្តរាយ ដោយមានការចូលរួមពីសហគមន

**CBDRR** ការបន្ថយគ្រោះមហន្តរាយនៅ ដោយមានការចូលរួមពីសហគមន៍

**CCA** ការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ

**CCBA** សម្ព័ន្ធភាពស្តីពីអាកាសធាតុ និង ជីវសាស្រ្តចំរុះថ្នាក់សហគមន៍

**CCCO** ការិយាល័យប្រែប្រួលអាកាស ធាតុកម្ពុជា

**CCCT** ក្រុមការងារស្តីអំពីការប្រែប្រួល អាកាសធាតុ

**CCD** នាយកដ្ឋានប្រែប្រួលអាកាសធាតុ

**CCDM** គណៈកម្មការឃុំទទួលបន្ទុកការ គ្រប់គ្រងគ្រោះមហន្តរាយ

**CD4CDM** ការកសាងសមត្ថភាពសំរាប់ យន្តការអភិវឌ្ឍន៍ស្អាត

**CDM** យន្តការអភិវឌ្ឍន៍ស្អាត

**CEDAC** មជ្ឈមណ្ឌលសិក្សា និង អភិវឌ្ឍន៍កសិកម្មកម្ពុជា

**CF** សហគមន៍ព្រៃឈើ

**CIAT** មជ្ឈមណ្ឌលអន្តរជាតិសំរាប់ កសិកម្មនៅតំបន់ត្រូពិក

**CER** ការកាត់បន្ថយឧស្ម័នដែលបាន បញ្ជាក់

**CFSP** គំរោងសន្សំសំចៃធនធានឱសនៅ កម្ពុជា

**CMDG** ទិសដៅអភិវឌ្ឍន៍ប្រចាំសហវត្សរ

**COP** សន្និសីទបណ្តាភាគី

**CRC** កាកបាទក្រហមកម្ពុជា

**CRCD** មជ្ឈមណ្ឌលស្រាវជ្រាវសំរាប់ការ អភិវឌ្ឍកម្ពុជា

**DIPECHO** នាយកដ្ឋានផ្តល់ជំនួយមនុស្សធម៌ សំរាប់ត្រៀមបង្ការ គ្រោះមហន្តរាយសហគមន៍ អ៊ឺរ៉ុប

**DM** ការគ្រប់គ្រងគ្រោះមហន្តរាយ

**DNA** អាជ្ញាធរជាតិទទួលបន្ទុកយន្តការ អភិវឌ្ឍន៍ស្អាត

**DNA-CDM** អាជ្ញាធរជាតិទទួលបន្ទុកយន្តការ អភិវឌ្ឍន៍ស្អាត

**DOM** នាយកដ្ឋានឧតុនិយម

**DPP** សំណើសុំធ្វើផែនការអភិវឌ្ឍន៍

**DRC** កាកបាទក្រហមប្រទេសដាណឺ ម៉ាក

**DRR** ការបន្ថយគ្រោះមហន្តរាយ

**EBA** ការបន្សាំផ្អែកលើប្រព័ន្ធអេកូឡូស៊ី

**ERPA** កិច្ចព្រមព្រៀងបន្ថយឧស្ម័នតាម ការទិញឧស្ម័នកាបូនិច

**ESPSEA** កម្មវិធីសេដ្ឋកិច្ច និងបរិស្ថានសំរាប់ តំបន់អាស៊ី ភាគអាគ្នេយ៍

**FAO** អង្គការស្បៀង និងកសិកម្ម

**FERP** គំរោងស្តារឡើងវិញជាបន្ទាន់ពី គ្រោះទឹកជំនន់

**FMMP** កម្មវិធីគ្រប់គ្រង និងសំរាលគ្រោះ ទឹកជំនន់

**FWUC** សហគមន៍កសិករអ្នកប្រើប្រាស់ ទឹក

**GERES** Groupe Energies Renouvelables, Environnement et Solidarités

**GEF** មូលនិធិបរិស្ថានពិភពលោក

**GHG** ឧស្ម័នផ្ទះកញ្ចក់

**HSP2** ផែនការយុទ្ធសាស្រ្តវិស័យសុខាភិបាលជំហានទី ២ ឆ្នាំ ២០០៨_ ២០១៥

**ICM** ការគ្រប់គ្រងចំរុះតំបន់ឆ្នេរ

**IDRC** មជ្ឈមណ្ឌលស្រាវជ្រាវអភិវឌ្ឍន៍ អន្តរជាតិ

**IETA** សមាគមជំនួញការបញ្ចេញឧស្ម័ន អន្តរជាតិ

**IFI** ស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ

**IFRC** សហព័ន្ធកាកបាទក្រហមអន្តរជាតិ

**IFRC-RCS** សហព័ន្ធកាកបាទក្រហម និង សង្គមអឌ្ឍច័ន្ទក្រហមអន្តរជាតិ

**IGES** វិទ្យាស្ថានយុទ្ធសាស្ត្រ បរិស្ថាន សាកល

**IPCC** ក្រុមការងារអន្តររដ្ឋាភិបាលស្តីពី ការប្រែប្រួលអាកាសធាតុ

**ISC-CDM** ការពង្រឹងសមត្ថភាពចំរុះសំរាប់ យន្តការអភិវឌ្ឍន៍ស្អាត

**ISET** បច្ចេកវិជ្ជាវិទ្យាសាស្ត្របរិស្ថាន អន្តរជាតិ

**IUCN** សហភាពអភិរក្សពិភពលោក

**IWRM** ការគ្រប់គ្រងធនធានទឹកចំរុះ

**LCDEG** ក្រុមអ្នកជំនាញសំរាប់ប្រទេស លូតលាស់តិច

**LDCF** មូលនិធិសំរាប់ប្រទេស លូតលាស់ តិច

**LWF** អង្គការ លូធេរ៉ានបំរើពិភពលោក

**MAFF** ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

**MAFF-FA** រដ្ឋបាលជលផល_ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

**MBSAP** យុទ្ធសាស្ត្រ និងផែនការសកម្ម ភាពជាតិសំរាប់ប្រព័ន្ធជីវសាស្ត្រ ចំរុះ

**MPWT** ក្រសួងសាធារណៈការ និងដឹក ជញ្ជូន

**MOE** ក្រសួងបរិស្ថាន

**MOEYS** ក្រសួងអប់រំ យុវជន និងកីឡា

**MOH** ក្រសួងសុខាភិបាល

**MOLMUPC** ក្រសួងរៀបចំដែនដី នគរូបនីយ កម្ម និងសំណង់

**MORD** ក្រសួងអភិវឌ្ឍន៍ជនបទ

**MOWRAM** ក្រសួងធនធានទឹក និងឧតុនិយម

**NAHRIM** វិទ្យាស្ថានជាតិស្រាវជ្រាវថាមពល ទឹកនៃប្រទេសម៉ាឡេស៊ី

**NAPA** កម្មវិធីសកម្មភាពជាតិ ដើម្បី បន្សាំទៅនឹងការប្រែប្រួល អាកាសធាតុ

**NBP** កម្មវិធីជីវឧស្ម័នជាតិ

**NBSAP** យុទ្ធសាស្ត្រ និងផែនការសកម្ម ជាតិសំរាប់ជីវឧស្ម័ន

| | |
|---|---|
| **NCCAP** | ផែនការសកម្មភាពជាតិសំរាប់ ការប្រែប្រួលអាកាសធាតុ |
| **NCCC** | គណៈកម្មាធិការជាតិគ្រប់ គ្រងការប្រែប្រួលអាកាសធាតុ |
| **NCDM** | គណៈកម្មាធិការជាតិ គ្រប់គ្រងគ្រោះ មហន្តរាយ |
| **NCSC** | គណៈកម្មការនាំមុខគ្រប់គ្រង តំបន់ឆ្នេរ |
| **NGO** | អង្គការមិនមែនរដ្ឋាភិបាល |
| **NPRS** | យុទ្ធសាស្រ្តជាតិកាត់បន្ថយភាព ក្រីក្រ |
| **NRML** | ការគ្រប់គ្រងធនធានធម្មជាតិ និង ការប្រកបមុខរបរចិញ្ចឹមជីវិត |
| **NSDP** | ផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ |
| **OCHA** | ការិយាល័ទទួលបន្ទុកការសំរប សំរួលកិច្ចការមនុស្សធម៌ |
| **PADEK** | អង្គការដៃគូសំរាប់ការអភិវឌ្ឍ នៅកម្ពុជា |
| **PDD** | ការរៀបចំគំរោងអភិវឌ្ឍន៍ |
| **PROLINNOVA** | ការលើកស្ទួយគំនិតនៅមូលដ្ឋាន អំពីកសិកម្ម និងការគ្រប់គ្រងធម្ម ជាតិ |
| **REDD** | បន្ថយឧស្ម័នពីការបំផ្លាញ និងធ្វើ ឲ្យរិចរិលព្រៃឈើ |
| **RGC** | រាជរដ្ឋាភិបាលកម្ពុជា |
| **RRCAP** | មជ្ឈមណ្ឌលធនធានថ្នាក់តំបន់ ប្រចាំទ្វីបអាស៊ី និងប៉ាស៊ីហ្វិក |
| **SCCF** | មូលនិធិពិសេសសំរាប់ការប្រែ ប្រួលអាកាសធាតុ |
| **SEI** | វិទ្យាស្ថានបរិស្ថានក្រុងស្តុកហូម |
| **SENSA** | លេខាធិការដ្ឋានបរិស្ថានសំរាប់ទ្វីប អាស៊ីនៃប្រទេសស៊ុយអែដ |
| **SIDA** | ភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិ ប្រទេស ស៊ុយអែដ |
| **SNAP-DRR** | ផែនការយុទ្ធសាស្រ្តសកម្មភាព ជាតិ_ដើម្បីកាត់បន្ថយគ្រោះ មហន្តរាយ |
| **SNV** | អង្គការអភិវឌ្ឍន៍ប្រទេសហូឡង់ |
| **SRI** | ប្រពលវប្បកម្មដំណាំស្រូវ |
| **TA** | ទីប្រឹក្សាបច្ចេកទេស |
| **TWG-AW** | ក្រុមការងារបច្ចេកទេស_កសិកម្ម និងទឹក |
| **UNDMT** | ក្រុមការងារគ្រប់គ្រងគ្រោះមហន្ត រាយសហប្រជាជាតិ |

**UNDP** កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ

**UNEP** កម្មវិធីបរិស្ថានសហប្រជាជាត

**UNESCAP** ស្នងការសហប្រជាជាតិផ្នែក សេដ្ឋកិច្ច និងវប្បធម៌សំរាប់តំបន់ អាស៊ី និងប៉ាស៊ីហ្វិក

**UNFCCC** អនុសញ្ញាក្របខ័ណ្ឌសហប្រជា ជាតិស្តីពីការប្រែប្រួលអាកាស ធាតុ

**UNITAR** វិទ្យាស្ថានសំរាប់ការបណ្តុះ បណ្តាល និងស្រាវជ្រាវ សហប្រជាជាតី

**VCS** ការកំណត់បទដ្ឋានឧស្ម័នដោយ ស្ម័គ្រចិត្ត

**VER** ការកំណត់ការកាត់បន្ថយឧស្ម័ន ដោយមានការបញ្ជាក់

**WFP** កម្មវិធីស្បៀងអាហារពិភពលោក

**WMO** អង្គការឧតុនិយមពិភពលោក

# សេចក្តីសង្ខេបប្រតិបត្តិ

តាមរយៈការស្វះស្វែងរកការសំរបសំរួលឲ្យកាន់តែប្រសើរនូវចំណេះដឹងអំពីការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុនៅថ្នាក់មូលដ្ឋាន និងថ្នាក់ជាតិនៅកម្ពុជា វេទិកាចំណេះដឹងស្តីអំពីការ បន្សាំទៅនឹងការប្រែប្រួលអាកាសធាតុថ្នាក់តំបន់តាមរយៈការជួយគាំទ្រផ្នែកថវិកាពីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិស៊ុយអែដ "ស៊ីដា" វេទិកានេះបានឧបត្ថម្ភការសិក្សាពិស្តារស្តីអំពីការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុនៅប្រទេសកម្ពុជា។

ដោយមានការជួយគាំទ្រពីបណ្តាដៃគូអន្តរជាតិ មានដូចជា វិទ្យាស្ថានបរិស្ថានក្រុងស្តុកហូម និងដៃគូដទៃទៀត ទើប គំរោងសិក្សាស្រាវជ្រាវនេះមានលទ្ធភាពអាចពិនិត្យមើលយ៉ាងទូលំទូលាយនូវការសិក្សា ផ្នែកទ្រឹស្តីបទថ្មីៗ រួមជាមួយការផ្តល់ទស្សនៈផ្សេងៗពីបណ្តា ភ្នាក់ងាររដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល គ្រឹះស្ថានស្រាវជ្រាវ និងជាពិសេស សហគមន៍សំខាន់ៗដែលមានការជាប់ពាក់ព័ន្ធជាមួយស្ថាប័នដែលត្រូវបានផ្តល់អាណត្តិ រួមជាមួយ ការរៀបចំផ្សេងៗ ថ្នាក់ជាតិ និងអន្តរជាតិ នាពេលបច្ចុប្បន្ន ឲ្យឆ្លើយតបពីថ្នាក់មូលដ្ឋានរហូតដល់ថ្នាក់ជាតិ ព្រមទាំងការទទួលយក ចំណេះដឹងក្នុង បរិបទនៃការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ។

សកម្មភាពបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុនៅកម្ពុជា កន្លងមកមានការសំរបសំរួលពីសំណាក់ ស្ថាប័នថ្នាក់ជាតិចំនួន ៤ស្ថាប័ន រួមមានដូចជា គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ នាយកដ្ឋានប្រែប្រួលអាកាសធាតុ អាជ្ញាធរ ជាតិទទួលបន្ទុកយន្តការអភិវឌ្ឍន៍ស្អាត និងគណៈកម្មាធិការជាតិសំរាប់ការប្រែប្រួលអាកាសធាតុ។ ស្ថាប័នទាំងនេះធ្វើការរួមគ្នាជាបឋម ប៉ុន្តែមិនកំរិត ជាមួយក្រសួងធនធានទឹក និងឧតុនិយម ក្រសួងបរិស្ថាន ក្រសួងផែនការ និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ ការគាំទ្រសំខាន់ចំពោះក្រសួងទាំងនេះ ទទួលបានពីក្រុមជំនាញសំរាប់ប្រទេសមានការអភិវឌ្ឍន៍តិច កម្មវិធីអភិវឌ្ឍន៍បរិស្ថានសហប្រជាជាតិ កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ និងអង្គការអន្តរជាតិមួយចំនួនទៀត ដូចជា ភ្នាក់ងារផ្តល់ជំនួយសំរាប់ការអភិវឌ្ឍន៍ ប្រទេសដាណឺម៉ាក ភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិ ប្រទេសស៊ុយអែដ និងសហព័ន្ធអន្តរជាតិកាកបាទក្រហម និងសង្គមអឌ្ឍចន្ទក្រហម។ បណ្តាសកម្មភាពទាំងឡាយ ជាចំបងត្រូវបានអនុវត្តយោងតាមផែនការយុទ្ធសាស្ត្រសកម្មភាព ជាតិសំរាប់កាត់បន្ថយគ្រោះមហន្តរាយ ២០០៨_២០១៣ ផែនការសកម្មភាពជាតិដើម្បីបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ និងយុទ្ធសាស្ត្ររយៈពេលមធ្យមសំរាប់វិស័យកសិកម្ម និងធនធានទឹក ២០០៦_២០១០។ ផែនការទាំងនេះ គឺជា ការឆ្លើយតបព្រមៗគ្នា ទៅនឹងការប្តេជ្ញា

ចិត្តរបស់បណ្តាប្រទេសទាំងឡាយ ចំពោះអនុសញ្ញាក្របខណ្ឌសហប្រជាជាតិ ស្តីពីការប្រែប្រួលអាកាសធាតុ និងពិធីសារក្រុងក្យូតូ ដែលឯកសារទាំងពីរនេះត្រូវបានផ្តល់សច្ចានុម័តដោយរាជរដ្ឋាភិបាលកម្ពុជា។

ចំណែកឯខាងក្នុងប្រទេសវិញ ការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ មានការគាំទ្រមិនទាន់រឹងមាំនៅឡើយ ពីគោលនយោបាយថ្នាក់ក្រសួង ចំពោះការការពារបរិស្ថាន ការគ្រប់គ្រងធនធានធម្មជាតិ ការគ្រប់គ្រងគ្រោះមហន្តរាយ ការអភិវឌ្ឍជនបទ និងតាមរយៈ យុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជាសំរាប់ការអភិវឌ្ឍ បង្កើន ពលកម្ម សមធម៌ និងប្រសិទ្ធិភាពសង្គម។

ការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុកំពុងមានហើយនៅកម្ពុជា។ ជាក់ស្តែងការបន្សាំដោយស្វ័យប្រវត្តិ ដោយសហគមន៍នានា ត្រូវបានគេឃើញកើតមាន ដូចជាការផ្លាស់ប្តូរនូវរយៈពេលនៃការដាំដុះ ដំណាំ និងការថែរក្សាទុកស្បៀងអាហារ ប៉ុន្តែការបន្សាំទាំងនេះចាត់ទុកថាគ្រាន់តែជាវិធានការណ៍ដោះ ស្រាយមួយគ្រាៗ ជាជាងការធ្វើផែនការបន្សាំដែលរៀបរយ។ ទោះជាយ៉ាងនេះក្តី សហគមន៍មួយចំនួន បានចូលរួមយ៉ាងសកម្មក្នុងការកសាងផែនការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ ជាក់ស្តែងមានការកសាង ទំនប់ទឹក ហេដ្ឋារចនាសម្ព័ន្ធធារាសាស្ត្រ ការស្តុកទុកទឹក និងការដាំដុះដំណាំដែលធន់ទ្រាំចំពោះការរាំងស្ងួត និងទឹកជំនន់។ សកម្មភាពបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុដ៏សកម្មបំផុត ដែលគួរឲ្យកត់សំគាល់មានលើវិស័យធនធានទឹក កសិកម្ម និងការគ្រប់គ្រងគ្រោះមហន្តរាយ នៅចំពោះគំរោងទាំងឡាយ ទាក់ទងនឹងផែនការ កម្មវិធីសកម្មភាពជាតិដើម្បីបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ ដែលអនុវត្តដោយក្រសួងមួយចំនួន និងតាម រយៈ អង្គការមិនមែនរដ្ឋាភិបាលជាតិ។ សកម្មភាពបន្សាំរួមមាន ការកែលំអកន្លែងត្រងទុកទឹកភ្លៀង នៅថ្នាក់ភូមិ ការកែប្រែ ការរៀបចំអាងស្តុកទឹក និងប្រឡាយធារាសាស្ត្រ និងការគ្រប់គ្រងការងារទាំងនេះ។ គំរោងដែលលើកមកជាឧទាហរណ៍ក្នុងឯកសារនេះគឺជាគំរោងនៃការកសាងសមត្ថភាពក្នុងការធ្វើផែនការធនធានទឹកចំរុះ ក្នុងកម្មវិធីអភិវឌ្ឍន៍ កសិកម្ម ដែលឧបត្ថម្ភដោយកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ។ លើសពីនេះទៀត ការគ្រប់គ្រង ការធ្វើផែនការ ការគ្រប់គ្រងទឹកជំនន់ និងប្រព័ន្ធផ្តល់ការព្រមានជាមុន បច្ចេកទេសធារាសាស្ត្រ និងការផ្គត់ផ្គង់ទឹក ប្រកបដោយប្រសិទ្ធិភាព និងការកែទំរង់ស្ថាប័ន វាបានជួយដល់ការផ្គត់ផ្គង់ទឹក និងស្បៀង ក្រោមលក្ខខណ្ឌ អាកាសធាតុផ្សេងៗ។

អង្គការមួយចំនួនដូចជា មជ្ឈមណ្ឌលកម្ពុជាសំរាប់ការសិក្សា និងអភិវឌ្ឍវិស័យកសិកម្ម និងអង្គការដៃគូក្នុងការអភិវឌ្ឍជាដើម ធ្វើការងារនៅកំរិតមូលដ្ឋានដើម្បីកសាងក្រុមផ្សព្វផ្សាយកសិកម្មទៅកសិករ ការបង្កើត

ថ្មីក្នុងប្រព័ន្ធដាំដុះ ការស្រាវជ្រាវប្រភេទដំណាំ និងការត្រៀមបង្ការ និងគ្រប់គ្រងគ្រោះមហន្តរាយ។ ក្នុងកំរិតផ្សេងទៀត មានអង្គការដូចជា មជ្ឈមណ្ឌលអូស្ត្រាលីសំរាប់ការស្រាវជ្រាវកសិកម្មអន្តរជាតិ កំពុងដឹកនាំតាមរយៈក្រុមបច្ចេកទេសរបស់ខ្លួនធ្វើការស្រាវជ្រាវជាមួយប្រជាជនមូលដ្ឋាន ខណៈពេលដែលអង្គការមួយចំនួនផ្សេងទៀតគាំទ្រវេទិកានិងបណ្តាញផ្សេងៗដែលទំនុកបំរុងចំពោះការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ និងការកសាងសមត្ថភាពក្នុងចំណោមមន្ត្រីនៅក្នុងក្រសួងនានា លើវិស័យធ្វើផែនការកាត់បន្ថយគ្រោះមហន្តរាយ និងការឆ្លើយតប ចំពោះហានិយភ័យ មានដូចជា: ការធ្វើគំរូធាតុអាកាស ការព្យាករ អាកាសធាតុ និងការប៉ាន់ប្រមាណភាពងាយរងគ្រោះ។

ការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុក៏កំពុងកើតមានផងដែរក្នុងវិស័យគ្រប់គ្រងធនធានធម្មជាតិ។ កិច្ចការទាំងនោះមានផ្តោតការយកចិត្តទុកដាក់ចំបងលើការកសាងសមត្ថភាពលើយុទ្ធសាស្ត្រគ្រប់គ្រង ការសំរបខ្លួនក្នុងការអភិរក្សប្រព័ន្ធអេកូឡូស៊ី ការការពារតំបន់ឆ្នេរ និងការចិញ្ចឹមជីវិត និងកិច្ចខិតខំប្រឹងប្រែងធ្វើឡើងសំដៅឲ្យ មានសន្តិសុខស្បៀង និងជីវិរសផ្សេងៗសំរាប់សហគមន៍ជនបទ ដើម្បីបង្កើតជាយុទ្ធសាស្ត្រសំរបខ្លួនមួយចំពោះការប្រែប្រួលអាកាសធាតុ។ កិច្ចខិតខំប្រឹងប្រែងបន្ថែមទៀតក៏កំពុងមានលើការបញ្ជ្រៀបនូវយន្តការបន្ថយ ការបញ្ចេញឧស្ម័នពីការបំផ្លាញ និងធ្វើឲ្យរិចរិលព្រៃឈើ (REDD)។ REDD មិនត្រឹមតែជាការស្តុកទុកឧស្ម័នកាបូនិច តែប៉ុណ្ណោះទេ ប៉ុន្តែ វាក៏ជាការកសាងសមត្ថភាពអ្នករស់នៅអាស្រ័យផលព្រៃឈើ ដើម្បីសំរាលនិងបន្សាំទៅនឹងផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុតាមរយៈការការពារតំបន់ទីជំរាល ការគ្រប់គ្រងទឹកជំនន់ និងការការពារ នូវជីវិរសចិញ្ចឹមជីវិតដើម្បីបន្តនូវការបន្សាំរបស់ពួកគេ។

ការប្រឈមនានាចំពោះប្រទេសកម្ពុជា លើការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ រួមមានលើរបៀបដោះស្រាយកង្វះធនធានទឹក ដែលនាំអន្តរាយដល់ប្រភពនៃទឹកស្អាតសំរាប់បរិភោគ និងកសិកម្ម ហើយផ្ទុយពីនេះ អំពីវិធីត្រូវដោះស្រាយចំពោះការមានទឹកច្រើនហួសហេតុ។ ប្រការនេះនាំឲ្យមាននូវតំរូវការផ្នែកហេត្ថារចនាសម្ព័ន្ធជាបន្ថែម ការសំរបអន្តរភ្នាក់ងារនានា ការសិក្សាស្រាវជ្រាវថែមទៀតដើម្បី កំណត់នូវការយល់ឃើញពីសំណាក់អ្នកប្រើប្រាស់ចំណេះដឹង និងការកសាងសមត្ថភាពបន្ថែមទៀត។ ខណៈពេលដែលប្រទេសកម្ពុជាបានចាប់ផ្តើមដំណាក់កាលឆ្លើយតបចំពោះការប្រែប្រួលអាកាសធាតុរយៈពេលខ្លី នោះគេគួរមានការផ្តោតសំខាន់ផងដែរលើតំរូវការផ្នែកចំណេះដឹងដើម្បីធ្វើផែនការបន្សាំ និងការឆ្លើយតបរយៈពេលវែង ឧទាហរណ៍ ការបង្កើតនូវគំរូអាកាសធាតុមួយដែលប្រសើរ ដើម្បីអភិវឌ្ឍនូវសន្ទស្សន៍តាមដាន ដែលមិនត្រឹមតែប្រើប្រាស់ក្នុងវិស័យបង្ការគ្រោះមហន្តរាយតែម្យ៉ាងនោះទេ ប៉ុន្តែ ក៏ប្រើប្រាស់វាសំរាប់តាមដាននូវសមត្ថភាពសំរបរបស់បុគ្គល និង



គំរោងនានាសំរាប់ដោះស្រាយការប្រែប្រួលអាកាសធាតុ ត្រូវគេឃើញមានស្រាប់ហើយនៅកម្ពុជា ប៉ុន្តែ វាតំរូវឲ្យ មានការរៀបចំ និងការកសាងសមត្ថភាពបន្ថែមទៀត

Photo credit: AIT/UNEP RRCAP/Serena Fortuna

ស្ថាប័ន និងគណៈកម្មការផ្សេងៗផងដែរ។ ចំណុចត្រូវចាប់ផ្តើម ដែលសមស្របមួយកំណត់នៅក្នុងការសិក្សាស្រាវជ្រាវនេះគឺការកំណត់នូវកំលាំងចលករនៃការប្រែប្រួលផ្នែកសង្គម-បរិស្ថានវិទ្យាតាមរយៈការចូលរួមបង្កើតសេនារីយ៉ូរួមគ្នា និងការលើកស្ទួយកិច្ចសន្ទនា និងការធ្វើផែនការរួមគ្នាជាមួយអ្នកពាក់ព័ន្ធទាំងអស់។ ខាងក្រោមនេះគ្រាន់តែជាការ បង្ហាញនូវវិស័យសំខាន់ៗដែលត្រូវការការកសាងសមត្ថភាព ដែលកំណត់ឡើងនៅក្នុងការសិក្សាស្រាវជ្រាវនេះ:

**ផ្នែកចំណេះដឹងដែល:**

- បង្កើតនូវទិន្នន័យប្រកបដោយគុណភាព និងងាយស្រួលប្រើប្រាស់អំពីអាកាសធាតុ រួមគ្នាជាមួយលក្ខខណ្ឌ ផ្នែកធាតុអាកាស និងជលសាស្ត្រ ដើម្បីសំរបសំរួលដល់ការកែលំអសេនារីយ៉ូ និងការព្យាករការប្រែប្រួល អាកាសធាតុ-ជាជំហានឆ្ពោះទៅកាន់ការប្រើប្រាស់ក្នុងកំរិតជាតិ និងកំរិតមូលដ្ឋាន។
- អភិវឌ្ឍជាបន្តនូវសមត្ថភាពរបស់ប្រជាជនកម្ពុជាទាក់ទងនឹងប្រព័ន្ធរបរកសកម្មផ្អែកលើ ដំណាំស្រូវដើម្បី ឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ ឧទាហរណ៍ ការធ្វើជាគំរូអំពីកា រដាំដុះលើកសិដ្ឋាន ការបង្ហាញពូជដំណាំដែលធន់ទ្រាំទៅនឹងទឹក ជំនន់ និងការរាំងស្ងួត ការប្រើប្រាស់បច្ចេកទេសសំណើមដូច ជាការ ត្រងយក ទឹកភ្លៀងចុងរដូវ ឬការប្រើប្រាស់ធារាសាស្ត្របង្រ្គប់ព្រមទាំងការគ្រប់គ្រងទឹក ដីជាតិដី និងធនធានដីធ្លី។
- ការយល់ដឹងយ៉ាងច្បាស់អំពីរបៀបដែលបណ្តាញសង្គមនិងស្ថាប័នក្រៅផ្លូវការប្រតិបត្តិដើម្បីសំរបសំរួល នូវវិធានការបន្សុាំ ឧទាហរណ៍ សមធម៌សង្គម បញ្ហាចោទលើភាពយុត្តិធម៌ និងវិសមភាពយេនឌ័រក្នុង បរិបទ បន្សុាំទៅនឹងការប្រែប្រប្រួកអាកាសធាតុ និង:
- កំណត់កត្តារាំងស្ទះ មិនឲ្យទទួលបានជោគជ័យ ចំពោះការធ្វើផែនការគ្រប់គ្រងសុខភាព និងធនធានធម្មជាតិ និងការបន្សុាំជាស្វ័យប្រវត្តិទៅនឹងផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ។

ដើម្បីកសាងចំណេះដឹងអនុវត្ត នោះមានតំរូវការដើម្បីកសាងនូវការយល់ដឹងឲ្យច្បាស់អំពីវិធីដែលបណ្តាញសង្គមនិងស្ថាប័នក្រៅផ្លូវការត្រូវប្រតិបត្តិ។ ធ្វើបែបនេះនឹងនាំឲ្យមានការធានាថាវិធានការបន្សុាំទៅនឹងការប្រែប្រួលអាកាសធាតុណាក៏ដោយ នឹងត្រូវបានគិតគូរយ៉ាងហោចណាស់ ក្នុងកំរិតអប្បរមានូវការពិចារណាលើសមធម៌ សង្គម និងយេនឌ័រ និងនាំយកនូវប្រសិទ្ធិផល និរន្តរភាព និងភាពអាចអនុវត្តទៅបានក្នុងដំណើរការបន្សុាំនេះ។

## ផ្នែកប្រព័ន្ធដែលៈ

- ដាក់បញ្ចូលគ្នានូវការព្យាករធាតុអាកាស និងអាកាសធាតុជាមួយការព្យាករជលសាស្ត្រដែលងាយប្រើប្រាស់ និងអាចអនុវត្តបានទាំងស្ថាប័ននៅថ្នាក់ជាតិ ថ្នាក់ខេត្ត និងថ្នាក់សហគមន៍មូលដ្ឋាន។
- ធានាឲ្យមានការវិភាគទិន្នន័យ ការធ្វើផែនការ និងការអនុវត្តគំនិតផ្តួចផ្តើមបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ និងការចែករំលែកចំណេះដឹងឆ្លងកាត់គ្រប់វិស័យទាំងអស់។
- រួមបញ្ចូលនូវរឿងរ៉ាវផ្នែកបរិស្ថាន ការប្រកបមុខរបរចិញ្ចឹមជីវិត ការអប់រំ សុខាភិបាល និងអាហារូបត្ថម្ភ ទៅក្នុងការ ធ្វើផែនការ និងឆ្លើយតបចំពោះគ្រោះហន្តរាយធម្មជាតិ។
- ធ្វើឲ្យមានភាពជាស្ថាប័ននូវ "ក្រមបទដ្ឋាន" ចំពោះវិធីសាស្ត្រស្រាវជ្រាវ និងសំរាប់អ្នកទាំងឡាយណាដែលកំពុងប្រតិបត្តិការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ
- បង្កើនភាពអាចទទួលបាន និងអាចប្រើប្រាស់នូវព័ត៌មានផ្នែកវិទ្យាសាស្ត្រអំពីអាកាសធាតុ និងលក្ខខណ្ឌធាតុអាកាសនៅថ្នាក់មូលដ្ឋាន និងសំរាប់គោលបំណងធ្វើការសំរេចចិត្តនៅថ្នាក់ជាតិ។
- បង្កើតលទ្ធភាពប្រើប្រាស់ដី និងការកាន់កាប់ឥណទាន ការវិនិយោគផ្នែកកសិកម្ម ការទុកដាក់បំរុង និង បច្ចេកវិទ្យាពីសំណាក់ស្ត្រី និងៈ
- ស្ថាបនានូវវិធានការផ្នែកសង្គម បច្ចេកវិទ្យា ភាពជាស្ថាប័ន និងគោលនយោបាយ ដើម្បីដោះស្រាយចំពោះ ឧបសគ្គដែលរារាំងការចូលរួមពីសំណាក់អ្នកពាក់ព័ន្ធទាំងអស់។

អ្វីដែលគួរកត់ចំណាំនោះ គឺនៅមិនទាន់មានប្រព័ន្ធសមស្របណាមួយ ដែលអាចដាក់ការព្យាករធាតុអាកាស និងអាកាសធាតុ ជាមួយព័ត៌មានជលសាស្ត្រសំរាប់ការប្រើប្រាស់នៅថ្នាក់ជាតិ ថ្នាក់ខេត្ត និងថ្នាក់សហគមន៍រួមជា មួយគ្នានៅឡើយ។ បំណងដែលលើកឡើងនេះ គឺដើម្បីធានាថា ចំណេះដឹងដែលបានបង្កើតឡើងទាក់ទងនឹង វិស័យទាំងនេះ នឹងត្រូវនាំយកទៅអនុវត្តយ៉ាងត្រឹមត្រូវ និងជាប់លាប់។ ដើម្បីសំរបសំរួល សកម្មភាពនេះ ត្រូវមានការបង្កើតនូវប្រព័ន្ធសំខាន់ៗ និងត្រូវតែសំរបសំរួលនូវការវិភាគទិន្នន័យឆ្លងកាត់វិស័យ ការចែករំលែកចំណេះដឹង ការធ្វើផែនការ និងការអនុវត្តនូវការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ។

## ផ្នែករចនាសម្ព័ន្ធដែល:

- ដែលមានសមត្ថភាពអនុវត្ត និងគាំទ្រដល់ការបង្កើត ផ្សព្វផ្សាយបន្តនូវចំណេះ ដឹងអំពីការបន្សាំទៅនឹងការ ប្រែប្រួលអាកាសធាតុ
- ដែលផ្តល់នូវវេទិកា និងបណ្តាញយ៉ាងជាប់លាប់ដើម្បីប្រតិបត្តិវេទិកា និងបណ្តាញ ទិម្មយៗផ្តោតការយកចិត្តទុកដាក់ចំបងលើការបន្សាំទៅនឹងការប្រែប្រួល អាកាសធាត សំរាប់ អ្នកបំរើការងារផ្នែកអភិវឌ្ឍន៍ ត្រូវធ្វើសកម្មភាពជាមួយ និងអ្នកធ្វើគោនយោបាយ និង
- សំរបសំរួល និងរៀបចំការកសាងសមត្ថភាព រាប់ចាប់តាំងពីថ្នាក់ជាតិ រហូតដល់ថ្នាក់ឃុំក្នុងគោលបំណងដើម្បីកែលំអលទ្ធភាពទទួលបាន និងមានសមត្ថភាពរៀបចំគំរោងឆ្លើយតបចំពោះ ការបន្សាំទៅនឹងការ ប្រែប្រួលអាកាសធាតុ និងការធ្វើការសំរេចចិត្ត។

ថ្វីបើអ្នកខ្លះនិយាយថា មានព័ត៌មានដ៏ច្រើនសន្ធឹកដែលអាចរកបានទាក់ទងនឹងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុក៏ដោយ ប៉ុន្តែភាគច្រើននៃព័ត៌មានទាំងនោះពិបាករក សូម្បីព័ត៌មានមូលដ្ឋាន ឬទិន្នន័យផ្សេងៗដែលបង្កើតថ្មីៗស្របតាមសេចក្តីត្រូវការ។ ស្ថានភាពនេះជាញឹកញាប់បង្កការរាំងស្ទះចំពោះការប្រើប្រាស់ចំណេះដឹងបន្សាំ និងគំរិតនៃបរិបទសំរាប់អនុវត្តជាក់លាក់ផ្សេងៗ។ ការកំណត់អាទិភាពសំរាប់សកម្មភាពដោយក្រុមអ្នកពាក់ព័ន្ធដែលចូលរួមក្នុងការសិក្សានេះ បានបង្ហាញពីតំរូវការ ដើម្បីបង្កើតនូវ "កន្លែងជាក់លាក់" សំរាប់ចំណេះដឹងនិងការដាក់បញ្ចូលនូវការបន្សាំទៅនឹងការប្រែប្រួលអាកាសការគាំទ្រសំខាន់ចំពោះការបង្កើតនូវការរៀបចំធ្វើគំរោងការអនុវត្តគំរោងនិងដំណើរការសំរេចចិត្តអំពីការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ ។

## ផ្នែកគោលនយោបាយដែល:

- គាំទ្រដល់ការដាក់បញ្ចូលនូវការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ ទៅក្នុងគោលនយោបាយថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ការធ្វើផែនការ និងដំណើរការរៀបចំថវិកា។
- លើកទឹកចិត្តផ្នែកឯកជនឲ្យចូលរួមក្នុងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ
- គាំទ្រការរួមបញ្ចូលនូវផែនការបន្សាំសំរាប់អនុផ្នែកនានា ដូចជា ជលផល និងវារីវប្បកម្ម ទៅក្នុងផែនការជាតិសំរាប់ការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ។
- គាំទ្រការចូលរួមរបស់សហគមន៍ដែលពឹងផ្អែកលើមុខរបរកសិកម្ម និងនេសាទ ទៅក្នុងការធ្វើផែនការសេដ្ឋកិច្ចជាតិ និងវិមជ្ឈការ។

- ផ្ដល់នូវការរួមបញ្ចូលនូវវិស័យគ្រប់គ្រងធនធានធម្មជាតិ ទៅក្នុង គោលនយោបាយ ឆ្លើយតបចំពោះគ្រោះមហន្តរាយ និងផែនការអភិវឌ្ឍន៍។
- បញ្ចូលការសំរេចចិត្តផ្អែកលើមូលដ្ឋានស្រាវជ្រាវចំពោះការស្រាវជ្រាវផ្លូវការ និងមិនផ្លូវការ នៅថ្នាក់មូលដ្ឋានទៅគ្រប់វិស័យសិក្សាទាំងអស់ និង
- ធានាថាមានកិច្ចសហការនិងការចែករំលែកព័ត៌មានក្នុងចំណោមអ្នកពាក់ព័ន្ធក្នុងការបន្សុំាទៅនឹងការប្រែប្រួលអាកាសធាតុទាំងអស់ រាប់ចាប់ពីមន្ទីរវិស័យ រហូតដល់គ្រឹះស្ថានស្រាវជ្រាវ អង្គការមិនមែនរដ្ឋាភិ បាល និងសហគមន៍មូលដ្ឋាន។

មានកង្វះខាតផ្នែកគោលនយោបាយដែលគាំទ្រដល់ការបញ្ជ្រាប ការបន្សុំាទៅនឹងការប្រែប្រួលអាកាសធាតុទៅក្នុងគោលនយោបាយថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដំណើរការ ធ្វើផែនការ និងផែនការថវិកា។ ការសិក្សានេះ នឹងលើកឡើងនូវសារៈសំខាន់នៃការបង្កើត និងដាក់ឲ្យអនុវត្តនូវគោលនយោបាយទាំងនេះ នឹងជួយ ឲ្យមាន ការធានាថា ចេតនាទាំងឡាយនៃចំណេះដឹងអំពីការបន្សុំាទៅនឹងការប្រែប្រួលអាកាសធាតុប្រព័ន្ធ និងរចនា សម្ព័ន្ធទាំងឡាយ នឹងត្រូវបានប្រើប្រាស់ប្រកបដោយប្រសិទ្ធិភាព និងមានមូលនិធិជានិរន្តន៍។ លើសពីនេះទៀត គោលនយោបាយមួយពិតជាត្រូវការដើម្បីគាំទ្រដល់ការចូលរួមពីសហគមន៍ដែលរស់នៅពឹងអាស្រ័យ លើមុខរបរ កសិកម្ម និងនេសាទ ក្នុងការធ្វើផែនការសេដ្ឋកិច្ចនៅថ្នាក់ជាតិ និងថ្នាក់វិមជ្ឈការ។ ធ្វើដូច្នេះ នឹងនាំឲ្យមាន ការរំកីលទៅមុខប្រកបដោយប្រសិទ្ធិភាពរបស់ "គោលនយោបាយ" ឲ្យទៅជិតការអនុវត្ត និងការគាំទ្រដល់ការប្រតិបត្តិនៅឯមូលដ្ឋាន ជាក់ស្ដែង មានការធ្វើឲ្យប្រសើរឡើងនូវភាពទាក់ទិន និងនិរន្តរភាពនៃអន្តរាគមន៍។

អ្វីៗដូចដែលបានបរិយាយខាងលើ នឹងត្រូវអនុវត្តដើម្បីកាត់បន្ថយហានិយភ័យនានា តាមរយៈការកែលំអទំលាប់អនុវត្តផ្នែកកសិកម្ម និងធ្វើឲ្យកាន់តែសម្បូរបែបនូវការប្រកបមុខរបរចិញ្ចឹមជីវិតផ្នែកកសិកម្ម ការកែលំអប្រព័ន្ធសុខាភិបាលដើម្បីដោះស្រាយជម្ងឺទាំងឡាយដែលជាប់ទាក់ទងដល់ការប្រែប្រួលអាកាសធាតុ និងផលវិបាកផ្នែកសុខភាពផ្សេងទៀត និងជាពិសេស ការស្វែងរកមធ្យោបាយដោះស្រាយផលប៉ះពាល់ផ្នែកសង្គម ដែលមានមែកធាងពីការប្រឈមផ្នែកអាកាសធាតុ និងរួមទាំងការធ្វើចំណាកស្រុក និងទំនាស់លើការទាញយកផលពីធនធានធម្មជាតិ។

តាមរយៈនៃការពិនិត្យមើលផ្នែកអក្សរសាស្រ្តនិងយោងតាមទស្សនៈផ្សេងៗ ពីសំណាក់អ្នក ដែលយើងបានពិគ្រោះវាច្បាស់លាស់ណាស់ថាចំណេះដឹងអំពីការបន្សុាំទៅនឹងការប្រែប្រួលអាកាសធាតុកំពុងកើតឡើងជាបណ្តើរៗ គ្រាន់តែថាចំណេះដឹងទាំងនោះស្ថិតនៅដំណាក់កាល "រៀនសូត្រ" នៅឡើយ។ អ្នកប្រើប្រាស់ចំណេះដឹងដែលបានបង្កើត មួយភាគធំស្ថិតនៅក្នុងដៃរបស់អ្នកដែលរៀបចំប្រមូលចំណេះដឹងនៅឡើយ អ្វីដែលយើងចង់លើកទឹកចិត្តនោះគេត្រូវ "ប្រមូលចំណេះដឹង" ហើយនាំយកទៅកាន់ការសំរបសំរួល ក្នុងចំណោមពហុអ្នកពាក់ព័ន្ធ។ ទោះជាយ៉ាងនេះក្តីអ្វីដែលនៅមិនទាន់ច្បាស់នោះគឺកំលាំងចលករនៃអ្នកប្រើប្រាស់ចំណេះដឹងនៅថ្នាក់សហគមន៏ ទំហំនៃ ចំណេះ ដឹងដែលត្រូវប្រមែប្រមូល របៀបចាត់អាទិភាព និងថាតើ ដំណើរការនោះមានប្រសិទ្ធិភាពប៉ុណ្ណា ឬសូម្បី វិធីដែលត្រូវប្រតិបត្តិក៏ស្ថិតនៅជាចំណោទនៅឡើយ។

ការកសាងសមត្ថភាពជាជំហានៗ ដើម្បីដោះស្រាយការប្រែប្រួលអាកាសធាតុកំពុងមានវត្តមាននៅកម្ពុជា ទោះជាយ៉ាងនេះក្តីប្រទេសនេះនៅត្រូវការការអភិវឌ្ឍផ្នែករចនាសម្ព័ន្ធ និងសមត្ថភាពជាបន្តទៅទៀត។ បណ្តាសកម្មភាពទាំងឡាយនាពេលបច្ចុប្បន្ននេះ បានតាក់តែងឡើងផ្អែកលើមូលដ្ឋាននៃអាណត្តិដែលជាប់ទាក់ទងទៅនឹងក្របខ័ណ្ឌ អភិវឌ្ឍន៍ចំនួន២ ពោលគឺសន្តិសុខស្បៀង និងការប្រកបមុខរបរចិញ្ចឹមជីវិត។ ស្តែងចេញពីហេតុផលនេះគេសង្កេតឃើញថាមួយភាគធំនៃលក្ខខណ្ឌសំរាប់ការបន្សុាំទៅនឹងការប្រែប្រួលអាកាសធាតុពុំបានធ្វើឡើងដោយបានគិតទុកជាមុនទេ ពោលគឺធ្វើឡើងដោយឆ្លើយតបចំពោះហេតុការណ៏ដែលកើតឡើងរួចហើយប៉ុណ្ណោះ ឧទាហរណ៏ កង្វះខាតការយល់ឃើញអំពីបរិបទនៃការប្រែប្រួល អាកាស ធាតុ។អ្វីដែលត្រូវការជាចាំបាច់រួមមានការផ្លាស់ប្តូរជាគ្រឹះនូវរបៀបបន្សុាំទៅនឹងការប្រែប្រួលអាកាសធាតុដែលនេះហួសពីការដែលគ្រាន់តែដោះស្រាយតំរូវការជាបន្ទាន់....និងឆ្ពោះទៅកាន់នវានុវត្តថ្មីៗ ឲ្យត្រូវតាមសេនារីយ៉ូអាកាសធាតុនាពេលអនាគត។ អ្វីដែលស្នើឡើងនេះ អាចសំរេចបានលុះណាតែមានការកសាងជារួមលើមូលដ្ឋានចំណេះដឹងអំពីអ្វីដែលជាតំរូវការពិតរបស់កម្ពុជាដើម្បីបន្សុាំទៅនឹងការប្រែប្រួលអាកាសធាតុ និងអំពីរបៀបដែលធ្វើឲ្យទទួលបានជោគជ័យតាមការអនុវតដោយប្រើប្រាស់ធនធានទាំងឡាយដែលមានក្នុងដៃ។

*សំគាល់: ឯកសារដើមនៃការសិក្សានេះរៀបចំឡើងជាភាសាអង់គ្លេស ហើយបានប្រែសំរួលទៅជាខេមរភាសាដោយ តួត ចំរើន សូមមេត្តាអភ័យទោសពីសំណាក់អ្នកអាន និងប្រើប្រាស់ ចំពោះការប្រែសំរួលជាភាសាខ្មែរអាចមានពាក្យ និងឃ្លា ប្រយោគខ្លះពិបាកយល់ និង ឬមានកំហុសឆ្គង។*

# ការសិក្សាក្នុងវិសាលភាពមួយស្តីពីការ បន្ស៊ាំទៅនឹងការប្រែប្រួលអាកាសធាតុ នៅកម្ពុជា

## ការពិនិត្យផ្នែកអក្សរសាស្ត្រ និងទស្សនៈរបស់អ្នកចូលរួម

### ប្រវត្តិនៃការសិក្សា

តាមរយៈការស្វះស្វែងរកការសំរបសំរួលឲ្យកាន់តែប្រសើរនូវចំណេះដឹងអំពីការបន្ស៊ាំទៅនឹងការប្រែប្រួលអាកាសធាតុនៅថ្នាក់មូលដ្ឋាន និងថ្នាក់ជាតិ ទើបវេទិកាចំណេះដឹងអំពីការបន្ស៊ាំទៅនឹងការប្រែប្រួលអាកាសធាតុថ្នាក់តំបន់ តាមរយៈការជួយគាំទ្រជាថវិកាពីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិប្រទេសស៊ុយអែដ“ស៊ីដា” ទើបវេទិកានេះបានឧបត្ថម្ភការសិក្សាក្នុងវិសាលភាពមួយ ស្តីអំពីការបន្ស៊ាំទៅនឹងការប្រែប្រួលអាកាសធាតុនៅប្រទេសកម្ពុជា។ ដោយមានការជួយគាំទ្រពីសំណាក់ដៃគូអន្តរជាតិ ដែលរួមមានៈ វិទ្យាស្ថានបរិស្ថានក្រុងស្តុកហូម (SEI) លេខាធិការដ្ឋានបរិស្ថានសំរាប់ទ្វីបអាស៊ីនៃប្រទេសស៊ុយអែត (SENSA) កម្មវិធីបរិស្ថានសហប្រជាជាតិ (UNEP)និងវិទ្យាស្ថានបច្ចេកទេសអាស៊ី(AIT)តាមរយៈមជ្ឈមណ្ឌលធនធានថ្នាក់តំបន់ នៃភូមិភាគអាស៊ី និងប៉ាស៊ីហ្វិក (RRCAP) រួម ជាមួយដៃគូកម្ពុជាជាម្ចាស់ផ្ទះ— ពោលគឺវិទ្យាស្ថានគ្រប់គ្រងធន ធានធម្មជាតិដោយ មានការចូលរួមពីសហគមន៍ (CBNRM LearningInstitute)ទើបធ្វើឲ្យការសិក្សាទំហំមួយនេះបានពិនិត្យមើលយ៉ាងទូលំទូលាយផ្នែកអក្សរ សាស្ត្រ និងទស្សនៈផ្សេងៗពីភ្នាក់ងាររដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល (NGO) គ្រឹះស្ថានសិក្សាស្រាវជ្រាវ និងជាពិសេស ស្ថាប័ននៅថ្នាក់សហគមន៍មូលដ្ឋាន

បរិបទនៃ “ការបន្ស៊ាំ” នៅក្នុងការសិក្សាទំហំមួយនេះ ត្រូវបានគេយល់ឃើញថាជាការប្រមូលផ្តុំនូវដំណើរការនៃការបន្ស៊ាំ ទាំងការបន្ស៊ាំជាស្វ័យប្រវត្តិ និង ឬ មានផែនការដែលនាំឲ្យមានការកែតំរូវចំពោះលក្ខខណ្ឌថ្មី ការសង្កត់ទម្ងន់ និងហានិភ័យធម្មជាតិនៅចំពោះមុខនៃការអភិវឌ្ឍ និងការប្រើប្រាស់ចំណេះដឹង ប្រព័ន្ធ និងរចនាសម្ព័ន្ធ

ដែលជួយជំរុញការបន្សាំទៅនឹងការប្រែប្រួលធម្មជាតិរបស់ប្រជាជនកម្ពុជា។ គេគួរកត់សំគាល់ថា ការកែតំរូវចំពោះលក្ខខណ្ឌថ្មី ក្នុងន័យទូលំទូលាយ ព្រមទាំងការចង្អុលទិសចំពោះយុទ្ធសាស្រ្ត "សំរាល" ដាក់លាក់ក្នុង បរិបទនៃការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុក៏ជាគោលបំណងមួយនៃការសិក្សានេះផងដែរ។

## ការឆ្លើយតបជាស្ថាប័នចំពោះការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ

យុទ្ធសាស្រ្តជាតិកាត់បន្ថយភាពក្រីក្ររបស់កម្ពុជា បានកំណត់យ៉ាងច្បាស់ថា គ្រោះមហន្តរាយធម្មជាតិ មានជាអាទិ៍ គ្រោះទឹកជំនន់ និងគ្រោះរាំងស្ងួតជាកត្តាយ៉ាងសំខាន់ដែលបាន និងបន្តធ្វើឲ្យមានកំណើនភាពងាយរងគ្រោះ ផ្នែកសេដ្ឋកិច្ចនៃប្រជាជនក្រីក្រនៅទីជនបទ ក្នុងនោះរួមមានទាំងការដាក់បន្ទុកប្រកបដោយវិសមភាពសំរាប់ការដោះស្រាយចំពោះស្រ្តី។ តាមទស្សនៈនេះ ការប្រែប្រួលអាកាសធាតុមិនមែនត្រឹមតែជាបញ្ហាទាក់ទងនឹងបរិស្ថានតែប៉ុណ្ណោះទេ ប៉ុន្តែវាក៏ជាបញ្ហានៃការអភិវឌ្ឍផងដែរ។ នៅក្នុងបរិបទនេះ យន្តការមួយចំនួននៃកិច្ចសហការ និង ការសំរបសំរួលត្រូវបានដាក់ឲ្យអនុវត្តដើម្បីសំរបសំរួលនូវការដាក់បញ្ចូលគ្នានៃកិច្ចខិតខំប្រឹងប្រែង ដើម្បីធ្វើឲ្យមាន ការយល់ដឹងកាន់តែប្រសើរអំពីផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ និងការឆ្លើយតបចំពោះបញ្ហានេះឲ្យបានសមស្របពីគ្រប់វិស័យទាំងអស់របស់សង្គម។ នៅក្នុងផ្នែកនេះ មានការបង្ហាញនូវស្ថាប័នរដ្ឋាភិបាលសំខាន់ៗ ដែលបានរួមចំណែកក្នុងដំណើរការនេះ។

### ស្ថាប័នសំរបសំរួលថ្នាក់ជាតិសំខាន់ៗដែលពាក់ព័ន្ធក្នុងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ

#### គណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ

គណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ (NCCC)ត្រូវបានបង្កើតឡើងដោយអនុក្រឹត្យតែងតាំង នៅថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០០៦។ គណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ ជាយន្តការអន្តរក្រសួងមួយដែលទទួលបានអាណត្តិពីរាជរដ្ឋាភិបាល ដើម្បីរៀបចំសំរបសំរួល

និងត្រួតពិនិត្យមើលលើការអនុវត្ត គោលនយោបាយ យុទ្ធសាស្ត្រ ឯកសារផ្លូវច្បាប់ ផែនការ និងកម្មវិធីនានារបស់រាជរដ្ឋាភិបាល ដើម្បីដោះស្រាយបញ្ហានានាទាក់ទងនឹងការប្រែប្រួលអាកាសធាតុនៅក្នុងប្រទេស ដែលវាជាការរួមិភាគទានយ៉ាងសំខាន់ចំពោះការការពារបរិស្ថាននិងធនធានធម្មជាតិ និងការប្រមើលមើល និងទប់ស្កាត់ការផ្លាស់ប្តូរធាតុអាកាសដែលបង្កឡើង ដោយមនុស្ស ដែលអាចនាំបណ្តាលឲ្យមាននូវផលប៉ះពាល់អាក្រក់ទៅលើសុខុមាលភាពរបស់មនុស្ស។ គណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ ជាគណៈកម្មាធិការអន្តរក្រសួង ស្ថិតក្រោមអធិបតេយ្យភាពដ៏ខ្ពង់ខ្ពស់របស់សម្តេច ហ៊ុន សែន រួមជាមួយរដ្ឋលេខាធិការ និងអនុរដ្ឋលេខាធិការមកពី ១៩ក្រសួង និងភ្នាក់ងាររដ្ឋាភិបាលផ្សេងទៀត (Mony, K., and C. Thou, 2007)។ សូមមើលគំនូសបង្ហាញ ១ អំពីទំនាក់ទំនងអង្គការលេខរបស់ គណៈកម្មាធិការគ្រប់គ្រងការប្រែប្រួលអាកាសធាតុ។

## ក្រុមបង្គោល និងអង្គការមិនមែនរដ្ឋាភិបាលដែលរួមចំណែកក្នុងការបន្សុាំទៅ នឹងការប្រែប្រួលអាកាសធាតុ

### ក្រុមជំនាញសំរាប់ប្រទេសមានការលូតលាស់តិច:

ក្រុមជំនាញសំរាប់ប្រទេសមានការលូតលាស់តិច (LEG) ដែលបានបង្កើតឡើងដោយសេចក្តីសំរេចចិត្តលេខ 29/CP.7 នៅឆ្នាំ ២០០១ ត្រូវបានប្រគល់អាណត្តិក្នុងលក្ខខណ្ឌយោង របស់ខ្លួនដើម្បីសំរបសំរួលការផ្លាស់ប្តូរព័ត៌មាន និងការលើកកំពស់ការប្រមូលផ្តុំគំនិតជាមួយស្ថាប័នបរិស្ថានពហុ ភាគីផ្សេងៗទៀត។ ក្រុមនេះក៏មានតួនាទីសំខាន់ក្នុងការរៀបចំនូវកម្មវិធីសកម្មភាពជាតិដើម្បីបន្សុាំទៅនឹងការ ប្រែប្រួលអាសធាតុផង និងធ្វើជាក្រុមបង្គោលចូលរួមក្នុងការអនុវត្តផង. (Danida, 2008).

**ក្រុមការងារអន្តរជាតិស្តីពីការប្រែប្រួលអាកាសធាតុ (IPCC) អង្គការឧតុនិយមពិភពលោក (WMO) និងកម្មវិធី បរិស្ថានសហប្រជាជាតិ (UNEP)** ផ្នែកមួយនៃកិច្ចខិតខំប្រឹងប្រែងរួមគ្នា ក្រោមគំនិតផ្តួចផ្តើមធ្វើការប៉ាន់ប្រមាណផលប៉ះពាល់ និងការបន្សុាំទៅនឹងការប្រែប្រួលអាកាសធាតុ ក្រុមការងារអន្តរជាតិស្តីពីការប្រែប្រួលអាកាសធាតុ អង្គការឧតុនិយមពិភពលោក និងកម្មវិធីបរិស្ថានសហប្រជាជាតិ បានប្រតិបត្តិរួមគ្នានូវភារកិច្ចទាំងឡាយខាងក្រោមនេះ:

## ក្រសួងបង្គោល និងរដ្ឋបាលពាក់ព័ន្ធផ្សេងៗទៀត

### ការិយាល័យប្រែប្រួលអាកាសធាតុ កម្ពុជា

នៅខែមិថុនា ឆ្នាំ ២០០៣ រាជរដ្ឋាភិបាលកម្ពុជា បានបង្កើតការិយាល័យប្រែប្រួលអាកាសធាតុ (CCCO) ដែលសព្វ ថ្ងៃបានក្លាយទៅជា នាយកដ្ឋានប្រែប្រួលអាកាសធាតុ (CCD) ជានាយកដ្ឋានដែលទទួលបន្ទុកទាំងស្រុងចំពោះ បញ្ហានៃការប្រែប្រួលអាកាសធាតុ។ សមាសភាពផ្នែកបច្ចេកទេសនៃនាយដ្ឋាននេះ ស្ថិតនៅក្នុងក្រសួងបរិស្ថាន ហើយអ្នកបច្ចេកទេសទាំងនេះទទួលបានអាណត្តិជាមួយនឹងភារកិច្ចអនុវត្តសកម្មភាពបច្ចេកទេសទាំងអស់ទាក់ទង ដល់ការអនុវត្តឲ្យស្របតាមអនុសញ្ញាក្រប ខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ(UNFCCC) និងសកម្មភាពទាំងឡាយដែលទាក់ទងទៅនឹងអនុសញ្ញាអន្តរជាតិស្តីពីបរិស្ថាន។ នាយកដ្ឋានប្រែប្រួលអាកាសធាតុគាំទ្រ និងរៀបចំក្រុមការងារបច្ចេកទេសអន្តរក្រសួងដែលមានឯកទេសលើវិស័យផ្សេងៗ ដូចជា ថាមពល និងព្រៃឈើ និងវិស័យទាំងឡាយណាក្រោមមូលបទប្រែប្រួលអាកាសធាតុ ដូចជា ការធ្វើសារពើភ័ណ្ឌឧស្ម័ន ផ្ទះកញ្ចក់ (GHG) ការសំរាលការបំភាយឧស្ម័ន ការសំរាលដោយស្ម័គ្រចិត្ត និងការបន្សាំ យន្តការអភិវឌ្ឍន៍ស្អាត (CDM) និងការ អនុវត្តនូវអនុសញ្ញាក្របខណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (UNFCCC)។

## គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ

គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ (NCDM) ជាភ្នាក់ងារថ្នាក់ជាតិទទួលខុសត្រូវផ្តល់នូវការសង្គ្រោះបន្ទាន់ និងបង្កើតវិធានការបង្ការដើម្បីកាត់បន្ថយការបាត់បង់អាយុជីវិត និងទ្រព្យសម្បត្តិបណ្តាលមកពីគ្រោះមហន្តរាយធម្មជាតិ។ គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយត្រូវបានបង្កើតឡើងនៅឆ្នាំ ១៩៩៥ ក្នុងនាមជា ស្ថាប័នអន្តរក្រសួងមួយ ដែលមានសមាសភាពសមាជិកមកពីក្រសួងពាក់ព័ន្ធ និងមកពីកងកម្លាំងប្រដាប់អាវុធ។ ជាបន្តបន្ទាប់មកទៀត គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយត្រូវបានបង្កើតឡើងនៅថ្នាក់ខេត្ត និងស្រុកនៅទូទាំងប្រទេស។ នៅឆ្នាំ ២០០៦ រាជរដ្ឋាភិបាលកម្ពុជាបានចេញនូវអនុក្រិត្យមួយដើម្បីបង្កើត គណៈកម្មការ ឃុំ គ្រប់គ្រងគ្រោះមហន្ត (CCDM) ក្នុងគោលបំណងដើម្បីពង្រឹងប្រព័ន្ធស្ថាប័ននៅថ្នាក់មូលដ្ឋាន។

## អាជ្ញាធរជាតិទទួលបន្ទុកយន្តការអភិវឌ្ឍន៍ស្អាត

រាជរដ្ឋាភិបាលកម្ពុជាបានតែងតាំងក្រសួងបរិស្ថានជា អាជ្ញាធរជាតិទទួលបន្ទុកយន្តការអភិវឌ្ឍន៍ស្អាតនៅថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៣។ នាយកដ្ឋានប្រែប្រួលអាកាសធាតុដើរតួនាទីជាលេខាធិការដ្ឋាននៃជនបង្គោលរបស់ អនុសញ្ញាក្របខណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ និងជាអាជ្ញាធរជាតិទទួលបន្ទុកការអនុវត្តតាមពិធីសារក្រុងក្យូតូ។ មានការត្រួតស៊ីគ្នាផ្នែកស្ថាប័នរវាងអាជ្ញាធរជាតិទទួលបន្ទុកយន្តការអភិវឌ្ឍន៍ស្អាត ជាមួយគណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ (NCCC) និងគណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា (CCC) ។

## ស្ថាប័នថ្នាក់ក្រសួងសំខាន់ៗដែលរួមចំណែកដល់ការបន្សាំទៅនឹងការ ប្រែប្រួលអាកាសធាតុ

### ក្រសួងធនធានទឹក និងឧតុនិយម

ក្រសួងធនធានទឹក និងឧតុនិយម ដើរតួនាទីកណ្តាលក្នុងការសំរាលផលប៉ះពាល់បណ្តាលមកពីមហន្តរាយធម្មជាតិ ដូចជាទឹកជំនន់ និងគ្រោះរាំងស្ងួត តាមរយៈការអនុវត្តនូវវិធានការបន្សាំទាក់ទងនឹងការគ្រប់គ្រងទឹកជំនន់រយៈ ពេលវែង។

### នាយកដ្ឋានឧតុនិយម នៃក្រសួងធនធានទឹក និងឧតុនិយម

នាយកដ្ឋានឧតុនិយម ស្ថិតនៅក្រសួងធនធានទឹក និងឧតុនិយម ជានាយកដ្ឋានបរង្គាលមួយសំរាប់ផ្តល់នូវការ ព្យាករ និងព័ត៌មានអំពីធាតុអាកាស និងអាកាសធាតុដល់រាជរដ្ឋាភិបាលកម្ពុជា និងសាធារណជនទូទៅអំពីស្ថាន ភាព ធាតុអាកាស និងអាកាសធាតុ។ (Danida, 2008).

### ក្រសួងបរិស្ថាន

ក្រៅពីការបង្កើតផែនការសកម្មភាពអំពីការប្រែប្រួលអាកាសធាតុនិងផែនការយុទ្ធសាស្រ្តអំពីប្រព័ន្ធជីវសាស្រ្តចំរុះ (NBSAP) ការផ្សព្វផ្សាប់ណាមួយទៅនឹងការបន្សាំចំពោះការប្រែប្រួលអាកាសធាតុនៅតំបន់ឆ្នេរតាមរយៈ គោលនយោបាយ និងនីតិវិធីនានារបស់រដ្ឋាភិបាលឃើញនៅទន់ខ្សោយនៅឡើយ។ ក្នុងផែនការសកម្មភាពអំពីការប្រែប្រួលអាកាសធាតុនិងកម្មវិធីសកម្មភាពជាតិដើម្បីបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ (NAPA) បានផ្តល់អនុសាសន៍សំរាប់សកម្មភាពទាំងឡាយដែលមានកំរិតព្រំដែនមួយ–ដែលសកម្មភាពភាគច្រើនសង្កត់ធ្ងន់លើការស្រាវជ្រាវ ដើម្បីប៉ាន់ប្រមាណផលប៉ះពាល់ដ៏មានសក្តានុពល និងវិធានការឆ្លើយតបដែលអាចមានចំពោះការកើនឡើងនូវកំរិតនិវៅទឹកសមុទ្រ(MoE, 2005) សូមមើលបន្ថែមនៅប្រអប់ ១ អំពីអាណត្តិរបស់ក្រសួងបរិស្ថាន។

### ក្រសួងសុខាភិបាល

ក្រសួងសុខាភិបាល ដោយអនុវត្តតាមផែនការយុទ្ធសាស្ត្រជាតិវិស័យសុខាភិបាលដំណាក់កាលទី ២ ឆ្នាំ ២០០៨_២០១៥ បានដើរតួនាទីដ៏ចង្អុលគាត់វិស័យមួយក្នុងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ—ពោលគឺផ្តោតការយកចិត្តទុកដាក់ចំពោះ យេនឌ័រ និងសុខភាពរបស់ជនងាយរងគ្រោះ ឬក្រុមជនមានតំណាងភាគតិច។ អ្វីដែលជាអាណត្តិជាស្នូលនៃក្រសួងសុខាភិបាលគឺពង្រឹងការធ្វើអន្តរាគមន៍សុខាភិបាលដល់សាធារណជន និងការលើក ស្ទួយប្រសិទ្ធិភាពនៃការកសាងភាពជាដៃគូ ជាមួយ សាធារណជន និងផ្នែកឯកជន ក្នុងការផ្តល់សេវាដល់ជនក្រីក្រ និងក្រុមជនងាយរងគ្រោះលើវិស័យអនាម័យផ្ទាល់ខ្លួន និងសាធារណៈ សុខភាពតាមសាលាហានិយភ័យ បរិស្ថាន សុខភាព និងការបន្ថយមហន្តរាយផ្នែក បរិស្ថាន និងផលប៉ះពាល់ផ្នែកសុខភាពពីជម្ងឺផ្សេងៗ។ (MoH, 2008)

### ក្រសួងផែនការ

ក្រសួងផែនការដើរតួនាទីជាគន្លឹះក្នុងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុដោយ អនុលោមតាមលំនាំនៃការការអភិវឌ្ឍផែនការយុទ្ធសាស្ត្រជាតិកាត់បន្ថយភាព ក្រីក្របច្ចុប្បន្នកម្ម ២០០៩_២០១៣ (Chhieng Yanara, H. E., 2009). មើលប្រអប់ ២ តួនាទី និងការទទួលខុសត្រូវរបស់ក្រសួងផែនការទាក់ទងនឹងការប្រែប្រួលអាកាស ធាតុ។

| ប្រអប់ ២_ ក្រសួងផែនការ _តួនាទី និងការទទួលខុសត្រូវក្នុងសកម្មភាពទាក់ទងដល់ការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ |
| --- |
| _ ផ្តល់ការណែនាំផ្នែកបច្ចេកទេសដល់ក្រសួងពាក់ព័ន្ធ និងភ្នាក់ងារនានា អំពីការអភិវឌ្ឍនូវខ្លឹមសារនិងដំណើរ ការជារួមសំរាប់ការស្ថាបនាផែនការយុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ បច្ចុប្បន្នកម្ម២០០៩_២០១៣<br>_ ផ្តល់នូវក្របខណ្ឌថ្នាក់ជាតិសំរាប់ការដាក់បញ្ចូល កម្មវិធីសកម្មភាពជាតិដើម្បីបន្សាំទៅនឹងការប្រែប្រួល អាកាសធាតុ និងការដោះស្រាយការប្រែប្រួលអាកាសធាតុនៅគ្រប់វិស័យទាំងអស់។<br>_ ធានាថា ការដាក់ស្នើគំនិតយោបល់ពីគ្រប់ក្រសួង និងភ្នាក់ងារពាក់ព័ន្ធទាំងអស់និងធានាថារាល់រចនាសម្ព័ន្ធគ្រប់គ្រងជំនួយទាំងអស់របស់កម្ពុជា គោលការណ៍ និងអាទិភាពទាំងអស់មានភាពសមស្រប និងបានបញ្ចូលក្នុងផែនការ និងបានលើកស្ទួយដល់ការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ និង<br>_ អភិវឌ្ឍ និងពិនិត្យឡើងវិញចំពោះឯកសារពង្រាង ផ្អែកលើមតិយោបល់ សំណើ និងអនុសាសន៍ទាំងឡាយដែលទទួលបានពីគ្រប់អ្នកពាក់ព័ន្ធទាំងអស់ នៅដំណាក់កាលនិមួយៗនៃការអភិវឌ្ឍផែនការរបស់ខ្លួន_ដែលរួមមានទាំងបាន |

## ក្រសួងបង្គោល និងរដ្ឋបាលពាក់ព័ន្ធផ្សេងៗ

**ប្រព័ន្ធអេកូឡូស៊ី និងជលផលតំបន់ឆ្នេរ:** ភ្នាក់ងារសំខាន់ៗដែលរួមចំណែកក្នុងការអភិវឌ្ឍ និងគ្រប់គ្រងតំបន់ឆ្នេរ រួមមាន ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួង ឧស្សាហ កម្ម រ៉ែ និងថាមពល ក្រសួងសាធារណការ និងដឹកជញ្ជូន ក្រសួងអភិវឌ្ឍន៍ជនបទ និងក្រសួងបរិស្ថាន។ ដើម្បី ដោះស្រាយបញ្ហាដែលមាននៅគ្រប់វិស័យ រដ្ឋាភិបាលបានបង្កើតគណ:កម្មាធិការជាតិទទួលបន្ទុកតំបន់ឆ្នេរ (NCSC)។ គណ:កម្មាធិការជាតិទទួលបន្ទុកតំបន់ឆ្នេរ ទទួលខុសត្រូវក្នុងការ បង្កើតទិសដៅរួម លើរាល់គំរោងតំបន់ឆ្នេរ និងសកម្មភាពទាំងឡាយទាក់ទងដល់ធនធានធម្មជាតិ ស្របតាម គោលនយោបាយជាតិបច្ចុប្បន្នរួមជាមួយបណ្តាក្រសួងទាំងឡាយដែលលើកឡើងខាងលើ។

- ដាក់បញ្ចូលគ្នានូវការប៉ាន់ប្រមាណផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ ការបន្សុាំទៅនឹងការប្រែប្រួលអាកាសធាតុ និងភាពងាយរងគ្រោះនៅតំបន់ទីជំរាល និងសហគមន៍ទាំងឡាយនៅភូមិភាគអាស៊ី អាគ្នេយ៍ (Philippines, Indonesia, Laos, Cambodia and Vietnam); និង
- ប៉ាន់ប្រមាណភាពងាយរងគ្រោះកំរិតតំបន់ ពីការប្រែប្រួលនៃធនធានទឹក និងព្រឹត្តិការណ៏ជលសាស្រ្តអាក្រក់ៗ បណ្តាលមកពីការប្រែ ប្រួលអាកាសធាតុ (Cambodia, Vietnam, Laos and Thailand) (AIACC, 2007).

### កម្មវិធីអភិវឌ្ឍន៏សហប្រជាជាតិ

ចំពោះការបន្សុាំទៅនឹងការប្រែប្រួលអាកាសធាតុ កម្មវិធីអភិវឌ្ឍន៏សហប្រជាជាតិមានភារកិច្ចផ្តោតសំខាន់លើ ការកសាងសមត្ថភាពអាជ្ញាធរជាតិនិងអាជ្ញាធរមូលដ្ឋាន អង្គការសង្គមស៊ីវិល និងផ្នែកឯកជន ដើម្បីលើកកំពស់នូវការបន្សុាំ និងសំរាលផលប៉ះពាល់ ពីការប្រែប្រួលអាកាសធាតុ។

### ធនាគារពិភពលោក – មូលនិធិសាកលសំរាប់កាត់បន្ថយគ្រោះមហន្តរាយ

ធនាគារពិភពលោក–មូលនិធិសាកលសំរាប់កាត់បន្ថយគ្រោះមហន្តរាយមានការចូលរួមយ៉ាងសកម្មក្នុងការផ្តល់នូវកញ្ចប់ថវិកាសំរាប់ទីប្រឹក្សាបច្ចេកទេស ដើម្បីធានាឲ្យមានការសំរបសំរួល និងអនុវត្តឲ្យកាន់តែប្រសើរនូវផែន ការយុទ្ធសាស្រ្តជាតិ–កាត់បន្ថយ គ្រោះមហន្តរាយ និងការដាក់បញ្ចូលនូវការកាត់បន្ថយគ្រោះមហន្តរាយទៅ

ក្នុងផែនការអភិវឌ្ឍន៍ជាតិ រួមទាំងការបង្កើតនូវគោលការណ៍ណែនាំសំរាប់ការដាក់បញ្ចូលនូវ ការកាត់បន្ថយគ្រោះមហន្តរាយ ទៅក្នុងការកសាងផែនការអភិវឌ្ឍន៍ថ្នាក់មូលដ្ឋាន និងការផ្តួចផ្តើមបញ្ចូល ការកាត់បន្ថយគ្រោះមហន្តរាយទៅក្នុងគោលនយោបាយ និងកម្មវិធីទាំងឡាយរបស់ក្រសួងពាក់ព័ន្ធ។

## ជំនួយអភិវឌ្ឍន៍អន្តរជាតិប្រទេសដាន៉ឺម៉ាក (DANIDA)

DANIDA កំពុងរួមវិភាគទានជាច្រើនចំពោះការអភិវឌ្ឍសង្គមប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ តាមរយៈការគាំទ្រដល់ការបន្ថយភាពងាយរងគ្រោះ និងភាពក្រីក្រនៅទីជនបទក្រីក្រ ដោយផ្តល់ជំនួយទៅដល់រាជរដ្ឋាភិបាលក្នុង អនុវិស័យចំនួន ៣ ដែលទាក់ទងទៅនឹងការគ្រប់គ្រងធនធានធម្មជាតិ និងការចិញ្ចឹមជីវិត ការគ្រប់គ្រងដីធ្លីបរិស្ថាន –វិស័យព្រៃឈើ និងជលផល។

## សហព័ន្ធអន្តរជាតិកាកបាទក្រហម និងសង្គមអឌ្ឍចន្ទក្រហមអន្តរជាតិ

តួនាទីរបស់សហព័ន្ធអន្តរជាតិកាកបាទក្រហម និងសង្គមអឌ្ឍចន្ទក្រហមអន្តរជាតិ (IFRC-RCS) ទាក់ទងនឹងការ បន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ មានជាចំបងលើការសំរបសំរួល និងសហការលើការងារខាងក្រោម:

- កសាងសមត្ថភាព ជាពិសេសដល់មន្ត្រីរាជការនៅថ្នាក់ខេត្ត ស្រុក ឃុំ និងថ្នាក់ ភូមិ បុគ្គលិកអង្គការអន្តរ ជាតិ និងអង្គការមិនមែនរដ្ឋាភិបាល។
- ផ្តល់ជំនួយសង្គ្រោះបន្ទាន់_ការគៀងគរធនធាន និងចែកចាយសំភារៈសង្គ្រោះដល់អ្នករងគ្រោះដោយធ្វើ ការងារជាមួយបណ្តាក្រសួង អាជ្ញាធរ សហព័ន្ធអន្តរជាតិកាកបាទក្រហម ក្រុមការងារគ្រប់គ្រងគ្រោះ មហន្តរាយសហប្រជាជាតិ ការិយាល័យទទួលបន្ទុកសំរបសំរួលកិច្ចការមនុស្សធម៌ (OCHA) និងអង្គការ អន្តរជាតិ និងអង្គការមិនមែនរដ្ឋាភិបាលខ្លះ និង
- កសាងសមត្ថភាពអំពីការគ្រប់គ្រងគ្រោះមហន្តរាយថ្នាក់មូលដ្ឋាន

## ភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិប្រទេសស៊ុយអែដ (SIDA)

កិច្ចសហការរបស់ (SIDA) ផ្តោតសំខាន់លើការគាំទ្រការធ្វើកំណែទម្រង់វិមជ្ឈការ និងប្រជាធិបតេយ្យនីយកម្ម និងសិទ្ធិមនុស្ស តាមការផ្តល់នូវការគាំទ្រដល់ការ អភិវឌ្ឍសង្គមស៊ីវិល និងការអប់រំ។ ការគាំទ្រកម្មវិធីបរិស្ថាន និងកម្មវិធីទាក់ទង នឹងអាកាសធាតុជាតិ ផ្តោតសំខាន់ និងមានការផ្សព្វផ្សាប់ទៅនឹងវិធានការទាំងឡាយថ្នាក់តំបន់

ដើម្បីធ្វើឲ្យគោលគំនិតទាំងឡាយអាចសំរេចជោគជ័យទាំងគោល គំនិតថ្នាក់តំបន់ និងទ្វេភាគី។ អ្វីដែលគួរឲ្យកត់ សំគាល់គឺថា តាមរយៈការគាំទ្រដល់ អភិបាលកិច្ចបែប ប្រជាធិបតេយ្យ (SIDA) បានផ្តល់ជំនួយដោយផ្ទាល់ដើម្បីបង្កើត និងពង្រឹងស្ថាប័ន និងប្រព័ន្ធដែលសំរួលឲ្យមាននូវសមមាត្រមួយចំណែកធំនៃការបែងចែកថវិកាជាតិ ដល់ថ្នាក់មូលដ្ឋាន និងការប្រើប្រាស់ថវិកាទាំងនោះសំរាប់ការអភិវឌ្ឍនៅសហគមន៍ មូលដ្ឋាន ដូចជា លើប្រសិទ្ធិភាពវិស័យ កសិកម្ម ការប្រើប្រាស់ដីធ្លី និងការបន្សុាំទៅ នឹងការប្រែប្រួលអាកាសធាតុ (Sida, 2008).

(SIDA)ក៏បានផ្តល់ជំនួយដល់គំរោងសាកល្បងរួមគ្នាមួយអំពីការប្រែប្រួលអាកាសធាតុ (JCCP) ដែលមានទិសដៅជួយដល់អង្គការមិនមែនរដ្ឋាភិបាល ដាក់បញ្ចូល គំរោង បន្សុាំទៅនឹងការប្រែប្រួលអាកាសធាតុ។ វាជាកិច្ចខិតខំប្រឹងប្រែងកសាងសមត្ថភាពដ៏ ធំធេងដែលឥឡូវកំពុងចេញដំណើរឆ្ពោះទៅបង្កើតនូវការផ្តួចផ្តើមគំនិតស្រាវជ្រាវធ្វើ សកម្មភាពអំពីការប្រែប្រួលអាកាសធាតុថ្នាក់មូលដ្ឋានចំនួន ១០ នៅកម្ពុជា។

## ផែនការសកម្មភាពយុទ្ធសាស្រ្តគាំទ្រដល់ការបន្សុាំទៅនឹងការប្រែប្រួលអាកាសធាតុ ផែនការយុទ្ធសាស្រ្តសកម្មភាពជាតិ ២០០៨_២០១៣ សំរាប់ការកាត់បន្ថយគ្រោះ មហន្តរាយ **(SNAP-DRR)**

ប្រទេសកម្ពុជាបានដាក់ឲ្យអនុវត្តនូវ ផែនការយុទ្ធសាស្រ្តសកម្មភាពជាតិ ២០០៨_ ២០១៣ សំរាប់កាត់បន្ថយគ្រោះមហន្តរាយ (SNAP-DRR) របស់ខ្លួននៅខែ មិនា ឆ្នាំ ២០០៩ ផែនការនេះ មានរួម បញ្ចូលនូវសមាសធាតុ នៃការកាត់បន្ថយ គ្រោះមហន្តរាយទៅក្នុងគោលនយោបាយ តាមវិស័យ និងក្នុងផែនការវិនិយោគ។ សកម្មភាព ជាអាទិភាពគឺការ ប្រើប្រាស់នូវ “វិធីសាស្រ្តម៉ាទ្រិច” មួយដែលមាន បញ្ចូលនូវសមាសធាតុកាត់បន្ថយគ្រោះមហន្តរាយទៅក្នុងការងាររបស់ក្រសួងសំ ខាន់ៗ (ដូចជា ក្រសួងរៀបចំដែនដី នគរូប នីយកម្ម និងសំណង់ ក្រសួងធនធានទឹក និងឧតុនិយម ក្រសួងកសិកម្មរុក្ខាប្រមាញ់និងនេសាទក្រសួងអភិវឌ្ឍន៍ជនបទ និងក្រសួងសុខាភិបាល)។ (Rinbo, E., 2009). មើលប្រអប់ ៣ លក្ខណៈសំខាន់ៗនៃ SNAP-DRR (Danida, 2008).

## អង្គការ GROUPE ENERGIES RENOUVELABLES, ENVIRONNEMENT ET SOLIDARITÉS (GERES) CAMBODIA

GERES Cambodia, ជាអង្គការមិនមែនរដ្ឋាភិបាលមួយដែលផ្តោតការងារជាចំបងលើការអភិវឌ្ឍ និងការប្រែ ប្រួលអាកាសធាតុ ជាអង្គការមិនមែនរដ្ឋាភិបាលមិនរកកំរៃរបស់ប្រទេសបារាំង បង្កើតឡើងនៅឆ្នាំ ១៩៧៦ ក្រោយព្រឹត្តិការណ៍កលិយុគប្រេងលើកដំបូង។ សព្វថ្ងៃនេះអង្គការ GERES កម្ពុជា មានការជាប់ទាក់ទីនជាពិសេសលើការអនុវត្តនូវដំណោះស្រាយផ្នែកវិស្វកម្មសំរាប់ការអភិវឌ្ឍ និងផ្តល់នូវអ្នកជំនាញឯកទេសជាក់លាក់សំរាប់ការ អភិរក្សបរិស្ថាន ការសំរាលនិងបន្សុាំទៅនឹងការប្រែប្រួលអាកាសធាតុ ការ កាត់បន្ថយការប្រើប្រាស់ថាមពល និងការលើកស្ទួយការចិញ្ចឹម ជីវិតរបស់ជនក្រីក្រ។

## អង្គការ PLAN កម្ពុជា

អង្គការ PLAN កម្ពុជាកំពុងអនុវត្តគំរោង “ការកាត់បន្ថយភាពក្រីក្រដែលមាន បញ្ឆាក់ពីទំនោរបរិស្ថានរាំងស្ងួត (PROVIDE)” ដែលជួយដល់អ្នកភូមិ ដើម្បីបង្កើននូវ ផលិតផលស្រូវរបស់គេនៅតំបន់ដែលមានទំនោរចំពោះភាពរាំងស្ងួត។ ពួកគេធ្វើ ការសាកពិសោធន៍លើពូជស្រូវដែលមានភាពធន់ទៅនឹងអាកាសធាតុស្ងួតហួតហែងដោយធ្វើជាដៃគូជាមួយវិទ្យាស្ថានស្រាវជ្រាវដំណាំស្រូវអន្តរជាតិ និងវិទ្យាស្ថានស្រាវជ្រាវកសិកម្ម និងអភិវឌ្ឍកម្ពុជា។

## អង្គការអុកស្វាមសហរដ្ឋអាមេរិក

គំរោងទាក់ទងនឹងការប្រែប្រួលអាកាសធាតុរបស់ អង្គការ អុកស្វាមសហរដ្ឋអាមេរិកផ្តោតសំខាន់លើការលើក កំពស់ការយល់ដឹងដល់សាធារណៈជនអំពីការប្រែប្រួលអាកាសធាតុ ការព្យាករធាតុអាកាសទាក់ទងនឹងវិស័យ កសិកម្ម ដើម្បីផ្តល់ដល់កសិករនូវព័ត៌មានអាកាសធាតុងាយប្រើប្រាស់ និងទាន់ពេលវេលា និងការផ្តល់នូវវេទិកាសំរាប់កិច្ចសន្ទនា និងការចងបណ្តាញ ឧទាហរណ៍ បណ្តាញថ្នាក់ជាតិស្តីពីការប្រែប្រួលអាកាសធាតុ។

### កម្មវិធីសកម្មភាពជាតិដើម្បីបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ

កម្មវិធីសកម្មភាពជាតិ ដើម្បីបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ (NAPA) សំរាប់ប្រទេសកម្ពុជា មានមូលដ្ឋាន លើសេចក្តីសំរេចចិត្តលេខ ២៨ ក្នុងស ន្និសីទបណ្តាភាគី (CoP) លើកទី ៧ នៃក្របខ័ណ្ឌអនុសញ្ញាសហប្រជាជាតិស្តីពី ការប្រែប្រួលអាកាសធាតុ។ ការបង្កើតនូវកម្មវិធីសកម្មភាពជាតិ ដើម្បីបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ (NAPA) ធ្វើឡើងតាមដំណើរការមានការចូលរួម ដែលរួមមានអ្នកទាំងឡាយណាដែលមានការប៉ះពាល់ខ្លាំងពីការ ប្រែប្រួលអាកាសធាតុ មានដូចជាប្រជាជននៅទីជនបទ និងជនក្រីក្រជាដើម។

### មើលប្រអប់ ៣ ផែនការយុទ្ធសាស្រ្តសកម្មភាពជាតិ ២០០៨_២០១៣ស្តីពីការកាត់បន្ថយគ្រោះមហន្តរាយ

- រួមចំណែកដល់ការយល់ឃើញស្របគ្នា និងចំណេះដឹងអំពីការកាត់បន្ថយគ្រោះមហន្តរាយ
- ផ្តល់នូវក្របខ័ណ្ឌទូលំទូលាយ ដែលណែនាំ និងត្រួតពិនិត្យ លើការអនុវត្តនូវគំរោងកាត់បន្ថយគ្រោះមហន្ត រាយក្នុងប្រទេស
- បង្កើតឲ្យមាននូវបរិយាកាសល្អសំរាប់ការបញ្ជ្រាបនូវការកាត់បន្ថយគ្រោះមហន្តរាយទៅក្នុងផែនការ អភិវឌ្ឍន៍ គោលនយោបាយ និងគំរោងទាំងឡាយរបស់រាជរដ្ឋាភិបាលកម្ពុជា
- ពង្រឹងការសំរបសំរួល និងកិច្ចសហការរវាងអ្នកពាក់ព័ន្ធទាំង ឡាយក្នុងការគ្រប់គ្រងគ្រោះមហន្តរាយ
- កែលំអភាពត្រឹមត្រូវនៃការបែងចែក និងប្រើប្រាស់ធនធានក្នុងការកាត់បន្ថយគ្រោះ មហន្តរាយ
- ចង្អុលទិសដល់អ្នកផ្តល់ជំនួយក្នុងការគាំទ្រដល់ការកាត់បន្ថយគ្រោះ មហន្តរាយដែលកំណត់អាទិភាពនៅ ថ្នាក់ជាតិ

Danida, 2008

### គោលបំណងសំខាន់របស់ កម្មវិធីសកម្មភាពជាតិដើម្បីបន្សាំទៅនឹងការ ប្រែប្រួលអាកាសធាតុ (NAPA) មាន:_

_យល់ដឹងអំពីលក្ខណៈចំបងៗនៃគ្រោះហានិយភ័យផ្នែកអាកាសធាតុនៅកម្ពុជា(ទឹកជំនន់ គ្រោះរាំងស្ងួត ខ្យល់ព្យុះ ការជោរនៃទឹកសមុទ្រ ការរាតត្បាតនៃទឹកសមុទ្រ និងជម្ងឺគ្រុនចាញ់)

_ យល់ដឹងនូវយន្តការដោះស្រាយចំពោះហានិយភ័យពីអាកាសធាតុ និងការប្រែប្រួលអាកាសធាតុនៅកំរិត មូលដ្ឋាន

_ លើកកំពស់ផលិតភាពកសិកម្ម តាមរយៈការពង្រីកប្រព័ន្ធធារាសាស្ត្រ និងការគ្រប់គ្រង ធនធានទឹក សំដៅ កាត់បន្ថយភាពងាយរងគ្រោះចំពោះមហន្តរាយបណ្តាលពី ធម្មជាតិ និង

_ កំណត់ និងចាត់អាទិភាពសកម្មភាពបន្សាំទៅនឹងគ្រោះហានិយភ័យពីអាកាសធាតុ និងផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ

កម្មវិធីសកម្មភាពជាតិ ដើម្បីបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ (NAPA) របស់កម្ពុជា ពិតជាបានគាំទ្រយ៉ាង ខ្លាំងក្លាចំពោះគោលបំណងអភិវឌ្ឍន៍របស់រាជរដ្ឋាភិបាល ដូចដែលមានចែងក្នុង "យុទ្ធសាស្ត្រចតុកោណសំរាប់ការ អភិវឌ្ឍន៍ វិស័យ ការងារ សមធមិ និងប្រសិទ្ធិផល" បានអនុម័តនៅខែកក្កដា ២០០៤ (RGC, ២០០៤)ក៏ដូចជា "ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០០៦_២០១០" ដែលដាក់អោយអនុវត្តនៅខែឧសភា ២០០៦។

### យុទ្ធសាស្ត្ររយៈពេលមធ្យមសំរាបវិស័យកសិកម្ម និងធនធានទឹក ២០០៦_២០១០

ផ្អែកតាមផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ ២០០៦_២០១០ ផែនការយុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ ក្របខ័ណ្ឌយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលសំរាប់កែទំរង់តាមបែបរិមជ្ឈការ និងវិសហមជ្ឈការ និងយុទ្ធសាស្ត្រដែលមានស្រាប់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងធនធានទឹក និងឧតុនិយម នោះសំណើយុទ្ធសាស្ត្ររយៈពេលមធ្យមមួយសំរាបវិស័យកសិកម្ម និងធនធានទឹក (២០០៦_២០១០) ត្រូវបានគាក់តែងឡើងរួម គ្នារវាងក្រុមអ្នកផ្តល់ជំនួយ និងសមាជិកក្រុមការ ងារបច្ចេកទេស_កសិកម្ម និងធនធានទឹក (TWG-AW). សំណើនេះត្រូវបាន អនុម័ត ដោយរដ្ឋមន្ត្រីនៃក្រសួងទាំងពីរ ពោលគឺក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួង

ប្រព័ន្ធដាំដុះដំណាំចំរុះ ហាក់ដូចជាយុទ្ធសាស្ត្របន្សុាំ ទៅនឹងការប្រែប្រួលអាកាសធាតុដែលពិសេសមួយ ដែលក្នុងនោះគេឃើញកសិករចាប់ផ្តើម ដាំដុះផ្កា និងបន្លែផ្សេងៗដូចជាការ៉ុត ប៉េងប៉ោះជាដើម ដែលផ្តល់នូវតំលៃទីផ្សារខ្ពស់ ជាងដំណាំស្រូវ ដែលជាដំណាំប្រពៃណី

Photo credit: AIT/UNEP RRCAP/ xxx

ធនធានទឹក និងឧតុនិយម នៅថ្ងៃទី ៣០ មិនា ២០០៧ (Veng Sakhon, H. E., 2007). ដើម្បីសំរេចនូវយុទ្ធសាស្ត្រ រយៈពេលមធ្យមនេះ គេបានរៀបចំរួមបញ្ចូលគ្នានូវកម្មវិធីជាចំបង់ៗចំនួន ៥ វិស័យ: ១. ការកសាងសមត្ថភាព ស្ថាប័នការគ្រប់គ្រង និងការគាំទ្រកម្មវិធីសំរាប់វិស័យកសិកម្ម និងធនធានទឹក ២. កម្មវិធីគាំទ្រដល់វិស័យសន្តិសុខ ស្បៀង ៣. កម្មវិធីកសិកម្ម និងកសិពាណិជ្ជកម្ម ៤. កម្មវិធីគ្រប់គ្រងធនធានទឹក ធារាសាស្ត្រ និងដីធ្លី និងទី ៥. កម្មវិធីគ្រប់គ្រង កសិកម្ម ធនធានទឹក និងដីធ្លី (Veng Sakhon, H. E., 2007).

## សង្ខេបនូវគោលនយោបាយ និងការរៀបចំផ្សេងៗសំដៅគាំទ្រដល់ការបន្សុាំទៅនឹងការប្រែប្រួលអាកាសធាតុ

### ការរៀបចំជាអន្តរជាតិ

- អនុសញ្ញាក្របខណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ ដែលផ្តល់សច្ចាទុម័តនៅថ្ងៃទី ១៨ ខែធ្នូ ឆ្នាំ ១៩៩៥ និងចូលជាធរមានបញ្ញត្តិនៅខែមិនា ១៩៩៦
- ពិធីសារក្រុងក្យូតូ ដែលផ្តល់សច្ចាទុម័តនៅថ្ងៃទី ៤ កក្កដា ២០០២ នឹងចូលជាធរមានបញ្ញត្តិនៅថ្ងៃ ២២ ខែសីហា ២០០២

### ការរៀបចំផ្សេងៗ និងគោលនយោបាយថ្នាក់ជាតិ

- ព្រះរាជក្រមលេខ ០២_៩៤ ចុះថ្ងៃទី ២៤ ធ្នូ ១៩៩៦ ប្រកាសឲ្យប្រើប្រាស់ច្បាប់ស្តីពីការអភិរក្សបរិស្ថាន និងគ្រប់គ្រងធនធានធម្មជាតិ
- ព្រះរាជក្រមលេខ ០១៩៦_២១ ចុះថ្ងៃទី ២៤ មករា ១៩៩៦ ស្តីពីការបង្កើតក្រសួងបរិស្ថាន
- ព្រះរាជក្រមលេខ ១២៩៦_៣៥ ចុះថ្ងៃទី ២៤ ធ្នូ ១៩៩៦ ស្តីពីការផ្តល់សច្ចាបណ្ណលើអនុសញ្ញាក្របខ័ណ្ឌ សហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ
- អនុក្រិត្យលេខ ៥៧ ចុះថ្ងៃទី ២៥ កញ្ញា ១៩៩៧ ស្តីពី ការចាត់តាំង និងការប្រព្រឹត្តិ ទៅនៃក្រសួង បរិស្ថាន
- អនុក្រិតលេខ ៣០ ចុះឆ្នាំ ២០០២ ស្តីពីការតែងតាំង និងការប្រព្រឹត្តិទៅចនៃគណៈកម្មាធិការ ជាតិគ្រប់គ្រង គ្រោះមហន្តរាយ និង

កសិកម្ម...បណ្តាសកម្មភាពទាំងឡាយរបស់វាផ្តោតសំខាន់លើការលើកដំកើងកសិដ្ឋានចំរុះប្រចាំគ្រួសារ និងការ អភិវឌ្ឍនិងកែលំអប្រព័ន្ធស្រោចស្រពសហគមន៍

Photo credit: XXX/XXX

- រាជរដ្ឋាភិបាលកម្ពុជា: យុទ្ធសាស្រ្តចតុកោណសំរាប់ការអភិវឌ្ឍវិស័យ ការងារ សមធម៌ និងប្រសិទ្ធិភាព (RGC, 2004).

## ការឆ្លើយតបចំពោះការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ

### ការឆ្លើយតបរបស់សហគមន៍ទៅនឹងការប្រែប្រួលអាកាសធាតុ

យុទ្ធសាស្រ្តនៃការបន្សាំជាស្វ័យប្រវត្តិ: យុទ្ធសាស្រ្តបន្សាំជាទូទៅមួយដែលគេច្រើនលើកមក និយាយនៅទូទាំងប្រទេសកម្ពុជា គឺការជ្រើសរើសប្រព័ន្ធ ដាំដំណាំ និងពូជដំណាំដែលសមស្របបំផុត ឧទាហរណ៍ ការជ្រើសយកនូវការប្រើប្រាស់នូវការដាំដុះដំណាំស្រូវដែលអាចធន់ចំពោះទឹកជំនន់រយៈពេលមួយអាទិត្យឬការពន្យាររយៈពេលនៃវដ្តរបស់ដំណាំ។ ការបង្កើតនូវប្រព័ន្ធ ដាំដុះ ថ្មីៗ និងវិធីចំរុះ ហាក់ដូចជាយុទ្ធសាស្រ្តនៃការបន្សាំដែលកំពុងរីកចំរើនយ៉ាងខ្លាំង ឧទាហរណ៍ កសិករបានដាំផ្កា និងបន្លែផ្សេងៗ ដូចជា ការ៉ុត ខ្ទឹម និងប៉េងប៉ោះជាដើម ដែលដំណាំទាំងនេះអាចទទួលបានតម្លៃទីផ្សារខ្ពស់ជាងដំណាំជាប្រពៃណី របស់ប្រជាជនកម្ពុជា_ដំណាំស្រូវ ការទុកដាក់ភោគផលស្រូវប្រចាំរដូវ ហាក់ដូចជា

"ការប្រតិបត្តិដែលមានសុវត្ថិភាពរបស់សហគមន៍ វាជាមធ្យោបាយដើម្បីដោះស្រាយភាពខ្វះស្បៀងនៅពេល អនាគត។ ម្យ៉ាងវិញទៀត ដូចដែល យើងបានកត់សំគាល់នៅក្នុងការពិនិត្យមើលផ្នែកអក្សរសាស្រ្ត ថាវិធានការ ចិញ្ចឹមសត្វជាដើម ដែលអ្នកភូមិអនុវត្ត បង្កើតបាន "ជាទ្រនាប់" ប្រឆាំងការបាត់ចំណូល ដែលអាចកើតមានចំពោះផលកសិកម្ម។ ការរក្សា ទុកនូវស្មៅក្រៀម ឬចំបើង ក៏ជាយុទ្ធសាស្រ្ត ទូទៅមួយសំរាប់ការពារពីការខ្វះខាត ចំណីសត្វនៅរដូវប្រាំង។ វិធានការ ដោះស្រាយដែលគួរឲ្យកាត់សំគាល់ដទៃទៀត រួមមានការបន្ថយការប្រើ ប្រាស់ទឹកក្នុងគ្រួសារ ដូចជា ការងូតទឹកតែ ២ ដងក្នុងមួយអាទិត្យនៅរដូវរាំងស្ងួតខ្លាំង ជាដើម។ (MoE, Global Environmental Facility [GEF], and UNDP, 2005).

យុទ្ធសាស្រ្តបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុដែលមានផែនការ: ទំរង់នៃការបន្សាំនេះ ពឹងអាស្រ័យលើស្ថាប័នពីខាងក្រៅ ដូចជាស្ថាប័នរដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាលជាដើម ដើម្បីផ្តល់នូវពូជដំណាំដែល ប្រសើរជាង ផ្តល់អណ្តូងទឹក និងការបណ្តុះបណ្តាលបច្ចេកទេសកសិកម្ម។ ឧទាហរណ៍ជាក់ស្តែង ការផ្តល់អណ្តូង

ស្នប់ ដោយអង្គការសន្តិសេនា ការផ្តល់នូវពូជ ស្រូវដោយអង្គការ (PADEK), អណ្តូងស្នប់ដោយអង្គការ អុកស្វាម និង អណ្តូងស្នប់ដែលផ្តល់ដោយក្រុមហ៊ុនឯកជនខ្លះ។ កម្មវិធីមួយចំនួនទៀតដែលបានអនុវត្តដោយអង្គការមិនមែន រដ្ឋាភិបាលខ្លះដូចជាអង្គការ (PADEK), និងកម្មវិធីស្បៀងពល កម្មរបស់កាកបាទក្រហមកម្ពុជា ក្នុងការជីកស្រះ ដើម្បីផ្ទុកទឹក និងប្រឡាយធារាសស្រ្ត និងការចែកសត្វមាន់ និងទាដល់កសិករ ដើម្បីលើកស្ទួយការចិញ្ចឹម សត្វបន្ថែម (MoE, GEF, and UNDP, 2005)។

របៀបអនុវត្តការបន្សុាំទាក់ទងនឹងទឹកជំនន់រួមមាន ការសាងសង់ទំនប់ទឹកដោយអង្គការមិនមែនរដ្ឋាភិបាល និង វិធានការទុក ដាក់សត្វពាហនៈនៅតាមផ្លូវនិងទីទួលសុវត្ថិភាពជាដើម។ ការបូមទឹកនៅរដូវរាំងស្ងួត ក៏ត្រូវបាន ប្រើប្រាស់ ដើម្បីស្រោចស្រពស្រែចំការដែលស្ថិតនៅក្បែទន្លេសាប។ ទំនប់ទឹកខ្លះក៏ត្រូវបានគេសាងសង់ដើម្បី ការពារពីការរាតត្បាតនៃទឹកប្រៃនៅតំបន់ឆ្នេរផងដែរ។

អាជ្ញាធរដែនដីនៅតំបន់បឹងទន្លេសាប និងតំបន់ផ្សេងៗទៀត បានប្រើប្រាស់ឧបករណ៍គ្រប់គ្រងធនធានធម្មជាតិក្នុង ស្រុក ដូចជា ការបិទរដូវនេសាទក្នុងបឹង ដែលធានានូវការរក្សាទុកធនធានត្រីសំរាប់វាលស្រែទាំងឡាយដែល នៅជុំវិញបឹងនោះ ដោយហេតុថា មច្ឆាជាតិបានចរាចរ ចេញ និងចូលក្នុងបឹងកំឡុងពេលនៃរដូវទឹកជំនន់។ អាជ្ញាធរខ្លះទៀតក៏បានបង្កើតតំបន់ទ្រនាប់ព្រៃសហគមន៍ដែលអនុញ្ញាតិដោយរដ្ឋាភិបាលថ្នាក់ជាតិ ដើម្បីផ្តល់នូវ សន្តិសុខស្បៀងបន្ថែម និងការពារពីការហូរច្រោះដី។ កសិករក៏បានប៉ុនប៉ងផងដែរដើម្បីពង្រឹង នូវការស្រោចស្រព ដំណាំស្រូវនៅរដូវប្រាំង ដោយយការជីកអណ្តូងយកទឹកពីក្រោម ដីជម្រៅពី ៣០_៤០ ម៉ែត្រ។ យើងអាចសំគាល់ឃើញថា អ្នកភូមិអាចមានការយល់ដឹងអំពីយន្តការនៃការដោះស្រាយ និងការបន្សុាំផ្សេងៗដែលអាចមាន ដូចជាការស្តារនូវរចនាសម្ព័ន្ធសំរាប់រក្សាទុកទឹក និងប្រព័ន្ធប្រឡាយធារាសាស្រ្ត ការកសាង ទំនប់ទឹក និងប្រព័ន្ធគ្រប់គ្រងទឹក ការពង្រឹងយន្តការប្រឆាំងនឹងខ្យល់ព្យុះ ។ល។ ទោះជាយ៉ាងណាក៏ដោយ ការខ្វះខាតផ្នែកហិរញ្ញវត្ថុ បានរាំងជាទូទៅដល់ការ អនុវត្តគំរោងទាំងនេះពីសំណាក់សហគមន៍មូលដ្ឋាន។

## វិស័យសំខាន់ៗដែលបានឆ្លើយតបចំពោះការប្រែប្រួលអាកាសធាតុ

**វិស័យកសិកម្ម:** កម្មវិធីសកម្មភាពជាតិ ដើម្បីបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ បានកំណត់វិស័យកសិកម្មដែល មានប្រហែល ៣៨%នៃសកម្មភាពដែលទាក់ទងទាំងអស់របស់ខ្លួន។ ដៃគូអនុវត្តចំបងក្នុងកម្មវិធីនេះរួមមាន ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងដៃគូអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកនៅស្រុកស្រែអំបិល ខេត្ត កោះកុង។ បណ្តាសកម្មភាពទាំងអស់មាននៅជុំវិញការលើកដំកើងនូវការប្រកបមុខរបរកសិកម្មចំរុះក្នុងគ្រួសារ។ និងការបង្កើត និងការកែលំអប្រព័ន្ធធារាសាស្រ្តសហគមន៍។ ជាមួយនឹងការផ្តោតសំខាន់លើគ្រប់វិស័យ នោះ កម្មវិធីសកម្មភាពជាតិ ដើម្បីបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានរួមបញ្ចូលគ្នានូវគំរោងចំនួន ៥ ដែលមានទិសដៅលើកកំពស់ប្រាក់ចំណូលកសិករ សន្តិសុខស្បៀង និងការ ប្រកបមុខរបរចិញ្ចឹមជីវិត ក្នុងវិស័យដែលរងប៉ះពាល់ពីទឹកជំនន់ និងរាំងស្ងួត។ ភាពជាដៃគូក្នុងគំរោងនេះ មាន គំរោង ស្តារហេត្ថារចនាសម្ព័ន្ធការពារតំបន់ឆ្នេរ ដើម្បីពង្រឹងផលិតកម្មកសិកម្មនៅតំបន់ឆ្នេរ និងការកាត់បន្ថយនូវ បំណាក់ដីនៅតំបន់ឆ្នេរ។

និយាយជារួម កម្មវិធីសកម្មភាពជាតិ ដើម្បីបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ បានសំរបសំរួល សកម្មភាពទាំងឡាយទាក់ទងនឹងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ តាមរយៈកែលំអស្ថានភាពត្រងយកទឹកភ្លៀងនៅកំរិតភូមិ ប្រព័ន្ធប្រពលវប្បកម្មដំណាំស្រូវ (បវស) ដើម្បីបន្ថយភាពងាយរងគ្រោះចំពោះបំរែបំរួលសណ្ឋាន និង បរិមាណ ការកែតំរូវចំពោះការគ្រោងរៀបចំអាងស្តុកទឹក និងប្រឡាយធារាសាស្រ្ត និងការគ្រប់គ្រងនូវទិដ្ឋភាព និងស្រះទឹកធម្មជាតិ ទាំងនេះ ដើម្បីធ្វើឲ្យប្រសើរឡើងនូវការគ្រប់គ្រងការបន្ថយហា និយភ័យពីការប្រែប្រួលអា កាសធាតុ។ គំរោងបង្គោលសំរាប់សកម្មភាពទាំងនេះមានឈ្មោះថា: កសាងសមត្ថភាព ដើម្បីបញ្ចូលការធ្វើផែន ការធនធានទឹកក្នុងការអភិវឌ្ឍ កសិកម្ម (pers com., CEDAC)។ អង្គការ អុកស្វាមក៏បានអនុវត្តនូវគំនិតបន្ថែមទៀតតាមរយៈការផ្តល់ជំនួយចំពោះការបង្កើតនូវការព្យាករផ្នែកកសិកម្ម ដែលនឹង ផ្តល់ដល់កសិករនូវព័ត៌មានធាតុអា កាសងាយប្រើប្រាស់ និងទាន់ពេលវេលា ជាមួយនឹងការបង្ហាញអំពី បាតុភូតនានាដូចជា ការកើតមាននូវសត្វល្អិត ចង្រៃ និងពពួកកង្កែប ដែលបង្កផលប៉ះពាល់ដល់ការប្រព្រឹត្តិទៅនៃប្រព័ន្ធកសិកម្មរបស់គេ។ (pers com., Oxfam America)។

មជ្ឈមណ្ឌលសិក្សា និងអភិវឌ្ឍន៍ កសិកម្មកម្ពុជា(CEDAC)ជាមជ្ឈមណ្ឌលសំរាប់ការចូលរួមរបស់កម្ពុជាក្នុង ការលើកស្ទួយការច្នៃប្រឌិតក្នុងវិស័យកសិកម្ម និងការគ្រប់គ្រងធនធានធម្មជាតិ (Prolinnova) ក្នុងបណ្តាញពិភពលោក។ សកម្មភាពទាំងឡាយរបស់បណ្តាញផ្តោតសំខាន់លើការផ្លាស់ប្តូរព័ត៌មានតាម ការផ្សព្វផ្សាយរវាង កសិកម្មទៅកសិករ និងគំនិតថ្មីៗ។ សកម្មភាពសព្វថ្ងៃផ្តោតលើការសាកពិសោធន៍ អំពីរបៀប អំពីការដាំដំណាំពេញមួយរដូវ ដោយពិចារណាលើការយល់ដឹងអំពី ទំនោរខ្យល់ ទឹកភ្លៀង និងការប្រើប្រាស់ទឹក ព្រមទាំងការ កសាងនូវការយល់ដឹងរបស់សហគមន៍ទាក់ទងនឹងការប្រែប្រួលអាកាសធាតុការណែនាំប្រព័ន្ធប្រពលវប្បកម្មដំណាំស្រូវនិងការចូលរួមក្នុងបណ្តាញបន្សុំាទៅនឹងការប្រែប្រួលអាកាសធាតុ និងវេទិកាផ្សេងៗនៅថ្នាក់ជាតិ ឧទាហរណ៍ "វេទិកាថ្នាក់ជាតិស្តីពីការស្រាវជ្រាវពីកសិករ និងការផ្សព្វផ្សាយកសិករទៅកសិករ" ដែលជាវេទិកាដែលផ្សាភ្ជាប់ កសិករទៅថ្នាក់ជាតិក្នុងការស្រាវជ្រាវថ្នាក់មូលដ្ឋាន។ (CEDAC, 2008)។

អង្គការអភិវឌ្ឍន៍និងភាពជាដៃគូក្នុងសកម្មភាព (DPA)ជាអង្គការមិនមែនរដ្ឋាភិបាលថ្នាក់ជាតិមួយដោយរួមចំណែកជាមួយស្ថាប័នឯទៀតដែលបានលើកឡើងខាងលើបានជួយសហគមន៍ដោះស្រាយចំពោះផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុលើវិស័យសុខភាពនិងការចិញ្ចឹមជីវិតរបស់គេ តាមរយៈការគាំទ្រក្នុងការកែសំរួលនូវការប្រតិបត្តិផ្នែកកសិកម្មរបស់ពួកគេឲ្យស្របទៅនឹងលក្ខខណ្ឌ នៃការប្រែប្រួលអាកាសធាតុដោយការណែនាំនូវពូជស្រូវដែលមានភាពសុាំទៅនឹងការប្រែប្រួលនេះព្រមទាំងដាក់ បញ្ចូលនូវគំនិតផ្តួចផ្តើមក្នុងបរិបទនៃការបន្ថយ គ្រោះមហន្តរាយ ក្នុងគំរោងរបស់គេដាក់ស្តែងការលើកទឹកចិត្តឲ្យសហគមន៍រៀបចំបង្ការគ្រោះមហន្តរាយនិងផែនការឆ្លើយតបដើម្បីបន្ថយនូវភាពងាយរងគ្រោះរបស់ពួកគេក្នុងមហន្តរាយ កើតឡើងភ្លាមៗដូចជាការ បាត់បង់ផល ដំណាំ (Van Aalst, M. K., T Cannon, and I. Burton, 2008) ជាដើម។ *(សូមអានបន្ថែម ប្រអប់ ៥ សំរាប់ លក្ខណៈទូ ទៅនៃយុទ្ធ សាស្ត្របន្សុំាទៅនឹងការប្រែប្រួលអាកាសធាតុ ក្នុងវិស័យកសិកម្ម)*។

### ប្រអប់ ៥: លក្ខណៈទូទៅនៃសកម្មភាពបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុក្នុងវិស័យកសិកម្ម

- កែលំអការគ្រប់គ្រងដីសំរាប់ការងារកសិកម្ម និងការចិញ្ចឹមសត្វ ដើម្បីបង្កើតការផ្ទុកឧស្ម័នក្នុងដី
- ស្តារឡើងវិញនូវដីវាលភក់ និងដីដែលខ្សោះជីជាតិ
- កែលំអការដាំដំណាំស្រូវ ការចិញ្ចឹមសត្វ និងការគ្រប់គ្រងកាកសំណល់លាមកសត្វដើម្បីបន្ថយការបំភាយ ជាតិ $CH_4$ ទៅក្នុងបរិយាកាស
- ការធ្វើឲ្យប្រសើរឡើងនូវការប្រើប្រាស់ជីគីមី នីត្រូហ្សែន ដើម្បីបន្ថយការបំភាយ $N_2O$ ទៅក្នុងបរិយា កាស
- លះបង់ដំណាំសំរាប់ប្រើប្រាស់ជាថាមពល ដើម្បជំនួសការប្រើប្រាស់ថាមពលពី ហ្វក់ស៊ុល និង
- ប្រើការដាំដំណាំតាមការក្រាល រក្សានូវការព្យួរគ្របដី ការគ្របការពារដំណាំ និងជីវីវងកកើតឡើងវិញ

pers com., collective response

pers com., collective response



រហូតទល់ពេលនេះ កិច្ចសហការពហុអ្នកពាក់ព័ន្ធ បានផ្តល់លទ្ធផលក្នុងការកំណត់របៀបការពារតំរូវការរបស់មនុស្សជាតិ ដែលជាការចាំបាច់សំរាប់បន្តកិច្ចការអភិវឌ្ឍន៍ ខ្ទ.ទ. ធនធានទឹក និងការផ្គត់ផ្គង់ទឹកស្អាត សន្តិសុខស្បៀង និងសុខភាព ពេលត្រូវគំរាមកំហែងពីផលអាក្រក់បណ្តាលពីការប្រែប្រួលអាកាសធាតុ

### ធនធានទឹក:

មានការសំរបសំរួលពីកម្មវិធីសកម្មភាពជាតិដើម្បីបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ សកម្មភាពដែលទាក់ទងចំពោះការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុរួមមានការធ្វើឲ្យប្រសើរឡើង នូវវិធី និងឧបករណ៏ត្រងទុកទឹកភ្លៀង នៅថ្នាក់ភូមិ ការកែសំរួលចំពោះ គំរោងអាងផ្ទុកទឹក និងប្រឡាយធារាសាស្រ្ត និងការគ្រប់គ្រងគំរោងទាំងនោះ រួមជាមួយនឹងស្រះធម្មជាតិ។ គំរោងបង្គោលសំរាប់សកម្មភាពទាំងនេះ មាន ឈ្មោះថា: កសាងសមត្ថភាព ដើម្បីបញ្ចូលការធ្វើផែនការធនធានទឹកក្នុងការអភិវឌ្ឍកសិកម្ម ដែលផ្តល់ថវិកា ដោយកម្មវិធីអភិវឌ្ឍន៏សហប្រជាជាតi (UNDP) ។ លើសពីនេះទៀត ការធ្វើផែនការគ្រប់គ្រងគ្រោះរាំងស្ងួតការគ្រប់គ្រងគ្រោះទឹកជំនន់ និងប្រព័ន្ធប្រាប់សញ្ញាអាសន្នជាមុន បច្ចេកវិទ្យាធារាសាស្រ្ត និងការផ្គត់ផ្គង់ទឹកដែលត្រឹម ត្រូវនិងកំណែទំរង់ស្ថាប័នតាមរយ:ក្របខ័ណ្ឌគ្រប់គ្រងធនធានទឹកចំរុះ (IWRM) បានជួយដល់ការរក្សាភាពជានិរន្តរ៏នៃទឹក និងការផ្គតផ្គង់ស្បៀង ក្រោមលក្ខខណ្ឌអាកាសធាតុផ្សេងៗ។ កិច្ចខិតខំប្រឹងប្រែងទាំងនេះធ្វើឡើង ដោយមានការសំរបសំរួលតាមរយ:ក្រសួងធនធានទឹក និង ឧតុនិយម។

សំរាប់ការផ្តួចផ្តើមគំនិតជាច្រើនដែលបានលើកឡើងក្នុងការសិក្សានេះមួយ



Phot credit: AIT/UNEP RRCAP/Serena Fortuna

អង្គការមិនមែនរដ្ឋាភិបាលជាតិ
និងអង្គការសហគមន៍មួយចំនួនកំពុងធ្វើការងារយ៉ាង
សកម្មក្នុងទំរង់ជាការគ្រប់គ្រងធនធានធម្មជាតិ
និងសកម្ម ភាពប្រកបមុខរបរចិញ្ចឹមជីវិត

Photo credit: XXX/XXX

ចំនួនធំស្ថិតនៅក្នុងដំណាក់កាលនៃការកសាងសមត្ថភាពនៅឡើយ។ ខណៈពេលដែលវិស័យកសិកម្មរបស់ប្រទេសកម្ពុជា មានទំនោរងាយរងគ្រោះពីទឹកជំនន់ និងរាំងស្ងួតទើបវិធានការបន្សាំនៅមានកំរិតត្រឹមតែជាការបណ្តុះបណ្តាល "អ្នកជំនាញខាងការបន្សាំ" ក្នុងការងារផ្សព្វផ្សាយកសិកម្ម ការអនុវត្តគំរោងសាកល្បងនៅសហគមន៍មូលដ្ឋានបច្ចេកទេសត្រងទុកទឹកភ្លៀង វិធានការបន្ថយនូវការបាក់ដីនិងការអភិវឌ្ឍពន្ធចំរុះក្នុងកសិកម្មដំណាំស្រូវការផ្លាស់ប្តូរនូវគ្រោងអាងផ្ទុកទឹក និងប្រឡាយធារាសាស្រ្ត ដើម្បីការពារមហន្តរាយបណ្តាលពីការកើនឡើងនៃលំហូរទឹកកំណាចពីទីខ្ពស់ និងការរៀន សូត្រទាំងឡាយពីការចែករំលែកព័ត៌មានទៅកាន់ថ្នាក់ជាតិ និងអន្តរជាតិ។ គំរោងទាំងនេះត្រូវបានអនុវត្តដោយ កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ តាមរយៈជំនួយពីមូលនិធិបរិស្ថានពិភពលោក ក្នុងភាពជាដៃគូជាមួយអង្គការមិន មែនរដ្ឋាភិបាលកម្ពុជា (GEF, 2009)។ ឧបករណ៍សំខាន់ដែលកំពុងប្រើប្រាស់គឺសៀវភៅសំរាប់អ្នកបណ្តុះបណ្តាល និងការពង្រឹងសមត្ថភាពទាក់ទងនឹងដំណើរការនៃអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាស ធាតុ ជាពិសេសក្នុងវិស័យដែលងាយរងគ្រោះ និងការបន្សាំ។ ឧបករណ៍ទាំងនេះត្រូវបានរៀបចំបង្កើតឡើងដោយមានកិច្ចសហការជាមួយមជ្ឈមណ្ឌលអន្តរជាតិសំរាប់ កសិកម្មនៅតំបន់ត្រូពិក (CIAT) វិទ្យាស្ថានបរិស្ថាន ក្រុង ស្តុកហូម (SEI) និង វិទ្យាស្ថានសំរាប់ការបណ្តុះបណ្តាល និងស្រាវជ្រាវសហប្រជាជាតិ (UNITAR)។

> ...ទំនដែលបានលើកឡើងក្នុងដំណើរការពិគ្រោះយោបល់ក្នុងការស្រាវជ្រាវ ...ច្ចខិតខំប្រឹងប្រែងសំរបសំរួលការបន្សាំ ទៅនឹងការប្រែប្រួលអាកាសធាតុ ...ណត់អត្ថន័យនៃពាក្យ "បន្សាំ" ណាមួយក្នុងការស្រាវជ្រាវនេះ គេមិនអាច ...បង្ហាញឲ្យច្បាស់ពីសហគមន៍ចំពោះជីវិស និងធនធានដែលត្រូវការសំរាប់ ...ការបន្សាំទៅ នឹងការប្រែប្រួលអាកាសធាតុឡើយ។

ការកសាងសមត្ថភាពក៏បានធ្វើឡើងផងដែរ អំពីប្រព័ន្ធព័ត៌មាន និងការសំរបសំរួលដែលកំពុងធ្វើឡើងដោយ នាយកដ្ឋានឧតុនិយម។ កម្មវិធី និងគំរោង សំខាន់ៗដែលកំពុងដំណើរការ រួមមានស្ថានីយ៍ឧតុនិយមដំណើរការ ដោយដៃចំនួន ២១ ការបង្កើតគំរូព្យាករអាកាសធាតុសំរាប់តំបន់ឆ្នេរ និងការបង្កើតនូវផលិតផលព្យាករអាកាសធាតុជាលេខនៅកម្ពុជា។ តាមកិច្ចសហការជាមួយវិទ្យាស្ថានស្រាវជ្រាវធនធានទឹកនៃប្រទេសម៉ាឡេស៊ី មានការ កសាងសមត្ថភាពអំពីការប្រមូលទិន្នន័យ និងការអង្កេតអំពីធាតុអាកាស និងអាកាសធាតុ។ កិច្ចសហការ ក៏មាន ភាពសកម្មផងដែរលើការបង្កើតនូវគំរូបន្សាំសាកល្បងក្នុងកំរិតមួយ ដែលរួមបញ្ចូលនូវដំណើរការអភិវឌ្ឍន៍

នៅមូលដ្ឋាន និងការប៉ាន់ប្រមាណរួមគ្នាចំពោះផលប៉ះពាល់បណ្ដាលពីការប្រែប្រួលអាកាសធាតុ ទៅលើធនធានទឹកនៅ ដែនដីសណ្ដទន្លេមេគង្គ និងទន្លេសាប (MoWRAM, 2008)។

ការគ្រប់គ្រងគ្រោះមហន្តរាយ: ការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ ជាការងារយ៉ាងសកម្មនៅកម្ពុជា ដោយពិចារណាលើការគ្រប់គ្រងគ្រោះមហន្តរាយ ធ្វើក្នុងចំណោមវិស័យទាំងអស់ កាន់តែសំខាន់ជាងនេះទៀត វារិតតែសកម្មទៀតក្នុងការបញ្ចូលទៅក្នុងផ្នែកនៃកិច្ចសហការនានា។ ដែលលើកឡើងមកនេះ គេអាចធ្វើការកត់សំគាល់ទៅលើបញ្ជីនៃអ្នកផ្ដល់ជំនួយ និងការចូលរួមពីស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ និងមូលនិធិបរិស្ថានពិភពលោក ខាងក្រោមនេះ:

- ភ្នាក់ងារផ្ដល់ជំនួយអភិវឌ្ឍន៍អន្តរជាតិអូស្ត្រាលី AusAID[3]ការកាត់បន្ថយភាពងាយរងគ្រោះរបស់ជនក្រីក្រពីគ្រោះមហន្តរាយធម្មជាតិ ជាប្រធានបទមួយក្នុងប្រធានបទទាំង ៣ ដែលប្រទេស អូស្ត្រាលី បានផ្ដល់កិច្ចសហការអភិវឌ្ឍន៍ជាមួយកម្ពុជា
- នាយកដ្ឋានជំនួយ មនុស្សធម៌សំរាប់ត្រៀមបង្ការ គ្រោះមហន្តរាយសហគមន៍អ៊ឺរ៉ុប DIPECHO: បន្តផ្ដល់ជំនួយលើគំរោង ដូចជា គំរោងលើកកំពស់ និងពង្រឹងការបន្សាំទៅនឹងគ្រោះមហន្តរាយ នៅកម្ពុជា ពីសហគមន៍ទៅក្នុងវិស័យអប់រំ។ ឪភដែះឿ មានដៃគូសហការជាមួយអង្គការមិនមែនរដ្ឋាភិបាលជាច្រើន ដូចជា អង្គការ Action Aids, LWF-Cambodia, កាក បាទក្រហមកម្ពុជា កាកបាទក្រហមដែនណឺម៉ាកអង្គការហូឡង់សង្គ្រោះផែន ដីជាដើម។
- ធនាគារអភិវឌ្ឍន៍អាស៊ី_អនុវត្តយុទ្ធសាស្ត្រកាត់បន្ថយគ្រោះមហន្តរាយដោយមានការចូលរួមពី សហគមន៍ (២០០៧_២០១២) ជាមួយ ADPC និងជាដៃគូជាមួយក្រសួងធនធានទឹក និងឧតុ និយម។ កិច្ចខិតខំប្រឹងប្រែងចំបងគឺការលើកដំកើងសកម្មភាពនៅមូលដ្ឋាន និងការអភិវឌ្ឍ ផែនការយុទ្ធសាស្ត្រកាត់បន្ថយគ្រោះមហន្តរាយដោយមានការចូលរួមពីសហគមន៍។
- កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ: បានអនុវត្តនូវការផ្ដល់ជំនួយដល់គណ:កម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ និងគណ:កម្មាធិការទន្លេមេគង្គ

និងការជួយបង្កើត និងអនុវត្តប្រព័ន្ធព្យាករ ធាតុអាកាស ផែនទីទឹកជំនន់ និងគំរោងផ្តល់សញ្ញាអាសន្នជាមុន។

- ធនាគារពិភពលោក: តាមរយៈមូលនិធិពិភពលោកសំរាប់កាត់បន្ថយគ្រោះមហន្តរាយ បានរៀប ចំនូវកញ្ចប់ថវិកាសំរាប់ទីប្រឹក្សាបច្ចេកទេសមួយ ដើម្បី ធានាឲ្យមានការសំរបសំរួល និងអនុវត្ត ឲ្យបានប្រសើរនូវផែនការយុទ្ធសាស្រ្តសកម្មភាពជាតិ កាត់បន្ថយគ្រោះមហន្តរាយ និងការដាក់ បញ្ចូលនូវការកាត់បន្ថយគ្រោះមហន្តរាយទៅក្នុងផែនការអភិវឌ្ឍន៍ជាតិ ការគាំទ្រដល់ការ អនុវត្ត យុទ្ធសាស្រ្តជាតិកាត់បន្ថយគ្រោះមហន្តរាយដោយមានការចូលរួមពី សហគមន៍ និង បង្កើតគោលការណ៍ណែនាំសំរាប់ការដាក់បញ្ចូលការកាត់បន្ថយគ្រោះមហន្តរាយក្នុងផែនការ អភិវឌ្ឍន៍ ថ្នាក់មូលដ្ឋាន ការផ្តួចផ្តើមគំនិតដើម្បីបញ្ជ្រាបការកាត់បន្ថយគ្រោះមហន្តរាយ ទៅក្នុងគោលនយោបាយ និងកម្មវិធីរបស់ក្រសួងទាំងពីរ ការគាំទ្រការបង្កើតនូវផែនការកាត់បន្ថយ ពហុមហន្តរាយនៅ ថ្នាក់ខេត្ត និងការអនុវត្តជាដៃគូជាមួយអាជ្ញាធរថ្នាក់ខេត្តយ៉ាងហោច ណាស់ពីរខេត្តថ្មីនៅឆ្នាំ ២០០៩ ព្រមទាំបានពង្រឹងការគ្រប់គ្រងគណៈកម្មាធិការជាតិគ្រប់គ្រង គ្រោះមហន្តរាយ។ កាលពីអតីតកាល អ្វីដែលគួរកត់សំគាល់បន្ថែមគឺ ធនាគារពិភពលោកបាន អនុវត្តក្រោមគំរោងស្តារឡើងវិញជាបន្ទាន់ពីគ្រោះមហន្តរាយទឹកជំនន់ បានជួសជុល និងស្តារ ឡើងវិញនូវហេដ្ឋារចនាសម្ព័ន្ធដែលខូចខាតពីទឹកជំនន់នៅឆ្នាំ ២០០០ និងការផ្តល់ជំនួយបច្ចេក ទេសដើម្បីជួយកសាងសមត្ថភាពដើម្បីឲ្យមានការគ្រប់គ្រង និងសំរាលគ្រោះមហន្តរាយកើតឡើងដោយសារទឹក ប្រកបដោយប្រសិទ្ធិភាព។

"មានជនក្រីក្របំផុតជាង ៤០០ លាននាក់ រស់នៅពឹងផ្អែកលើត្រីជាអាហារ នោះ ការស៊ូទ្រាំបានទៅនឹងអាកាសធាតុនៃធន ធានត្រី និងធនធានវារិជាតិ តំរូវឲ្យមានការលើកយកមកជជែកជាចាំបាច់ក្នុងរបៀបវារៈនៃការប្រែប្រួលអា កាសធាតុ។ ម្យ៉ាងវិញទៀតវិស័យជលផល និងធនធានវារិជាតិ ដាក់ស្តែង ត្រូវគេផាត់ ចេញពីការជជែកពិភាក្សាអំពី ការប្រែ ប្រួលអាកាសធាតុ បើទោះជា វិទ្យាសាស្រ្ត បានបង្ហាញថា ការប្រែប្រួល អាកាសធាតុ ចោទជាការគំរាមយ៉ាង ធំចំពោះផលិតកម្មស្បៀងផ្អែកវារិជាតិ ដែលជនក្រីក្រ ទាំង ឡាយមានការពឹង អាស្រ័យលើក៏ដោយ"។

*World Fish Center, 2009*

- GTZ ផ្តល់ជំនួយគាំទ្រជាច្រើនដល់គណៈកម្មាធិការទន្លេមេគង្គនិងមជ្ឈមណ្ឌលបង្ការគ្រោះ មហន្តរាយ អាស៊ី (ADPC) សំរាប់ពង្រឹងការគ្រប់គ្រងគ្រាមានអាសន្នពីគ្រោះទឹកជំនន់។

- កម្មវិធីស្បៀងអាហារពិភពលោកបានផ្ដល់ជំនួយជាស្បៀងតាមរយៈកម្មវិធីស្បៀងពលកម្ម នៅក្នុងសហគមន៍ក្រីក្របំផុត ក៏ដូចជា ការបង្កើតនូវគោលការណ៍ណែនាំអំពីការប៉ាន់ប្រមាណ ការខូចខាត និងតំរូវការ (DANA)និងឧបករណ៍សំរាប់គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះ មហន្តរាយ និង
- ស្ថានការសហប្រជាជាតិផ្នែក សេដ្ឋកិច្ច និងវប្បធម៌សំរាប់តំបន់អាស៊ីនិង ប៉ាស៊ីហ្វិក UNESCAP: បានអនុវត្តក្នុងភាពជាដៃគូសំរាប់ការកាត់ បន្ថយគ្រោះ មហន្តរាយនៅភូមិភាគអាស៊ី អាគ្នេយ៍។

សំរាប់ករណីនៃកម្មវិធីរៀបចំបង្ការគ្រោះមហន្តរាយដោយមានការចូលរួមពីសហគមន៍របស់កម្ពុជាវិញ ការប៉ាន់ប្រមាណអំពីការកាត់បន្ថយគ្រោះមហន្តរាយត្រូវបានអនុវត្តដោយការសាងសង់គំរោងខ្នាតតូចៗដោយមានការចូល រួមវិភាគទានពីសហគមន៍។ គំរោងទាំងនេះ រួមមានការសាងសង់ស្ពានតូចៗដែលសំរួលដល់ការជន្លៀសប្រជាជននាគ្រាអសន្ន ការសាងសង់លូទឹកដើម្បីពន្លឿនដល់ការហូរទឹក ទំនប់ទឹកដែលជួយសំរួលដល់ការជន្លៀសចេញ ប៉ុន្តែ ក៏បានធ្វើឲ្យមានការទប់ទឹកទុកសំរាប់ស្រោចស្រពដំណាំនៅរដូវប្រាំងផងដែរ។ ឧទាហរណ៍ដែលលើកឡើងចុង ក្រោយនេះ បានរំលេចឲ្យឃើញអំពីការយកចិត្តទុកដាក់របស់សហគមន៍អំពីការចិញ្ចឹមជីវិត។ មានរបាយការណ៍ខ្លះថាសហគមន៍មូលដ្ឋាននាពេលនេះ មានភាពប្រសើរនូវសមត្ថភាពសង្គម និងការរៀបចំនិងមានទឹកចិត្តកាន់តែខ្ពស់ ដើម្បីរួមចំណែកចំពោះការបង្ការគ្រោះមហន្តរាយនៅក្នុងភូមិ និងបានបន្ថយនូវភាពពឹងផ្អែកលើជំនួយពីខាងក្រៅ។ ទឹកចិត្តទាំងនេះមានកាន់តែខ្លាំងទៀតនៅតំបន់ដែលការវិនិយោគខ្នាតតូចៗ–ពោលគឺគំរោងខ្នាតតូចៗបានបង្ហាញពីប្រសិទ្ធិភាពជាក់ស្តែងក្នុងការបន្ថយនូវផលប៉ះពាល់ពីទឹកជំនន់។ (Van Aalst, M. K., T. Cannon, and I. Burton, 2008).

ការបង្កប់នូវការប៉ាន់ប្រមាណហានិយភ័យអំពីអាកាសធាតុ ត្រូវបានគេធ្វើឡើងក្នុងទំរង់នៃសមត្ថភាពប៉ាន់ប្រមាណ ភាពងាយរងគ្រោះនៅកម្ពុជា ដែលបានបង្កប់រួចស្រេចហើយក្នុងកម្មវិធីទំហំធំៗ។ ជាឧទាហរណ៍ កាកបាទក្រហម កម្ពុជាបានរួមសហការជាមួយរាជរដ្ឋាភិបាលកម្ពុជា ដើម្បីបង្កើតផែនការជាតិគ្រប់គ្រងគ្រោះមហន្តរាយដែល

សមស្រប និងការអភិវឌ្ឍស្ថាប័ន គណៈកម្មការជាតិគ្រប់គ្រងគ្រោះមហន្តរាយ (NCDM) (Van Aalst, M. K., T. Cannon, and I. Burton, 2008.) ជាដើម។ ចំពោះការចូលរួមរបស់កម្មវិធីសកម្មភាពជាតិដើម្បីបន្សាំទៅនឹងការ ប្រែប្រួលអាកាសធាតុក្នុងវិស័យនេះ មានសកម្មភាពទាំងឡាយដែលកម្មវិធីនេះគាំទ្រ ផ្តោតសំខាន់លើ ការពង្រឹង នូវសមត្ថភាពរៀបចំបង្ការ និងឆ្លើយតបចំពោះគ្រោះមហន្តរាយរបស់សហគមន៍ ដែលបានអនុវត្តតាមរយៈកិច្ចខិតខំ ប្រឹងប្រែងរបស់គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ អង្គការអុកស្វាមចក្រភពអង់គ្លេស និងអុកស្វាម សហរដ្ឋអាមេរិក (pers com., Oxfam America)។

មានអង្គការមិនមែនរដ្ឋាភិបាលជាច្រើនរួមចំណែកក្នុងការគ្រប់គ្រងគ្រោះមហន្តរាយបានបង្កើតនូវវេទិកាស្តីពីការ បន្ថយគ្រោះមហន្តរាយ ដោយមានកិច្ចសហការពីនាយកដ្ឋានជំនួយមនុស្សធម៌សំរាប់ត្រៀមបង្ការគ្រោះមហន្តរាយសហគមន៍អ៊ឺរ៉ុប DIPECHO. ដោយមានការជួយឧបត្ថម្ភពី នាយកដ្ឋានជំនួយមនុស្សធម៌សំរាប់ត្រៀមបង្ការគ្រោះមហន្តរាយសហគមន៍អ៊ឺរ៉ុប និងមជ្ឈមណ្ឌលបង្ការគ្រោះមហន្តរាយអាស៊ី ក្រសួងអប់រំយុវជន និងកីឡាបានសាកល្បងបញ្ចូលវិធានការកាត់បន្ថយគ្រោះមហន្តរាយទៅក្នុងវិស័យអប់រំជាតិ។ ការងារទាំងនេះរួមមាន ការបង្កើត និងរៀបចំបញ្ចូលនូវការបន្ថយគ្រោះមហន្តរាយទៅក្នុងកម្មវិធីអប់រំតាមសាលារៀន។ ដៃគូរួមជាមួយការងារនេះមានគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ បានបង្កើតនូវយុទ្ធសាស្រ្តទំនាក់ទំនងអំពីគ្រោះមហន្តរាយ ជាតិដែលសំរបសំរួលដល់បណ្តាអង្គការមិនមែនរដ្ឋាភិបាលទាំងឡាយក្នុងការធ្វើយុទ្ធនាការលើកកំពស់ការយល់ដឹងជាសាធារណៈ។

*ការអប់រំ ចំណេះដឹង និងការលើកកំពស់ការយល់ដឹង:* ដូចដែលបានលើកឡើងខ្លះខាងលើ វេទិកាស្តីពីការបន្ថយ គ្រោះមហន្តរាយ ដោយមានការជួយគាំទ្រថវិកាពី DIPECHO និង ADPC ក្រសួងអប់រំ យុវជន និងកីឡាបានសាកល្បងបញ្ជ្រាបវិធានការបន្ថយគ្រោះមហន្តរាយទៅក្នុងវិស័យអប់រំ។

តាមទស្សនៈទូលំទូលាយ ការប៉ាន់ប្រមាណផលប៉ះពាល់ និងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ (AIAICC) ទទួលបានថវិកាជំនួយចំពោះការស្រាវជ្រាវ ការបណ្តុះបណ្តាល និងការគាំទ្រផ្នែកបច្ចេកទេស ដើម្បីលើកកំពស់ សមត្ថភាពផ្នែកវិទ្យាសាស្រ្តរបស់កម្ពុជាក្នុងការប៉ាន់ប្រមាណភាពងាយរងគ្រោះ និងការបន្សាំទៅនឹងការប្រែប្រួល អាកាសធាតុ និងការផ្តល់ព័ត៌មានដែលមានសារៈប្រយោជន៍សំរាប់ការធ្វើផែនការ និងអនុវត្តការបន្សាំ

ទាំងនេះ។ ការប៉ាន់ប្រមាណផលប៉ះពាល់ទៅនឹងការប្រែប្រួលអាកាសធាតុ AIACC បានអនុវត្តដោយកម្មវិធីបរិស្ថានសហប្រជាជាតិ និងអនុវត្តរួមគ្នាជាមួយមជ្ឈមណ្ឌល "ស្តាត" នៅតំបន់អាស៊ីអាគ្នេយ៍ និងបណ្ឌិតសភាវិទ្យាសាស្ត្រសំរាប់ពិភពលោកអភិវឌ្ឍន៍។ AIACC បានផ្តល់ជំនួយដល់ក្រុមសិក្សាស្រាវជ្រាវចំនួន ២៤ ក្រុម ដើម្បីស្រាវជ្រាវរយៈពេល ៣ឆ្នាំ លើផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ ការបន្សុាំ និងភាពងាយរងគ្រោះនៅបណ្តាប្រទេសក្នុងភូមិភាគ អាស៊ីអាគ្នេយ៍ ដែលប្រទេសកម្ពុជាក៏ស្ថិតនៅក្នុងការសិក្សាស្រាវជ្រាវនោះដែរ។ សកម្មភាពស្រាវជ្រាវបានបកស្រាយនូវសំណួរចោទសួរឡើងមួយចំនួនអំពីភាពងាយរងគ្រោះចំពោះការប្រែប្រួលអាកាសធាតុ និងហេតុផលមួយចំនួនទៀតដែលមានឥទ្ធិពលទៅដល់ការអភិវឌ្ឍមនុស្ស និងគោលនយោបាយនាពេលអនាគត។ (AIACC, 2006).

គំរោង និងការផ្តួចផ្តើមគំនិតទាំងឡាយដូចដែលបានបរិយាយខាងលើ ក៏ត្រូវបានចប់ សព្វគ្រប់តាមការជួយគាំទ្រ ពី សាកលវិទ្យាល័យភូមិន្ទភ្នំពេញ (RUPP) – ពោលគឺមហាវិទ្យាល័យវិទ្យាសាស្ត្របរិស្ថាន។ សាកលវិទ្យាល័យភូមិន្ទ ភ្នំពេញដ៏សំបើមចំពោះអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ និងកម្មវិធីសកម្មភាពជាតិដើម្បីបន្សុាំទៅនឹងការប្រែប្រួលអាកាសធាតុផងដែរ។ ការប្រឹងប្រែងបន្ថែមទៀត រួមមានការបញ្ជ្រាបនូវការរៀនសូត្រអំពីការប្រែប្រួលអាកាសធាតុ និងវិធានការបន្សុាំ ទៅក្នុងកម្មវិធីសិក្សារបស់ខ្លួន។ អ្វីដែលកាន់តែពិសេសជាងនេះទៀត គឺមហាវិទ្យានេះបានអនុវត្តនូវក្របខ័ណ្ឌនៃការរៀនសូត្រផ្អែកលើបញ្ហាមួយ ដែលបន្តអនុញ្ញាតិឲ្យមានឯកសាររបស់វគ្គសិក្សាថ្មីៗ និងការហាត់ការដែលផ្តោតលើរឿងរ៉ាវទាក់ទងនឹងការប្រែ ប្រួលអាកាសធាតុ (pers com., RUPP).

អង្គការអុកស្វាមសហរដ្ឋអាមេរិក កំពុងលើកស្ទួយការយល់ដឹងជាសាធារណៈអំពីការប្រែប្រួលអាកាសធាតុ ដោយ រួមសហការជាមួយនាយកដ្ឋានឧតុនិយម នាយកដ្ឋានដំណាំស្រូវនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និង នាយកដ្ឋានប្រែប្រួលអាកាសធាតុនៃក្រសួងបរិស្ថាន។ សំណើសំរាប់ឆ្នាំ ២០១០ រួមមានសកម្មភាពទាំងឡាយ ដូចតទៅ: (pers com., Oxfam America):

- ការផ្តើមធ្វើយុទ្ធនាការលើកកំពស់ការយល់ដឹងជាសាធារណៈ ដែលរួមមានការផលិតសំភារៈ សោតទស្សន៍ (រូបភាព) ដើម្បីកត់ត្រានូវផលប៉ះពាល់ បណ្តាលពីការប្រែប្រួល

ចំណេះ និងសម្ថភាពត្រូវបានធ្វើអោយប្រសើឡើង អាចជាការគាំទ្រដល់ផែនការប្រតិបត្តិការដើសមរម្យមួយ ក៏ដូចជាការជួយដល់កសិករផងដែរក្នុងការធ្វើការសម្រេចចិត្ត ថាតើត្រូវប្រមូលផលពេលណា និងដោយរបៀបណា?

Photo credit: SEI/ Rongchai Kongmuang

អាកាសធាតុនៅ ក្នុងសហគមន៏ ដែលនោះរួមទាំងចំណេះដឹងក្នុងមូលដ្ឋានដែលមានស្រាប់អំពីផលប៉ះពាល់ និងការ បន្សុាំរបស់ប្រជាជនផងដែរ។

- ពង្រឹងបន្ថែមបណ្តាញប្រែប្រួលអាកាសធាតុថ្នាក់ជាតិដោយមានគោលដៅដើម្បីចែករំលែក “ការប្រតិបត្តិល្អ” និងបង្កើតវេទិកាសំរាប់ការកសាងសមត្ថភាព និងយុទ្ធនាការលើកកំពស់ការ យល់ដឹង និង

- ពង្រឹងនូវការផ្តួចផ្តើមគំនិតលើកកំពស់ការយល់ដឹង ដោយសំរបសំរួលជាមួយនាយកដ្ឋានប្រែប្រួលអាកាសធាតុ ដើម្បីកសាងសមត្ថភាពដល់មន្ត្រីរាជការពាក់ព័ន្ធ និងធ្វើយុទ្ធនាការបង្កើន ការយល់ដឹង ដែលរួមមានទាំងការសិក្សាអំពីទស្សនៈផ្សេងៗអំពីការប្រែប្រួលអាកាសធាតុផង។

វិស័យថាមពល: ដោយឆ្លើយតបទៅនឹង “លក្ខខណ្ឌថ្មី” ជាសាកល រួមជាមួយនឹងតំរូវការសំរាប់ការកសាងសមត្ថ ភាពបន្សុាំ និងសំរាលទៅនឹងការប្រែប្រួលអាកាសធាតុ យន្តការអភិវឌ្ឍន៏ស្អាត ត្រូវបានផ្តើមប្រតិបត្តិក្នុងបរិបទនៃវិនិយោគផ្នែកសេដ្ឋកិច្ចដែលផ្សាភ្ជាប់ទៅនឹងការបន្សុាំទៅនឹងការប្រែប្រួលអាកាសធាតុ។ សំរាប់ប្រទេសកម្ពុជា គោលការណ៏យន្តការអភិវឌ្ឍន៏ស្អាត ផ្តល់នូវការណែនាំសំរាប់ប្រទេស (រដ្ឋ) និងក្រុមហ៊ុនឯកជន អំពីរបៀប វិនិយោគលើការប្រើដើមទុនទាបនៅចំពោះឱកាសវិនិយេាគទាំងឡាយក្នុងប្រទេសកម្ពុជា។ ជាការតបស្នង ត្រឡប់ វិញពួកគេ នឹងទទួលបានឥណទានសំរាប់ការបន្ថយការបំភាយឧស្ម័នពីគំរោង (ដែលគេឲ្យឈ្មោះថា “ការកាត់បន្ថយឧស្ម័នដែលបានបញ្ជាក់” ឬ CER)។ សាមុីប្រទេសដែលបានវិនិយោគជាបន្តមកអាចបន្ថែមនូវការកាត់បន្ថយឧស្ម័នដែលបានបញ្ជាក់ទាំងនេះទៅក្នុងថវិកាបន្ថយឧស្ម័នផ្ទះកញ្ចក់របស់ខ្លួន ក្រោមពិធីសារក្រុងក្យូតូ។ វិស័យថាមពលនៅកម្ពុជាត្រូវបានគេចាត់ទុកថាជាវិស័យមានសក្តានុពលធំជាង គេក្នុងយន្តការអភិវឌ្ឍន៏ស្អាត ឧទាហរណ៏ក្នុងវិស័យថាមពលកើតឡើងវិញគំរោងសន្សំសំចៃថាមពល គំរោងកែប្រែឧស្ម័នពីសំរាម (EU-ASIA, 2008) និង ការដាំដើមឈើនៅតំបន់ថ្មី និងគំរោងស្តារព្រៃឈើ និងនៅក្នុងប្រ ព័ន្ធកាត់បន្ថយឧស្ម័នកាបូនិច ដោយស្ម័គ្រចិត្ត តាមគំរោងកាត់បន្ថយការបញ្ចេញឧស្ម័ន ពីការ បំផ្លាយព្រៃឈើ និងធ្វើឲ្យរិចរិលព្រៃ+ (REDD+) (Bradley, 2009).

### ការរៀបចំ ដើម្បីវិនិយោគ លើយន្តការអភិវឌ្ឍន៍ស្អាតនៅកម្ពុជា ដែលកំពុងអនុវត្តគឺ:

_ គំរោងកសាងសមត្ថភាពសំរាប់យន្តការអភិវឌ្ឍន៍ស្អាត(CD4CDM)ដែលគាំទ្រថវិកាដោយរដ្ឋាភិបាល ហូឡង់ តាមរយៈមជ្ឈមណ្ឌលសហប្រតិបត្តិការផ្នែកថាមពល អាកាសធាតុ និងការអភិវឌ្ឍន៍ប្រកប ដោយចិរភាពនៃ កម្មវិធីបរិស្ថានសហប្រជាជាតិ។

_ ការកសាងសមត្ថភាពចំរុះសំរាប់គំរោងយន្តការអភិវឌ្ឍន៍ស្អាត (ICS-CDM) ដែលទទួលបានមូលនិធិពីរាជរដ្ឋាភិបាលជប៉ុន តាមរយៈវិទ្យាស្ថានយុទ្ធសាស្ត្របរិស្ថានពិភពលោក (IGES)និង

_"ដៃគូសន្ទនា អាស៊ី_អ៊ឺរ៉ុប ស្តីពីយន្តការអភិវឌ្ឍន៍ស្អាត" ក្រោមកម្មវិធី និយមសេដ្ឋកិច្ចអាស៊ី

ចូរធ្វើការកត់សំគាល់ថា ថាមពលកើតឡើងវិញ គំរោងសន្សំសំចៃថាមពល គំរោងថាមពលពីសំរាម ការដាំដើមឈើនៅតំបន់ថ្មី និងគំរោងស្តារព្រៃឈើឡើងវិញ ត្រូវបាន គេកំណត់ថាជាគំរោង នៃយន្តការអភិវឌ្ឍន៍ស្អាត ដែល អាចអនុវត្តបាននៅកម្ពុជា។ ប្រអប់ ៦ បញ្ជីឧទាហរណ៍ នៃការផ្តួចផ្តើមគំនិតសំខាន់របស់ការិយាល័យប្រែប្រួល អាកាសធាតុ ទាក់ទងនឹងយនត្តការអភិវឌ្ឍន៍ស្អាតនៅកម្ពុជា។

ដោះស្រាយតំរូវការនៃការបន្សុាំទៅនឹងការប្រែប្រួលអាកាសធាតុនៅថ្នាក់មូលដ្ឋានដូចជាកម្មវិធីជាតិជីវៈឧស្ម័ន របស់កម្ពុជា (BNP) ដែលអនុវត្តដោយមានជំនួយថវិកាពីអង្គការអភិវឌ្ឍន៍ហូឡង់ រួមសហការជាមួយអាជ្ញាធរជាតិ។ គោលបំណងចំបងរបស់វាគឺចែកចាយនូវប្រព័ន្ធជីវៈឧស្ម័នទំហំគ្រួសារចំនួន ១៧ ៥០០ ក្នុងរយៈពេលពីឆ្នាំ ២០០៦_២០០៩ (Danida, 2008)។ ដោយកសាងចេញពីចំណុចនេះ គំរោងសន្សំសំចៃថាមពលឱសកម្ពុជា (CFSP) ត្រូវបានរៀបចំបង្កើតឡើងដោយអង្គការមិនមែនរដ្ឋាភិបាលបារាំងមួយឈ្មោះ(GERES)ដែលមានជំនួញលក់ចង្រ្កានដែលសន្សំសំចៃថាមពលប្រហែល ២០% តិចជាងចង្រ្កានប្រើធ្យូងជាប្រពៃណី។ ការខិតខំប្រឹងប្រែងផ្សេងទៀតរបស់អង្គការ (GERES) រួមមានការសាកពិសោធន៍អំពីថាមពលកំដៅព្រះអាទិត្យ បច្ចេកទេសចំអិនជីវឥន្ធនៈ ការបង្កើតឥន្ធនៈជីវម៉ាស់ ដែលគំរោងទាំងនេះភាគច្រើនបានដាក់បញ្ចូលជាមួយការផ្តួចផ្តើមគំនិត ព្រៃសង្គមទាំង ឡាយនៅកម្ពុជា ឧទាហរណ៍ គំរោង កាត់បន្ថយការបំភាយឧស្ម័ន បណ្តាលពីការបំផ្លាយប្រៃឈើ និងការរិចរិលព្រៃ រួមជាមួយ ការចិញ្ចឹមជីវិត (REDD+)។ លទ្ធផលទាំងអស់ត្រូវបានគេកត់ត្រាទុកជាឯកសារ និងប្រើប្រាស់ជាមូលដ្ឋានសំរាប់ការបង្កើតគោលនយោបាយ។

វិស័យសុខាភិបាល: យុទ្ធសាស្ត្រផ្នែកសុខភាពទាក់ទងនឹងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ ផ្តោតសំខាន់ លើការអប់រំអំពីជម្ងឺគ្រុនចាញ់ និងយុទ្ធនាការកំចាត់ទីជម្រករបស់មូស ការផលិតជីវៈ ថ្នាំសំលាប់សត្វ ការបង្កើត ប៉ុស្តិ៍ និងមណ្ឌលសុខភាព ការផ្តល់ទឹកមានសុវត្ថិភាពនៅតំបន់មានហានិយភ័យខ្ពស់ពីជម្ងឺគ្រុនចាញ់ ការពង្រឹងកម្មវិធីអង្កេតជម្ងឺគ្រុនចាញ់នៃមន្ទីរសុខាភិបាល និងការចែកចាយមុងជ្រលក់ថ្នាំដោយអង្គការ មិនមែនរដ្ឋាភិបាល ផ្សេងៗ (Mony, K. E., and C. C. Thou (MoE), 2007)។ ក្រសួងសុខាភិបាលក៏ធ្វើសកម្មភាពផងដែរ ក្នុងការ បង្កើតផែន ការសកម្មភាព "ការប្រែប្រួលអាកាសធាតុ និងសុខភាព" ដោយមានការជួយគាំទ្រ ពីអង្គការ សុខភាពពិភពលោក។

ការបែងចែករបស់កម្មវិធីសកម្មភាពជាតិ ដើម្បីបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ នូវសកម្មភាពជាអាទិភាព នៅក្នុងវិស័យនេះ មានគំរោងកាត់បន្ថយជម្ងឺគ្រុនចាញ់ចំនួន ៦ ដូចជា "ការផ្គត់ផ្គង់ទឹកមានសុវត្ថិភាពនៅសហគមន៍ ជនបទ" ដើម្បីកាត់បន្ថយគ្រោះថ្នាក់ ពីការកើតមានជម្ងឺដែលទាក់ទងជាមួយទឹក។ អាជ្ញាធរមូលដ្ឋាន និងអង្គការ មិនមែនរដ្ឋាភិបាល ដូចជា អង្គការ ជឿណដព្រៃ មជ្ឈមណ្ឌលស្រាវជ្រាវសំរាប់ការអភិវឌ្ឍកម្ពុជា អង្គការស្បៀង និងកសិកម្ម ណីជជែ និងកម្មវិធីស្បៀងអាហារពិភពលោក បានផ្តោតការយកចិត្តទុកដាក់លើការសាងសង់មណ្ឌល ថែទាំសុខភាព និងប៉ុស្តិ៍សុខភាពនានាដើម្បីជួយដល់ក្រសួងសុខាភិបាលប្រយុទ្ធប្រឆាំងនឹងជម្ងឺគ្រុនចាញ់នៅតំបន់ មានហានិយភ័យខ្ពស់ ដែលមានភាពងាយរងគ្រោះចំពោះការប្រែប្រួលអាកាសធាតុ។ ការខិតខំប្រឹងប្រែងទាំងនេះមានការរាំងស្ទះដោយកង្វះធនធានថវិកាដើម្បីសំរេចគោលដៅបច្ចុប្បន្នដែលកំណត់។ ជាចុងក្រោយ ការផ្តល់ ទឹកសុវត្ថិភាព នៅតំបន់មានហានិយភ័យខ្ពស់នៅតែកំពុងអនុវត្តដោយក្រសួងអភិវឌ្ឍន៍ជនបទ ដោយរួមសហការ ជាមួយបណ្តាអង្គការមិនមែនរដ្ឋាភិបាលនិងអង្គការអន្តរជាតិ ដូចជាអង្គការសុខភាពពិភពលោក ផ្តោតសំខាន់លើការអង្កេតលើមូសដែកគោល កែលំអការអប់រំ និងដំណើរការព្យាបាលដល់ក្នាក់ងារគ្រុនចាញ់ភូមិ និងការផ្តល់ មុងជ្រលក់ថ្នាំ និងការបាញ់ថ្នាំកំចាត់មូសតាមផ្ទះ។

## ធនធានធម្មជាតិកើតឡើងវិញ–ប្រព័ន្ធអេកូឡូស៊ីតំបន់ ឆ្នេរ និងជលផល ព្រៃនៅតំបន់វាលទំនាប និងខ្ពង់រាប:

ផែនការយុទ្ធសាស្ត្រសកម្មភាពជាតិស្តីពីជីវសាស្ត្រចំរុះនៅកម្ពុជា ដែលប្រតិបត្តិដោយក្រសួង បរិស្ថាន និងក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានស្នើចេញនូវគោល

បំណងជាយុទ្ធសាស្ត្រ និងសកម្មភាពជាអាទិភាពមួយចំនួន ហើយដែលបញ្ហាប្រែប្រួលអាកាសធាតុក៏ត្រូវបានទទួល ស្គាល់ថាជាការគំរាមមួយយ៉ាងធ្ងន់ធ្ងរដល់ជីវសាស្ត្រចំរុះ។ ផែនការយុទ្ធសាស្ត្រសកម្មភាពជាតិស្តីពីជីវសាស្ត្រចំរុះនៅ កម្ពុជា (NBSAP) កំពុងដោះស្រាយចំពោះទំនាក់ទំនងរវាង ការអនុវត្តការងារទាំងក្នុងបរិបទអភិវឌ្ឍន៍មូលដ្ឋាន និងក្រោម អនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែ ប្រួលអាកាសធាតុ។ លើសពីនេះទៀត (NBSAP) ក៏ត្រូវបាន បញ្ចូលទៅក្នុងវិធានការបន្សាំផ្សេងៗក្រោមកម្មវិធី (NAPA) របស់កម្ពុជា ដែលមានមូលដ្ឋានលើការប៉ាន់ ប្រមាណភាពងាយរងគ្រោះ និងការបន្សាំនៅវិស័យជាអាទិ ភាព ដូចជាវិស័យកសិកម្ម និងការផ្លាស់ប្តូរនៃការប្រើប្រាស់ដីធ្លី នៅតំបន់ព្រៃ និងតំបន់ឆ្នេរ។ (Danida 2008)។

គំរោងប៉ាន់ប្រមាណសមត្ថភាពដោយខ្លួនឯងថ្នាក់ជាតិ ប្រទេសកម្ពុជា តាមរយៈក្រសួងបរិស្ថាន បានដោះស្រាយនូវ វិស័យចំនួន៣ គឺ: ជីវសាស្ត្រចំរុះ ការប្រែប្រួលអាកាសធាតុ និងការខ្សោះជីជាតិដី រួមជាមួយបញ្ហាឆ្លងវិស័យ និងការរួមបញ្ចូលចូលគ្នាក្នុងចំណោមវិស័យទាំងនោះទៀតផង។ គោលដៅដំបូងគឺ កំណត់អាទិភាពរបស់ប្រទេស និងតំរូវការសំរាប់ ការកសាងសមត្ថភាពដើម្បីដោះស្រាយតំរូវការគ្រប់គ្រងបរិស្ថានពិភពលលោក។

អ្វីដែលជាគន្លឹះទៅនឹងប្រធានបទ ការប្រែប្រួលអាកាសធាតុនោះគឺ ការដាក់បញ្ចូលនូវការអភិរក្សជីវសាស្ត្រចំរុះ និងក្តីកង្វល់ផ្សេងៗ ទៅក្នុងផែនការសកម្មភាពជាតិស្តីពីការប្រែប្រួលអាកាសធាតុ។ (CBEA, 2009)។

បើទោះជា មូលនិធិសំរាប់ប្រទេសមានការលូតលាស់តិច (LCDF) និងមូលនិធិពិសេសសំរាប់ការប្រែប្រួលអាកាស ធាតុ (SCCF) ត្រូវបានដាក់ឲ្យប្រតិបត្តិត្រឹមតែប៉ុន្មានឆ្នាំកន្លងមកក៏ដោយ ក៏ការប្រើប្រាស់មូលនិធិនេះនៅកម្ពុជា បានធ្វើឡើងដើម្បីគាំទ្រគំរោងទាំងឡាយ ដែលសំដៅបន្ថយភាពងាយរងគ្រោះ និងបង្កើនសមត្ថភាពដោះស្រាយ បញ្ហាប្រែប្រួលអាកាសធាតុ តាមរយៈការផ្តល់ថវិកាដល់គំរោង ឬការផ្តួចផ្តើមគំនិតអំពី “ការអភិវឌ្ឍភាពស៊ាំទៅ នឹងអាកាសធាតុ និងស៊ាំទៅនឹងប្រព័ន្ធអេកូឡូស៊ី”។ គំរោង LCDF-SCCF ដែលទទួលបានការអនុម័តរួមមាន ១. ការកសាងសមត្ថភាពដើម្បីដាក់ បញ្ចូលនូវផែនការធនធានទឹកក្នុងការអភិវឌ្ឍកសិកម្ម_ដែលអនុវត្តដោយកម្មវិធីអភិវឌ្ឍន៍ អង្គការសហប្រជាជាតិ និង ២. ការប៉ាន់ប្រមាណភាពងាយរងគ្រោះ និងកម្មវិធីបន្សាំទៅនឹង

ការប្រែប្រួលអា កាសធាតុនៅតំបន់ឆ្នេរប្រទេសកម្ពុជា ដោយពិចារណាលើការលើកកំពស់កំរិតជីវភាព និងប្រព័ន្ធអេកូឡូស៊ី-អនុវត្តដោយកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (GEF, 2010)។ រហូតដល់សព្វថ្ងៃនេះ កិច្ចសហការពហុអ្នកពាក់ព័ន្ធ ផ្ដល់នូវលទ្ធផល ដែលធ្វើឲ្យមានការកំណត់អំពីរបៀបការពារតំរូវការរបស់មនុស្សជាតិ ដែលសំខាន់សំរាប់បន្តនូវការអភិវឌ្ឍ ឧទាហរណ៍ ធនធានទឹក និងការផ្គត់ផ្គង់ទឹកបរិភោគ សន្តិសុខស្បៀង និងសុខភាព ពេលត្រូវគំរាម កំហែងដោយផលប៉ះពាល់អាក្រក់នៃការប្រែប្រួលអាកាសធាតុ។ ព័ត៌មានទាំងនេះត្រូវបានគេផ្ដល់ឲ្យទៅក្នុងបញ្ជីសកម្មភាពអាទិភាពរបស់ NAPA ។ ជាក់ស្ដែង គំរោងការពារតំបន់ឆ្នេរចំនួន ៣ ត្រូវបានអនុវត្តក្រោមគំរោងការ ស្ដារព្រៃកោងកាងឡើងវិញ និងការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយចិរភាពដើម្បីធ្វើឲ្យមានស្ថេរភាពច្រាំង និងបន្ថយការហូរច្រោះ ដើម្បីបន្ថយការរាតត្បាតនៃទឹកប្រៃ និងការពារតំបន់ឆ្នេរពីការខូចខាតពីខ្យល់ព្យុះ។ ស្ថាប័ន នាំមុខគេក្នុងការអនុវត្តការងារនេះ រួមមានក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងបរិស្ថាន តាមការគាំទ្រថវិកាពីមជ្ឈមណ្ឌលស្រាវជ្រាវ និងអភិវឌ្ឍអន្តរជាតិ ប្រទេសកាណាដា (IDRC) និង(DANIDA) សកម្មភាពទាំងអស់នេះ បានបង្ហាញពីការផ្លាស់ប្ដូរជំនួយថវិកាចំពោះគំរោងរបស់ NAPA ពីការគ្រប់គ្រងចំរុះនៅ តំបន់ឆ្នេរ (ICM) មកជា ការគ្រប់គ្រងធនធានជលផលផ្អែកលើប្រព័ន្ធអេកូឡូស៊ី ដែលរឹងមាំជាង។ (GEF, 2009).

សហភាពអភិរក្សពិភពលោក (IUCN) កំពុងលើកកំពស់ការទទួលស្គាល់នូវការបន្សាំផ្អែកលើប្រព័ន្ធអេកូឡូស៊ី (EbA) នៅកម្ពុជាថាជា "ធាតុមួយ នៃការឆ្លើយតបចំពោះការប្រែប្រួលអាកាសធាតុ។ មានការផ្ដួចផ្ដើមគំនិត មួយចំនួនកំពុងអនុវត្តដើម្បីការពារ និងប្រើប្រាស់ធនធានធម្មជាតិប្រកបដោយប្រសិទ្ធិផល ដែលនេះមានជាប់ទាក់ ទងទៅនឹងការបន្សាំ ឧទាហរណ៍ គំរោងអំពីធនធានជលផលសហគមន៍ប្រកបដោយចិរភាព។ គំរោងទាំង នេះធ្វើការដើម្បីស្ដារភ្លើងធម្មជាតិ និងរបបជលសាស្ត្រក្នុងតំបន់ដីសើម។ សកម្មភាពថ្នាក់សហគមន៍ជាច្រើនដែលបាន

ដាក់ឲ្យអនុវត្ត តបទៅនឹងលក្ខខណ្ឌផ្សេងៗនៃអាកាសធាតុនៅទីជនបទទៀតក្នុងដែនដីសណ្ដទន្លេមេគង្គ ជាវិធានការបន្សាំឆ្លើយតបកំរិតធំផងចំពោះការផ្លាស់ប្ដូរ ដូចជា ដំណោះស្រាយប្រកបដោយភាពច្នៃប្រឌិតចំពោះ ទឹកជំនន់ ដោយការសាងសង់ទំនប់ទឹកដែលធ្វើពីដីនៅតំបន់ទាប ដែលអាចឲ្យមានការថែរក្សាទុកធនធានត្រី (IUCN 2009) ។

តម្រូវការចាំបាច់ គឺការកសាងសម្ថភាពសម្របសម្រួល ហើយដើម្បីធ្វើទៅបានគេត្រូវផ្តល់អោយមានការសម្រប សម្រួលមួយ ហើយស្ថិតនៅក្នុងវិធីសាស្ត្រមួយដ៏សមរម្យ ប្រហែលជាអាចចេញពីកន្ទុំមួយដែលមានប្រភពពីខាង ក្នុងនៃធនធានមនុស្សប្រកបដោយជំនាញ

Photo credit: AIT/UNEP RRCAP/ Serena Fortuna

រាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋបាលព្រៃឈើ រួមសហការជាមួយអង្គការសហគមន៍ព្រៃឈើអន្តរជាតិ និងអង្គការ Terra Global ជាជិតាល បានបង្កើតគំរោងដំបូងមួយនៅកម្ពុជាឈ្មោះ "គំរោង ជៀសវាងការបំផ្លាញព្រៃឈើ"។ គំរោងនេះមានការចូលរួមពីសហគមន៍ព្រៃឈើ (CF) ចំនួន ១២ ដែលតំណាងឲ្យ ៥៥ ភូមិ ដែលការពារដែនព្រៃ ទំហំ ៦០២៤៥ ហិចតា នៅខេត្តឧត្តរមានជ័យ ភាគពាយព្យប្រទេសកម្ពុជា។ គំរោងនេះ និង ក្លាយជាការប្រើប្រាស់នូវ វិធីសាស្ត្រថ្មីសំរាប់ដាក់ស្នើ ក្រោមបទដ្ឋានបន្ថយការបំភាយឧស្ម័នស្ម័គ្រចិត្ត រួមបញ្ចូលជាមួយ គោលការណ៏ណែនាំពីសំណាក់ សម្ព័ន្ធភាពស្តីពីអាកាសធាតុ និងជីវសាស្ត្រចំរុះថ្នាក់សហគមន៏ (CCBA) ។ គំរោងត្រូវបានគេរំពឹង ថានឹងអាចស្រូបទុកឧស្ម័នកាបូនិចប្រហែល ៨.៧ លានម៉ែទ្រិកតោន ក្នុងរយៈពេល ៣០ឆ្នាំ ដែលនេះបានបង្ហាញពីរបៀបដែលប្រទេសកំពុងអភិវឌ្ឍន៏អាចទាញយកនូវចំណូលពីទីផ្សារឧស្ម័នកាបូនិច និងបាន ឆ្លើយតបជាវិជ្ជមាន ទៅនឹងការប្រែប្រួលអាកាសធាតុ ក៏ដូចជា បានប្រើប្រាស់ស្ថានភាពនៃការបន្សុាំទៅនឹងផល វិបាកនៃការប្រែប្រួលអាកាសធាតុទៀតផង។ (Pact, 2009).

នៅខែឧសភាព ឆ្នាំ ២០០៨ គំរោងបន្ថយ ការបំភាយឧស្ម័នបណ្តាលពីការបំផ្លាញ និងធ្វើឲ្យរិចរិលព្រៃឈើ (REDD) ត្រូវបានផ្តល់ ការអនុញ្ញាតិជាផ្លូវការដោយ សម្តេច ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃប្រទេសកម្ពុជាតាមរយៈស.ជ.ណលេខ៦៩៩។គោលការណណែនាំទាំងឡាយបានធានាថាចំណូលបានពីការដោះដូរកាបូនិចនឹងត្រូវបានប្រើ ១. កែលំអគុណភាពព្រៃ ២. ផ្តល់នូវផលប្រយោជន៏ជាអតិបរិមាដល់សហគមន៏មូលដ្ឋានដែលបានចូលរួមក្នុងសកម្ម ភាពគំរោង និងទី ៣. សិក្សាកំណត់ទីកន្លែងមានសក្តានុពលថ្មីសំរាប់ គំរោង (REDD) ដទៃទៀតនៅកម្ពុជា។ ក្នុងបរិបទខ្លះ កិច្ច ខិតខំប្រឹងប្រែងនេះ អាចត្រូវ គេមើលឃើញថា ជាយុទ្ធសាស្ត្រសំរាល ទោះជាយ៉ាងនេះក្តី ការការពារទុកព្រៃហុចលទ្ធផលនាំឲ្យមាននូវលំនឹងនៃដី ដែលនឹងការពារសហគមន៏ពីបញ្ហាហូរច្រោះ ផលវិបាក ធូន់ធ្ងរនៃទឹកជំនន់ និងបានការពារនូវមធ្យោបាយចិញ្ចឹមជីវិតដែលស្មើនឹងប្រាក់ចំណូលរបស់សហគមន៏ក្នុង កាលៈទេសៈលំបាក អាស្រ័យដូច នេះ គំរោងក៏ត្រូវគេចាត់ទុកថាជាការបន្សុាំមួយទៅ នឹងលក្ខខណ្ឌថ្មី។ (Bradely, 2009)

អង្គការជាតិ និងអង្គការមិនមែនរដ្ឋាភិបាលជាច្រើនមានភាពសកម្មក្នុងទំរង់ជាការគ្រប់

គ្រង់ធនធានធម្មជាតិ ដោយ មានការចូលរួមពីសហគមន៍ និងសកម្មភាពទាក់ទងនឹងការប្រកបមុខរបរ។ សំរាប់អ្នកខ្លះ ការផ្តួចផ្តើមគំនិត ទាំងនេះ អាចមិនត្រូវគេចាត់ទុកថាជា "ការបន្សុំា" ទៅនឹងការប្រែប្រួលអាកាសធាតុ។ ទោះជាយ៉ាងណាក៏ដោយ បើចង្អុលគេចង់ឲ្យចំភាគច្រើននៃអង្គការមិនមែនរដ្ឋាភិបាលទាំងនេះ ឧទាហរណ៍ ការផ្តួចផ្តើមគំនិតរបស់វិទ្យាស្ថាន គ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួមពីសហគមន៍តំរង់ទិសដៅដើម្បីអភិរក្ស និងស្តារឡើងវិញនូវប្រព័ន្ធអេកូឡូស៊ីធម្មជាតិ ជាដៃគូទៅនឹងការរីកចំរើនខាងរបរចិញ្ចឹមជីវិតពីអនុផលព្រៃឈើ ការកសាងសមត្ថភាពសំរាប់កាត់បន្ថយភាពក្រីក្រ និងការស្រាវជ្រាវអភិវឌ្ឍន៏ជនបទ ខ្សែបណ្តាញ នៃគំនិតទាំង ឡាយដែលបានលើក ឡើងក្នុងដំណើរការនៃការពិគ្រោះយោបល់សំរាប់ការសិក្សានេះបង្ហាញថា កិច្ចខិតខំប្រឹងប្រែងទាំងនេះពិតជាសំរបសំរួលដល់ការបន្សុំាទៅនឹងការប្រែប្រួលអាកាសធាតុ ឬថាវាមានទំនាក់ទំនង យ៉ាងជិត ស្និត ទៅនឹងនិយមន័យនៃ "ការបន្សុំា" ដែលកំណត់ឡើងក្នុងការសិក្សានេះ សំរាប់ភាពដែលជៀសមិនរួចពី ការបញ្ជាក់ឲ្យឃើញថា សហគមន៍ ជាមួយជីវិស និងធនធានទាំងឡាយពិតជាសំខាន់ដើម្បីសំរបសំរួលតំរូវការ ទាំងអស់ក្នុងការបន្សុំាទៅនឹងការប្រែប្រួលអាកាសធាតុ។

## ផ្នែក ៣.០ ចំណេះដឹងអំពីការប្រែប្រួលអាកាសធាតុ ការស្រាវជ្រាវ និងគំរូការសកម្មភាព

### ៣.១ ចំណេះដឹងមានស្រាប់ និងការស្រាវជ្រាវដែលអាចរកបាន

ធានបទនៃការស្រាវជ្រាវនេះ ត្រូវបានធ្វើ
្យាល័យភូមិនភ្នំពេញ ដោយផ្អែកលើការ
និងការបន្សុំាទៅនឹងការប្រែប្រួលអាកាស
ប្រួលអាកាសធាតុលើកិច្ចអភិវឌ្ឍន៍ជាតិ
ភ្នំពេញ (រួមសហការជាមួយវិទ្យាស្ថាន
ងការបន្តសិក្សាអំពីហានិយភ័យធនធានទឹក

ការស្រាវជ្រាវរបស់ NAPA ដែលកសាងលើយុទ្ធសាស្រ្តដោះស្រាយដែលមានស្រាប់ អនុវត្តដោយសហគមន៏មូលដ្ឋាន ដើម្បីពង្រឹងនូវសមត្ថភាពបន្សុំារបស់ពួកគេ។ ការងារស្រាវជ្រាវរបស់ពួកគេផ្តោតសំខាន់លើការពង្រឹង ការយល់ដឹងទាក់ទងដល់: ១.លក្ខណ:ចំបងៗនៃហានិយភ័យអាកាស ធាតុនៅកម្ពុជា (ទឹកជំនន់ រាំងស្ងួត ខ្យល់ព្យុះ ការជោរខ្ពស់នៃសមុទ្រ ការរាតត្បាត នៃទឹក ប្រៃ និងជម្ងឺគ្រុនចាញ់)ទី២ យន្តការដោះស្រាយចំពោះមុខសញ្ញា គ្រោះថ្នាក់ពីអាកាសធាតុ និង ការប្រែប្រួលអាកាសធាតុនៅថ្នាក់មូលដ្ឋាន និងទី ៣. កម្មវិធិដែលមានស្រាប់ និង ការរៀបចំស្ថាប័នសំរាប់ដោះស្រាយគ្រោះភ័យផ្អែកធាតុអាកាស និងការប្រែប្រួលអាកាសធាតុ (RGC, 2006)។ ដើម្បីសំរបសំរួលចំពោះរបៀបវារ:នៃការស្រាវជ្រាវនេះមានការសិក្សារួមគ្នាជាមួយសាកលវិទ្យាល័យភូមិន្ទ ភ្នំពេញ លើប្រធានបទស្តីពី ការព្យាករភាពងាយរងគ្រោះ និងការបន្សុំាទៅនឹងការប្រែប្រួលអាកាសធាតុ ផលប៉ះពាល់នៃការ

ប្រែប្រួលអាកាសធាតុលើការអភិវឌ្ឍជាតិ ការពិនិត្យមើលលើរបបទឹកនៅរាជធានីភ្នំពេញ (សហការជាមួយវិទ្យាស្ថានបរិស្ថានក្រុងស្តុកហូម) និងការសិក្សាជាបន្តលើភាពងាយរងគ្រោះនៃបណ្តាជនក្នុងតំបន់ជាយក្រុង។ ការប្រើប្រាស់ការស្រាវជ្រាវនេះ ផ្តោតលើការការធ្វើផែនការថ្នាក់ក្រសួង និងកិរិតសំរាប់ធ្វើ របាយការណ៍ និងសំរាប់គោលបំណងបញ្ចុះបញ្ចូលដើម្បីការគាំទ្រផ្នែកធនធាន ដែលយ៉ាងហោចណាស់ធ្វើឡើង ដោយអ្នកផ្តួចផ្តើមអនុវត្តការបន្សាំនាំមុខគេទាំងអស់។

ក្រសួងបរិស្ថាន ដោយមានជំនួយគាំទ្រពីតំណាងផ្សេងៗពីសាកលវិទ្យាល័យភូមិន្ទភ្នំពេញ និងអ្នកដទៃទៀត បានដឹកនាំផលិត "ការវិភាគគោលនយោបាយ ដោះស្រាយផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុនៅកម្ពុជា" និង "ភាពងាយរងគ្រោះ និងការបន្សាំទៅនឹងគ្រោះភ័យពីធាតុអាកាស និងការប្រែប្រួលអាកាសធាតុ: ការអង្កេត ទៅលើគ្រួសារនៅជនបទកម្ពុជា" (MoE, GEF, and UNDP, 2005)។ ការស្រាវជ្រាវចុងក្រោយនេះត្រូវបានបញ្ជាក់ថាពិតជាមានតម្លៃ ដោយសារវាបានលើកឡើងយ៉ាងច្បាស់នូវការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ នៅថ្នាក់មូលដ្ឋាន ដោយប្រើប្រាស់នូវនិន្នាការរបស់ឧតុនិយមវិទ្យា។ គេសង្ឃឹមថា ព័ត៌មានទាំងនេះនឹងអាចអនុវត្ត ដើម្បីប៉ាន់ប្រមាណអំពីអនាគតនៃផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុទៅលើផ្នែកងាយរងគ្រោះជាគន្លឹះមួយចំនួន ពិពណ៌នានូវការទាក់ទងគ្នារវាងអាកាសធាតុ បរិស្ថាន និងលក្ខខណ្ឌសង្គម-សេដ្ឋកិច្ចក្នុងផ្នែកដែលងាយរង គ្រោះ និងកំណត់នូវយុទ្ធសាស្ត្របន្សាំដែលមានអាទិភាពផ្សេងៗទៀត។ ការប្រើប្រាស់ឯកសារនេះ និងខ្លឹមសារទាំង ឡាយដែលបានលើកឡើងក្លាយជាយុទ្ធសាស្ត្រក្នុងការបង្កើតកម្មវិធីសកម្មភាពជាតិដើម្បីបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ។

*ការទទួលស្គាល់ភាពងាយរងគ្រោះនៃវិស័យកសិកម្មកម្ពុជា និយាយដោយឡែក* ដំណាំដែលពឹងផ្អែកលើទឹកភ្លៀង មានភាពងាយគ្រោះថ្នាក់ពីការផ្លាស់ប្តូរសណ្ឋានអាកាសធាតុផ្សេងៗ ទើបមជ្ឈមណ្ឌលអូស្ត្រាលីសំរាប់ការស្រាវ ជ្រាវកសិកម្មអន្តរជាតិ (ACIAR) បានអនុវត្តកម្មវិធីស្រាវជ្រាវដើម្បីជួយគាំទ្រចំពោះការបន្សាំទៅការប្រែប្រួលអាកាសធាតុនៅក្នុងកសិដ្ឋាន បង្កើនសមត្ថភាពសំរាប់ប្រើប្រាស់ឲ្យកាន់តែត្រឹមត្រូវនូវធនធានដី និងទឹកនៅខេត្ត តាកែវ កំពត និងខេត្តកំពង់ធំ (ACIAR, 2009)។ មជ្ឈមណ្ឌលសិក្សា និងអភិវឌ្ឍន៍កសិកម្មកម្ពុជា (CEDAC) ក៏បានចូលរួមផងដែរក្នុងការស្រាវជ្រាវ

ក៏វិតកសិដ្ឋានផ្តោតលើកសិដ្ឋានខ្នាតតូចៗ។ ការស្រាវជ្រាវរបស់ពួកគេនាំមកនូវការពិនិត្យអំពីសមត្ថភាពស្តុកទុកកាបូន រវាងវិធីសាស្ត្រនៃការធ្វើស្រែជាប្រពៃណីធៀបទៅនឹងវិធីសាស្ត្រប្រពលវប្បកម្មដំណាំស្រូវ (SRI)។ SRI ជាវិធីសាស្ត្រនៃការធ្វើស្រែមួយបែបដែលផ្តោតលើការប្រតិបត្តិដំណាំស្រូវសរីរាង្គ ឧទាហរណ៍ គេប្រើប្រាស់ជីកំប៉ុស្តិ អង្គាមរលួយ និងការជ្រើសរើសសំរាំងពូជ (pers com.,CEDAC)។

ការស្រាវជ្រាវបន្តទៀតអំពី ប្រពលវប្បកម្មដំណាំស្រូវក៏មានធ្វើផងដែរដោយអង្គការអុកស្វាមសហរដ្ឋអាមេរិក។ នៅឆ្នាំ ២០០១ អង្គការអុកស្វាមសហរដ្ឋអាមេរិកបានផ្តោតការយកចិត្តទុកដាក់ដោយចំពោះលើការយល់ដឹង អំពីទំនាក់ទំនងរវាង (SRI) និងសក្តានុពលរបស់វាក្នុងការសំរាល និងបន្សុាំទៅនឹងការប្រែប្រួលអាកាសធាតុ។ ការ ស្រាវជ្រាវបន្ថែមដែលត្រូវធ្វើឡើង ទោះជាមិនមានទាក់ទងដោយផ្ទាល់ជាមួយ (SRI) អំពីការចាប់ផ្តើម “ការសន្សំ សំរាប់ការផ្លាស់ប្តូរ” ជាគំរោងការស្រាវជ្រាវ មានការចូលរួមធ្វើសកម្មភាពដែលផ្សាភ្ជាប់ទៅនឹងការសន្សំខ្នាតតូច ចំពោះក្រុមងាយរងគ្រោះទៅនឹងការប្រែប្រួលអាកាសធាតុ។ (pers com., Oxfam America) ។

តាមរយៈជំនួយមូលនិធិពី គំរោងប៉ាន់ប្រមាណផលប៉ះពាល់ និងការបន្សុាំទៅនឹងការប្រែប្រួលអាកាសធាតុ (AIACC) កិច្ចសហការស្រាវជ្រាវត្រូវបានគេផ្តោតសំខាន់លើការពង្រឹងសមត្ថភាពផ្នែកវិទ្យាសាស្ត្រនៃបណ្តាប្រទេស កំពុងអភិវឌ្ឍន៏ ដើម្បីប៉ាន់ប្រមាណលើភាពងាយរងគ្រោះ និងការបន្សុាំទៅនឹងការប្រែប្រួលអាកាសធាតុ និងប្រមែប្រមូល និងចែកចាយព័ត៌មានដែលមានប្រយោជន៏សំរាប់ការធ្វើផែនការ និងធ្វើសកម្មភាពបន្សុាំ ដោយក្រសួងពាក់ព័ន្ធ និងដៃគូនៅមូលដ្ឋានរបស់គេ។ ឯកសារចំនួន ២ ខាងក្រោមនេះត្រូវបានបោះពុម្ព ទុកជាស្នាដៃនៃការ ខិតខំប្រឹង ប្រែងរបស់គេនៅកម្ពុជា:

Chinvanno, S., et al., 2006. Climate risks and rice farming in the lower Mekong River countries. AIACC Working Paper No. 40

Wehbe, M. B., et al., 2005. Social Methods for Assessing Agricultural Producers’ Vulnerability to Climate Variability and Change based on the Notion of Sustainability. AIACC Working Paper No.19

ជាផ្នែកមួយនៃអនុគំរោង ៣ របស់ខ្លួន មជ្ឈមណ្ឌលអូស្ត្រាលីសំរាប់ការស្រាវជ្រាវកសិកម្មអន្តរជាតិ បានសិក្សាស្រាវជ្រាវលើប្រធានបទខាងក្រោម:

- ការប៉ាន់ប្រមាណចំពោះឧបសគ្គជីវរូបវន្ត និងគោលនយោបាយនិងកាលានុវត្ត ភាពសំរាប់ការប្រែប្រួល អាកាសធាតុក្នុងកិរិតកសិដ្ឋាន
- ការប៉ាន់ប្រមាណលើភាពត្រឹមត្រូវនៃសេវា កសិឧតុនិយមវិទ្យា និងការផ្សព្វផ្សាយ ក្នុងបរិបទនៃការ បន្សាំទៅនឹងការប្រែប្រួលអាកាសធាតុនៅកម្ពុជា
- ការប៉ាន់ប្រមាណទំហំនៃកម្មវិធីរបស់អ្នកផ្ដល់ជំនួយផ្សេងទៀត និងសក្ដានុពល សំរាប់ការតភ្ជាប់ទៅនឹង កម្មវិធីបន្សាំទៅនឹងអាកាសធាតុអូស្ដ្រាលី
- ការប៉ាន់ប្រមាណសមត្ថភាពរបស់ឧបករណ៍គំរូអំពីប្រព័ន្ធដាំដំណាំដែលបាន ជ្រើសរើស ដើម្បីឲ្យមានការក្ដោបយកសមស្របទៅនឹងទំហំជីវរូបវន្តសង្គម សេដ្ឋកិច្ចនៃការដាំដុះផ្អែកលើស្រូវ និងការរួមគ្នានៃប្រព័ន្ធ ដំណាំ និងសត្វ ក្នុងបរិបទធាតុអាកាសផ្សេងៗ និងការប្រែប្រួលអាកាសធាតុ និង
- អភិវឌ្ឍ និងសាកល្បងវិធីសាស្ត្រកំណត់មួយ និងប្រមូលទិន្នន័យ និងរបៀប អង្កេតក្នុងក្របខ័ណ្ឌមួយដែល ប៉ាន់ប្រមាណលើផលប៉ះពាល់ពីការបន្សាំទៅនឹង ការប្រែប្រួលអាកាសធាតុ។

អ្វីដែលយើងអាចយល់បាន នោះគឺការប្រើប្រាស់ជាបឋមនៃការសិក្សានេះ អាចធ្វើឡើង ដើម្បីសំរបសំរួលរដ្ឋបាលផ្សេងៗរបស់រាជរដ្ឋាភិបាលអង្គការមិនមែនរដ្ឋាភិបាល និងសហ គមន៍ ទោះជាយ៉ាងណាក៏ដោយការប្រើប្រាស់របស់សហគមន៍កិរិតនៅត្រឹមអ្នកដែលមាន ការជាប់ទាក់ទងផ្ទាល់ជាមួយការសិក្សានេះក្នុងនាមជាអ្នកទទួល និងអ្នកសាកល្បង ប៉ុណ្ណោះ។

មានឧទាហរណ៍ជាច្រើនអំពីវិស្សការក្នុងការគ្រប់គ្រងធនធានដី និងទឹក។ មជ្ឈមណ្ឌល START នៅអាស៊ី ភាគអគ្នេយ៍ រួមជាមួយដៃគូថ្នាក់តំបន់ និងថ្នាក់ជាតិ បានគាំទ្រនូវការ ស្រាវជ្រាវផ្អែក វិទ្យាសាស្ត្រដំបូងអំពីផល ប៉ះពាល់ និងយុទ្ធសាស្ត្របន្សាំទៅនឹងការប្រែ ប្រួលអាកាសធាតុនៅកម្ពុជា។ គំរោងទាំង នេះមានការបញ្ជាក់យ៉ាង រឹងមាំលើវិស័យ កសិកម្ម ធនធានទឹក និងផលប៉ះពាល់ទាំងឡាយទាក់ទងនឹងព្រៃឈើ និងយុទ្ធសាស្ត្រ បន្សាំទៅ នឹងផលប៉ះពាល់ទាំងនោះ។ លទ្ធផលនៃការសិក្សានេះមានភាពស្រដៀងគ្នា ទៅនឹងការរកឃើញរបស់ Kirby, M., M. Mainuddin, and J ។ Eastham (2009) នៃ គំរោងប្រែប្រួលអាកាសធាតុនៅតំបន់មេគង្គ ដែលផ្ដោតសំខាន់ លើផលប៉ះពាល់ លើវិស័យកសិកម្ម និងការបន្សាំ តាមរយៈការប៉ាន់ប្រមាណអំពីផលប៉ះពាល់ ពីការប្រែ

ប្រែប្រួលអាកាសធាតុ នៅចំពោះមុខរបបជលសាស្ត្រនៅទន្លេមេគង្គ ដោយប្រើប្រាស់គំរូដំណាំ វារិជាតិ បង្កើតឡើង ដោយអង្គការស្បៀង និងកសិកម្ម។ ការស្រាវជ្រាវនេះក៏បានបញ្ចូលផងដែរនូវការស្រាវជ្រាវ ផ្សេងៗទៀត អំពី ផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុលើវិស័យកសិកម្ម ត្រី និងសន្តិសុខស្បៀង និងយុទ្ធ សាស្ត្របន្សាំដោយ Kirby, M., M. Mainuddin, and J. Eastham (2009)។

ការស្រាវជ្រាវអំពីវិស័យគ្រប់គ្រងគ្រោះមហន្តរាយ មានមូលដ្ឋានលើកម្មវិធីដែលជាប់ទាក់ទងគ្នាមួយជាមួយ កម្មវិធីសេដ្ឋកិច្ច និងបរិស្ថានសំរាប់តំបន់អាស៊ី ភាគអគ្នេយ៍ (EEPSEA)។ កម្មវិធី (EEPSEA) បានផលិតឯកសារស្រាវ ជ្រាវជាច្រើនផ្នែក ដែលបានបង្កើតនូវផែនទីសមាសធាតុមួយសំរាប់ការប៉ាន់ប្រមាណភាពងាយរងគ្រោះ: ផែនទី បង្ហាញពីហានិយភ័យទាក់ទងនឹងអាកាសធាតុ ផែនទីបង្ហាញអំពីផលប៉ះពាល់លើមនុស្ស និងអេកូឡូស៊ី និងផែនទី បង្ហាញអំពីសមត្ថភាពបន្សាំ ដែលស្របទៅនឹងក្របខ័ណ្ឌប៉ាន់ប្រមាណភាពងាយរងគ្រោះ នៃក្រុមការងារអន្តររដ្ឋា ភិបាលស្តីពីការប្រែប្រួលអាកាសធាតុ (IPCC) របស់អង្គការសហប្រជាជាតិ។

វិស័យថាមពល បើទោះជាសកម្ម ប៉ុន្តែមិនសូវជាប់លាប់ ជាមួយការស្រាវជ្រាវដែលកំពុងធ្វើក្នុងវិស័យកសិកម្ម និងធនធានទឹក។ អង្គការ (GERES) មានភាពសកម្មក្នុងការពិសោធន៏ទៅលើថាមពលប្រព័ន្ធកំដៅព្រះអាទិត្យ បច្ចេកទេសចំអិន និងជីវឥន្ទន: ការអភិវឌ្ឍជីវម៉ាស និងព្រៃសង្គម និងប្រពលវប្បកម្មកសិកម្ម ការគ្រប់គ្រងទឹក និងជីថ្លី និងការចាត់ចំណាត់ថ្នាក់នៃបច្ចេកវិជ្ជាប៉ាន់ប្រមាណទាក់ទងដល់ការព្យាករ និងភាពងាយរងគ្រោះក្នុងបរិបទនៃការប្រែប្រួលអាកាសធាតុ និងការបន្សាំទោនឹងការប្រែប្រួលនេះ។

វាពិតជាសំខាន់ដែលត្រូវធ្វើការកត់សំគាល់ថា ភោគទ្រព្យទាំងឡាយនៃការស្រាវជ្រាវកំពុងបន្តកើតមានជាហូរ ហែអំពីការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ ធ្វើឡើងដោយ "មនុស្ស"។ ការបន្សាំទាំងនោះអាចចាត់ទុក ថាជាការគាំទ្រចំពោះបច្ចេកវិជ្ជា "រូបវន្ត" នៃការបន្សាំដែលលើកឡើងមកនេះ។ ជាឧទាហរណ៏ វិទ្យាស្ថានគ្រប់គ្រង ធនធានធម្មជាតិដោយមានការចូលរួមពីសហគមន៏ (CBNRM LI) កំពុងស្ថិតក្នុងដំណើរការអនុវត្តគំរោង ទាក់ទង នឹង ជលផល និងព្រៃឈើ វិទ្យាស្ថាននេះក៏បានផ្តោតប្រធានបទស្រាវជ្រាវរបស់ខ្លួនលើរបៀបដែលសហគមន៏នេសាទ និង ការប្រតិបត្តិផ្នែកព្រៃឈើ ត្រូវបានឃ្លាំមើលដោយសហគមន៏ និងនៅកំរិតជាតិ។ គេក៏បានបញ្ជាក់បន្ថែម

សំរាប់អ្នកជាច្រើនគិតថាតួនាទីរបស់វេទិកាសំខាន់ ត្រូវពង្រឹងឥទ្ធិពលលើអ្នកធ្វើគោលនយោបាយ ដោយផ្តល់ភស្តុតាង និងបទពិសោធន៍ជាក់លាក់

Photo credit: AIT/UNEP RRCAP/ Serena Fortuna

ប្រែប្រួលអាកាសធាតុ នៅចំពោះមុខរបបជលសាស្ត្រនៅទន្លេមេគង្គ ដោយប្រើប្រាស់គំរូដំណាំ វារិជាតិ បង្កើតឡើង ដោយអង្គការស្បៀង និងកសិកម្ម។ ការស្រាវជ្រាវនេះក៏បានបញ្ចូលផងដែរនូវការស្រាវជ្រាវ ផ្សេងៗទៀត អំពី ផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុលើវិស័យកសិកម្ម ត្រី និងសន្តិសុខស្បៀង និងយុទ្ធ សាស្ត្របន្សាំដោយ Kirby, M., M. Mainuddin, and J. Eastham (2009)។

ការស្រាវជ្រាវអំពីវិស័យគ្រប់គ្រងគ្រោះមហន្តរាយ មានមូលដ្ឋានលើកម្មវិធីដែលជាប់ទាក់ទងគ្នាមួយជាមួយ កម្មវិធីសេដ្ឋកិច្ច និងបរិស្ថានសំរាប់តំបន់អាស៊ី ភាគអគ្នេយ៍ (EEPSEA)។ កម្មវិធី (EEPSEA) បានផលិតឯកសារស្រាវ ជ្រាវជាច្រើនផ្នែក ដែលបានបង្កើតនូវផែនទីសមាសធាតុមួយសំរាប់ការប៉ាន់ប្រមាណភាពងាយរងគ្រោះ: ផែនទីបង្ហាញពីហានិយភ័យ
ទាក់ទងនឹងអាកាសធាតុ ផែនទីបង្ហាញអំពីផលប៉ះពាល់លើមនុស្ស និងអេកូឡូស៊ី និងផែនទី បង្ហាញអំពីសមត្ថភាពបន្សាំ ដែលស្របទៅនឹងក្របខ័ណ្ឌប៉ាន់ប្រមាណភាពងាយរងគ្រោះ នៃក្រុមការងារអន្តររដ្ឋា ភិបាលស្តីពីការប្រែប្រួលអាកាសធាតុ (IPCC) របស់អង្គការសហប្រជាជាតិ។

វិស័យថាមពលបើទោះជាសកម្មប៉ុន្តែមិនសូវជាប់លាប់ជាមួយការស្រាវជ្រាវដែលកំពុងធ្វើក្នុងវិស័យកសិកម្ម និងធនធានទឹក។ អង្គការ (GERES) មានភាពសកម្មក្នុងការពិសោធន៍ទៅលើថាមពលប្រព័ន្ធកំដៅព្រះអាទិត្យ បច្ចេកទេសចំអិន និងជីវឥន្ទន: ការអភិវឌ្ឍ
ជីវម៉ាស និងព្រៃសង្គម និងប្រពលវប្បកម្មកសិកម្ម ការគ្រប់គ្រងទឹក និងដីធ្លី និងការចាត់ចំណាត់ថ្នាក់នៃបច្ចេកវិជ្ជាប៉ាន់ប្រមាណទាក់ទងដល់ការព្យាករ និងភាពងាយរងគ្រោះក្នុង បរិបទនៃការប្រែប្រួលអាកាសធាតុ និងការបន្សាំទៅនឹងការប្រែប្រួលនេះ។

វាពិតជាសំខាន់ដែលត្រូវធ្វើការកត់សំគាល់ថា ភោគទ្រព្យទាំងឡាយនៃការស្រាវជ្រាវកំពុងបន្តកើតមានជាហូរ ហែអំពីការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ ធ្វើឡើង

ដោយ "មនុស្ស"។ ការបន្សាំទាំងនោះអាចចាត់ទុក ថាជាការគាំទ្រចំពោះបច្ចេកវិជ្ជា "រូបវន្ត" នៃការបន្សាំដែលលើកឡើងមកនេះ។ ជាឧទាហរណ៍ វិទ្យាស្ថានគ្រប់គ្រង ធនធានធម្មជាតិដោយមានការចូលរួមពីសហគមន៍(CBNRM LI) កំពុងស្ថិតក្នុងដំណើរការអនុវត្តគំរោង ទាក់ទង នឹង ជលផល និងព្រៃឈើ វិទ្យាស្ថាននេះក៏បានផ្តោតប្រធានបទស្រាវជ្រាវរបស់ខ្លួនលើរបៀបដែលសហគមន៍នេសាទ និង ការប្រតិបត្តិផ្នែកព្រៃឈើ ត្រូវបានឃ្លាំមើលដោយសហគមន៍ និងនៅកំរិតជាតិ។ គេក៏បានបញ្ជាក់បន្ថែមផងដែរលើ របៀបលើកកំពស់ សិទ្ធិ តួនាទី ការទទួលខុសត្រូវ និងផលប្រយោជន៍របស់អ្នកនេសាទតូចតាច ជាពិសេសស្ត្រី។ សំរាប់វិទ្យាស្ថានគេគិតថាការស្រាវជ្រាវទាំងនេះពិតជាមានសារៈសំខាន់និងអាចប្រើប្រាស់ដោយ សហគមន៍គ្រប់គ្រងធនធានធម្មជាតិ ពេលគេគិតពីការពង្រីកបន្ថែម និងការទាញចេញនូវការប្រតិបត្តិល្អពោលគឺ ការប្រតិបត្តិដែលផ្តល់នូវជំរើសដល់សហគមន៍ជនបទក្រីក្រដើម្បីដោះស្រាយ និងពង្រឹងភាពស៊ាំរបស់គេទៅនឹងអាកាសធាតុ និងសេនារីយ៉ូប្រែប្រួលរបស់វា (pers com., CBNRM LI)។

> នាពេលបច្ចុប្បន្ននេះ មិនទាន់មានវេទិកា និងបណ្តាញគ្រប់គ្រាន់នៅកម្ពុជាដែលអនុវត្តការងារបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ សំរាប់បុគ្គលិកអភិវឌ្ឍន៍ប្រើប្រាស់ រឺទំនាក់ទំនងគ្នានៅឡើយ។

## ៣.២ ការពង្រឹងគំរូការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ

ការចាប់ផ្តើមជាមួយចំណេះដឹងអំពីអាកាសធាតុ នៅប្រទេសកម្ពុជា បើនិយាយជាទូទៅ និងនិយាយដោយចំពោះ នាយកដ្ឋានប្រែប្រួលអាកាសធាតុ (CCD) ត្រូវការនូវទិន្នន័យអំពីអាកាសធាតុប្រកបដោយគុណភាព ក្នុងការជួយ ជំរុញ ការបង្កើតការព្យាករ និងសេនារីយ៉ូប្រែប្រួលអាកាសធាតុដ៏ប្រសើរមួយ។ ទិន្នន័យខ្លះមានរក្សាទុកតាំងពីទសវត្សរ៍ ទី៨០ នៅនាយកដ្ឋានឧតុនិយម និងមានលើឯកសារ (ក្រដាស)។ ការធ្វើឲ្យមានទិន្នន័យ ឌីជីថល ដោយ នាយកដ្ឋានឧតុនិយមពិតជាសំខាន់សំរាប់ការទំនាក់ទំនងថ្នាក់ជាតិលើកទី២ ដែលរៀបចំ ដោយនាយកដ្ឋាន ប្រែ ប្រួលអាកាសធាតុ។ សមត្ថភាពអង្កេតរបស់នាយកដ្ឋានឧតុនិយម ក្រោយមកអាចត្រូវពង្រឹងបន្ថែម ដោយហេតុថា ការដែលមានទិន្នន័យត្រឹមត្រូវនឹងជួយឲ្យមានការព្យាករគំរោងប្រសើរផងដែរ ឧទាហរណ៍ ការធ្វើគំរូអាកាសធាតុ ការចាត់អាទិភាពគំរោង និងប្រព័ន្ធផ្តល់សញ្ញាព្រមានជាមុន។ នៅមានការបន្តក្នុងផ្នែកខ្លះនៃការធ្វើឲ្យប្រសើរឡើងជាច្រើនទៀត ដូចជាការគ្រប់គ្រងទិន្នន័យអាកាសធាតុ ការព្យាករ និងការធ្វើទំនើបកម្មស្ថានីយ៍ព្យាករ



ការយល់ដឹងរបស់ប្រទេសកម្ពុជា អំពីការបន្សុាំទៅនឹងការប្រែប្រួលអាកាសធាតុនៅក្មេងខ្ចីនៅឡើយ បើទោះជាមានការលេចឡើងនូវអ្នកជំនាញជាច្រើន ប៉ុន្តែបើនិយាយពីទូទាំងប្រទេសវិញ បើទោះអ្នកដែលបានផ្តល់ភារកិច្ចឲ្យបំពេញការងារស្រាវជ្រាវអំពីតំរូវការ និងការអនុវត្ត គំនិតបន្សុាំនេះក្តីគង់នៅមានចំណោទជាច្រើនដែលត្រូវការស្រាយបំភ្លឺ

Photo credit: AIT/UNEP RRCAP/Serena Fortuna

អាកាសធាតុ ឲ្យមានលក្ខណៈស្វ័យប្រវត្តិ (Danida, 2008)។

ការប្រឈមទៅនឹងការបន្តអភិវឌ្ឍនូវចំណេះដឹងអំពីគំរូអាកាសធាតុនោះ គឺការទាញយកប្រព័ន្ធទាំងឡាយ បញ្ចូល ទៅក្នុងទិដ្ឋភាពជលសាស្ត្រ ដើម្បីឲ្យមានភាពងាយស្រួលប្រើ និងអនុវត្តបានដោយស្ថាប័នដូចជា ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងធនធានទឹក និងឧតុនិយម។ មានការស្នើបន្ថែមទៀតផងដែរថាការប្រតិបត្តិ នៃ គំរូអាកាសធាតុ ត្រូវធ្វើក្នុងទំរង់ដែលងាយស្រួលប្រើប្រាស់ ជាក់ស្តែងគេត្រូវប្រើពេលស្ទើរតែ ២ ឆ្នាំដើម្បីរៀន អំពីការប្រើប្រាស់គំរូនេះ (pers com., RUPP)។ ក្នុងពេលជាមួយគ្នានេះ ក៏មានការស្នើឲ្យមានការធ្វើទំនើបកម្មក្នុងការនាំយកចំណេះដឹង ឬប្រព័ន្ធរបស់អ្នកប្រើប្រាស់ទៅកាន់កំរិតមូលដ្ឋាន សំរាប់សហគមន៍ ឬកសិករប្រើប្រាស់ ដើម្បី ជួយពួកគេធ្វើការកែសំរួលនៅនឹងកន្លែងលើគំនិតផ្តួចផ្តើមបង្កើនផលិតភាពស្របតាមលក្ខខណ្ឌអាកាសធាតុទូទៅមួយ (pers com., MAFF–Fisheries Administration)។

មានអនុសាសន៍ខ្លះបានស្នើសុំឲ្យ គណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ (NCCC) បង្កើតនូវ ដំណើរការនៃការប្រមូល និងវិភាគទិន្នន័យរួមបញ្ចូលគ្នារីងមាំមួយព្រមទាំងយន្តការសំរាប់ការចែករំលែកទិន្នន័យទាំងនេះ ទៅគ្រប់អ្នកពាក់ព័ន្ធទាំងអស់។ ដំណើរការនេះគួរធ្វើឲ្យស្របគ្នានឹងការបន្សុាំទៅនឹងការប្រែប្រួលអាកាសធាតុ ដែលចាត់ទុកថាជាក្របខ័ណ្ឌសំរាប់ប៉ាន់ប្រមាណ និងចាប់ផ្តើមឆ្លើយតប និងក្នុងពេលជាមួយគ្នានេះ មានភាព បទបែនគ្រប់គ្រាន់ ដើម្បីបញ្ចូលទៅក្នុងប្រព័ន្ធដំណើរការសំរាប់ការធ្វើផែនការ និងការគ្រោងថវិកាថ្នាក់វិស័យ ជាក់ ស្តែង វាជាប្រព័ន្ធចំរុះសំរាបការកសាងផែនការ (Pers com., UNDP)។

ស្តែងចេញពីដំណើរការពិគ្រោះយោបល់មានការកត់សំគាល់យ៉ាងខ្លាំងក្លាថា ការសិក្សាប្រភេទនេះ ត្រូវតែអាចយកទៅប្រើប្រាស់បាន និងទៅដល់កំរិតសហគមន៍ ដែលជាញឹកញាប់មិនធ្លាប់ទទួលបាននៅឡើយ។ បញ្ហាបន្ថែម ទៀតមានលើការធ្វើយ៉ាងណាដើម្បីឲ្យលទ្ធផលនៃការសិក្សាអាចប្រតិបត្តិបានជាទូទៅ–ពោលគឺជាឯកសារជា ភាសាមូលដ្ឋាន ដែលពុំចាំបាច់តំរូវឲ្យមានចំណេះដឹង "អានអក្សរ" ជាសមត្ថភាពដើម្បីប្រើប្រាស់វា។ គ្រប់ផ្នែក បានផ្តល់តំលៃដ៏វិសេសវិសាលលើកិច្ច

ខំប្រឹងប្រែងរបស់អ្នកស្រាវជ្រាវកសិកម្ម និងស្នើឲ្យមានការស្រាវជ្រាវ ច្រើនថែមទៀតលើគ្រប់វិស័យនៃបច្ចេកវិទ្យាអនុវត្តទាំងអស់។ ទោះជាយ៉ាងណាក៏ដោយការ វិភាគទិន្នន័យស្រាវជ្រាវ តែងតែមានការលំបាកសំរាប់អ្នកប្រើប្រាស់យល់ ឬភាពមិនស្របគ្នានៃ "ក្រមបទដ្ឋាន" ជាការ បណ្តាលឲ្យ ការចែករំលែកព័ត៌មានជាមួយអ្នកដទៃទៀត លំបាកវិភាគ ដែលប្រការនេះ នាំឲ្យសារៈប្រយោជន៍របស់ខ្លឹមសារ និងបរិបទទាំងឡាយរបស់ការស្រាវជ្រាវជួបការលំបាកយកទៅប្រើប្រាស់ ឬសូម្បី ពិបាករៀនជាក់ស្តែងមិនដឹងប្រើនៅទីណា និងប្រើប្រាស់ដោយរបៀបណា។ ចាប់ពីពេលនេះតទៅគេត្រូវធ្វើ ការកែលំអសមត្ថភាពនៃ ការស្រាវជ្រាវ ដែល ត្រូវការស្ទើរនៅគ្រប់វិស័យ (pers com., RUPP)។

**ទស្សនៈអំពីប្រព័ន្ធផលិតកម្មផលផលនិងវារីវប្បកម្ម** មានតំរូវការយ៉ាងខ្លាំងក្នុងការកសាងលើបទពិសោធន៍ ពីអតីតកាល និងបច្ចុប្បន្នកាលដើម្បបង្កើនសមត្ថភាពស៊ាំចំពោះអាកាសធាតុ។អ្វីដែលជាកង្វះខាតទាក់ទងនឹងការ ស្រាវជ្រាវនាពេលបច្ចុប្បន្ននេះ តំរូវឲ្យមានការកែលំអផលិតភាពប្រព័ន្ធទឹកភ្លាវ និងទឹក អែសតួរីន–ជាបច្ចេកវិទ្យាដែលផ្តោតការចាប់អារម្មណ៍ខ្លាំងលើការរៀនសូត្រអំពីអេកូឡូស៊ីការកាន់កាប់ និងភាពជាស្ថាប័ន។ ដើម្បីសំរេចគោលដៅនេះ គប្បីវិនិយោគលើប្រព័ន្ធផលិតកម្មបន្ទាប់បន្សំដែលត្រូវការ –ពោលគឺការធ្វើឲ្យមានតុល្យភាព រវាងការអនុវត្តការចិញ្ចឹមសត្វ និងការចិញ្ចឹមត្រីខ្នាតតូចៗ –អ្វីដែលត្រូវការគឺចំណេះដឹងអំពីរបៀបអនុវត្ត (pers com., MAFF-Fisheries Administration)។

**ផ្សព្វផ្សាយទៅនឹងកសិករ និងប្រជានេសាទដែលប្រកបរបរចិញ្ចឹមជីវិតខ្នាតតូច។** ការបន្សុំាទៅនឹងការប្រែប្រួល អាកាសធាតុ គឺពិតជាទាក់ទងនឹងការបង្កើនសន្តិសុខនៃមុខរបរចិញ្ចឹមជីវិត។ ធ្វើរបៀបនេះជាដំបូងត្រូវកំណត់ នូវសក្តានុពល និងតំរូវការសំរាប់ការចិញ្ចឹមជីវិតក្នុងដំណើរអន្តរកាលឆ្ពោះទៅកាន់ក្របខ័ណ្ឌនៃការបន្សុំាទៅនឹងការ ប្រែប្រួលអាកាសធាតុ ឧទាហរណ៍ ការបង្កើនជំនាញ និងអប់រំ ប៉ុន្តែអ្វីដែលរិតតែសំខាន់ គឺការយល់ដឹងអំពីកត្តា និងលក្ខខណ្ឌដែលបង្កឲ្យមានកង្វះភាពជាតំណាង និងមតិយោបល់របស់ផលិតករតូចតាច ក្នុងការធ្វើផែនការ បន្សុំាទៅនឹងការប្រែប្រួលអាកាសធាតុលំដាប់ជាតិ និងលំដាប់មធ្យម។

មានការស្នើទៀតថា គ្រប់ចំណេះដឹង និងប្រព័ន្ធ ឬយន្តការទាំងឡាយពិតជាត្រូវឲ្យមានការពង្រឹងបន្ថែមឲ្យសម ស្របទៅនឹងសមត្ថភាពរបស់ផលិតករតូចតាច ក្នុងវិស័យនៃការបន្សាំថ្នាក់មូលដ្ឋាន និងគំនិតផ្តើមថ្មីៗក្នុងវិស័យ កសិកម្ម និងប្រព័ន្ធផលិតកម្មជលផល ជាពិសេសក្នុងកាលៈទេសៈនៃការកើនឡើងនូវជាតិប្រៃក្នុងទឹកសាប។ អ្វីដែលត្រូវការផងដែរគឺឧបករណ៍សំរាប់ធានាសន្តិសុខអ្នកប្រើប្រាស់ និងការទទួលបានប្រកបដោយសមធម៌ចំពោះ ភោគទ្រព្យ និងហេត្ថារចនាសម្ព័ន្ធផ្សេងទៀត និងមធ្យោបាយក្នុងការបង្កើនលទ្ធភាពទទួល និងប្រើប្រាសព័ត៌មាន ផ្នែក វិទ្យាសាស្ត្រអំពីសណ្ឋានអាកាសធាតុ និងធាតុអាកាសនៅថ្នាក់មូលដ្ឋាន។ ដោយហេតុថានៅមានភាពមិនច្បាស់លាស់ខ្លះអំពីសន្តិសុខនៃការប្រកបរបរចិញ្ចឹមជីវិត របស់ប្រជានេសាទ និងកសិករតូចតាច ទើបធ្វើឲ្យមាន ការគំរាម ចំពោះការឆ្លើយតបទៅនឹងការបន្សាំចំពោះការប្រែប្រួលអាកាសធាតុ ពេលដែលគេបញ្ចូលវាជាមួយ បញ្ហាសង្គម និងបរិស្ថានដទៃទៀត (pers com., MAFF-Fisheries Administration)។

ដូចដែលបានពិភាក្សាមកនេះ មានតំរូវការយ៉ាងខ្លាំងផងដែរសំរាប់ការបង្កើនមូលដ្ឋានចំណេះដឹងសំរាប់គាំទ្រដល់ ការសំរេចចិត្ត។ មូលដ្ឋានចំណេះដឹងទាំងនេះរួមមាន ១. កែលំអការត្រួតពិនិត្យ ២. កែលំអផែនទីធនធានទឹក ក្រោមដី  និងការចងក្រងចំណេះដឹងមានស្រាប់ (ប៉ុន្តែ នៅមិនរៀបរយ) អំពីទឹកក្រោមដីដែលមាននិងគុណភាពរបស់វា ៣. កែលំអភាពអាចរកបាន និងលទ្ធភាពប្រើប្រាស់ទិន្នន័យសំរាប់ដំណើរការការសំរេចចិត្ត និង ៤. ប្រព័ន្ធគាំទ្រសំរាប់ការរួមបញ្ចូលគ្នា និងការពង្រឹងសមត្ថភាគ្រប់គ្រងនៅកំរិតឃុំ និងខេត្ត និងនៅកំរិតធារា សាស្ត្រ។ ការពង្រឹងចំណេះដឹងនិងសមត្ថភាពស្របជាមួយមូលដ្ឋាននេះ អាចធ្វើឲ្យមានការគាំទ្រយ៉ាងសមស្របចំពោះយន្តការប្រតិបត្តិ ព្រមទាំងជួយផលិតករកសិកម្មធ្វើការសំរេចចិត្តថា តើត្រូវដាំដុះដំណាំរបស់ពួកគេនៅ ពេលណា និងដោយរបៀបណា ឧទាហរណ៍ ព័ត៌មានទាន់ពេលអំពីកំរិតទឹក និងភ្លៀង ការព្យាកររយៈពេលខ្លីនៃ កំរិត ទឹក និងភ្លៀងនិងការព្យាករទឹកជំនន់នៅរដូវវស្សា (Watt, B., 2009) (personal com collective consultation response)។

ប្តូរការយកចិត្តទុកដាក់មកកាន់ការបន្ថយ, គ្រប់គ្រងគ្រោះមហន្ត ក្រសួងអប់រំយុវជន និងកីឡា ពិតជាបាន ផ្តល់នូវការណែនាំសំរាប់ការសាងសង់សាលារៀន ទោះជាយ៉ាង ណាក៏ដោយ បញ្ហាទាក់ទងនឹងការបន្ថយគ្រោះ មហន្តរាយ មិនត្រូវបានគេបញ្ជាក់ ច្បាស់ក្នុងការសាងសង់សាលារៀនថ្មីៗនេះ ក្រោមជំនួយឧបត្ថម្ភពីគំរោងរបស់ធនាគារ ពិភពលោក និងធនាគារអភិវឌ្ឍន៍អាស៊ីនោះទេ។ សំរាប់ក្រសួងអប់រំ យុវជន និង កីឡា ពិតជានៅត្រូវការ ឲ្យមាននូវគោលការណ៏ណែនាំ និងក្រមបទដ្ឋានសាងសង់ ជាក់លាក់មួយ ដែលរួមបញ្ចូលនូវវិធានការបន្ថយគ្រោះមហន្តរាយនៅឡើយ។ អ្វីដែល សំខាន់ជាងនេះទៀត គឺគោលការណ៏ណែនាំទាំងនេះ ត្រូវអនុញ្ញាតិដោយក្រសួង រៀបចំដែនដីនគរូបនីយកម្ម និងសំណង់ MoLMUPC ដោយមានការពិគ្រោះយោបល់ ជាមួយក្រសួងសាធារណ: ការ និងដឹកជញ្ជូន MPWT និងស្ថាប័នឬក្រសួងពាក់ ព័ន្ធផ្សេងៗទៀត។ ដោយផ្សាភ្ជាប់ទៅនឹង "កង្វះខាត" នេះ បតំរូវឲ្យមានការបង្កើត នូវការណែនាំបន្ថែមទៀតសំរាប់ការធ្វើផែនការគ្រាអាសន្ននៅក្នុងសាលារៀន (ADPC, 2008)។ មានការស្នើថាដើម្បីរៀបចំការណែនាំនេះគេត្រូវពិគ្រោះយោបល់ ជាមួយកាកបាទក្រហមកម្ពុជា។ លើសពីនេះទៀត ដំណើរការពិគ្រោះយោបល់ត្រូវ ចង្អុលបង្ហាញពីតំរូវការពង្រីកវិសាលភាពនៃការអប់រំ អំពី ការបន្ថយគ្រោះមហន្តរាយ នៅគ្រប់កំរិតទាំងអស់នៃប្រព័ន្ធអប់រំ ក៏ដូចជានៅក្នុងសហគមន៏ ពោលគឺមិនមែនតែ ចំពោះអ្នកដែលធ្លាប់ទទួលរងគ្រោះ ឬអ្នកដែលត្រូវបានចាត់អាទិភាពថាមានហានិយ ភ័យខ្ពស់នោះទេ។

វិស័យគ្រប់គ្រងសុខភាព និងអាហារូបត្ថម្ភសហគមន៏ ជាវិស័យដែលអាច និងត្រូវបាន គេស្នើដាក់ជាចំណុចចាប់ផ្តើម សំរាប់ការបន្ថយគ្រោះមហន្តរាយ (Mony, K., and C. Thou, (2007) in their paper 'Health Impacts of Climate Variability and Change in Cambodia)។ ក្នុងចំណោមស្ថាប័នស្រាវជ្រាវទាំងឡាយ រួមមានទាំងក្រសួងសុខាភិ បាលជាដើម បានកំណត់ឃើញមានតំរូវការដើម្បីពង្រឹងរវាងការភ្ជាប់ទំនាក់ទំនង បញ្ជ្រៀបការប្រតិបត្តិ ការបន្សុំា ទៅនឹងការប្រែប្រួលអាកាសធាតុ និងភាពស៊ាំរបស់ សហគមន៏ចំពោះផលលំបាក់ផ្សេងៗកើតមានលើសុខភាពនិងផលិតភាពនៅគ្របវិ ស័យទាំងអស់ (MoH, 2008, and Resurreccion, B. P., Sajor, E. E. and E។ Fajber, 2008.)។

ចំណែកឯ អង្គការអុកស្វាមវិញ ការបន្សុាំទៅនឹងការប្រែប្រួលអាកាសធាតុជាបញ្ហាអភិវឌ្ឍន៍ ជនបទ ដែលតំរូវឲ្យមានការឆ្លើយតប ដែលនឹងបង្កើតយុទ្ធសាស្រ្ត និងជំរើសដោះស្រាយប្រកបដោយវិជ្ជមាន សំរាប់ ការបន្សុាំទៅនឹងការប្រែប្រួលអាកាសធាតុ។

សំរាប់យន្តការអភិវឌ្ឍន៍ស្អាត បានបញ្ជាក់យ៉ាងច្បាស់អំពីតំរូវការឲ្យមានការកំណត់នូវការទាក់ទងគ្នារវាងអាទិ ភាពវិនិយោគ ទៅនឹងគោលដៅអភិវឌ្ឍន៍ប្រកបដោយចិរភាព យន្តការលើកទឹកចិត្តឲ្យមានការចូលរួមសកម្មទាំង ពីផ្នែកឯកជន និងផ្នែកសាធារណៈ ក្នុងការទទួលយកនូវការផ្ទេរបច្ចេកវិទ្យាដែលមាននិរន្តរភាពទាក់ទងនឹងផលិតកម្មថាមពលប្រសិទ្ធផល និងការអភិរក្សព្រមទាំងយន្តការដើម្បីធានាថាការខិតខំប្រឹងប្រែងទាំងឡាយពិតជា បានបង្កើតផលផ្លែផ្កាច្បាស់លាស់ដល់ផ្នែកបរិស្ថានមូលដ្ឋាន (EU-ASIA, 2008)។ ការយល់ឃើញទាំងនេះ ក៏បាន លើកឡើងផងដែរពីសំណាក់អ្នកដែលបានចូលរួមក្នុងដំណើរការពិគ្រោះ ក្នុងការសិក្សាទំហំមួយនេះ។ ទោះជាយ៉ាងណាក៏ដោយ ពួកគេបានចាត់ទុកគំនិតចុងក្រោយនេះ ថាជាការបោះជំហានមួយដោយអំពាវនាវឲ្យមាន ដំណើរការនេះក្លាយជាស្ថាប័នមួយ (ជាការរួមបញ្ចូលគ្នានៃចំណេះដឹង និងប្រព័ន្ធផ្សេងៗ) ដែលនាំយកសហគមន៍ ទៅកាន់វិស័យជាក់ស្តែងមួយនៃយន្តការអភិវឌ្ឍន៍ស្អាត និងយន្តការទីផ្សារឧស្ម័នកាបូនិចផ្សេងទៀតដោយផ្ទាល់ក្នុងនាមជាអ្នកចូលរួមដែលមានសិទ្ធិចំពោះសប្បទានទាំងនោះ។

កំណត់កង្វះខាតចំណេះដឹងអំពីការបន្សុាំទៅនឹងការប្រែប្រួលអាកាសធាតុ ជាការផ្តោតការយកចិត្តទុកដាក់សំខាន់ មួយចំពោះការងារដែលបានអនុវត្តដោយក្រុមបច្ចេកវិជ្ជាវិទ្យាសាស្រ្តបរិស្ថាន អន្តរជាតិ និងក្រុមបច្ចេកវិជ្ជាវិទ្យា សាស្រ្តនេះបាល់ការសិក្សាស្រាវជ្រាវរបស់ពួកគេមានការចង្អុលបង្ហាញលើកង្វះខាតយ៉ាង**ខ្លាំងក្នុងការយល់ដឹង**យុទ្ធសាស្រ្តស្វ័យប្រវត្តិនៅកំរិតបុគ្គលនិងកំរិតគ្រួសារ និងអំពីប្រព័ន្ធទាំងឡាយដែលអាចជួយដោយផ្ទាល់ និងដោយប្រយោលសំរាប់ការបន្សុាំទៅនឹងការប្រែប្រួលអាកាសធាតុ។ (Resurreccion, B. P., Sajor, E. E. and E. Fajber, 2008)។

ចំណែកឯផ្នែកអង្គការមិនមែនរដ្ឋាភិបាលវិញចលនាការងារប្រាក់ចំណូលនិងអន្តោប្រវេសន៍ត្រូវបានគេមើលឃើញថា ជាយុទ្ធសាស្ត្រជា ស្វ័យប្រវត្តិដ៏សំខាន់សំរាប់ការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ។

តាមទស្សនៈពីក្នុងតំបន់ មជ្ឈមណ្ឌល START ប្រចាំតំបន់អាស៊ីភាគអាគ្នេយ៍ បានគាំទ្រចំពោះគំនិតផ្តើមស្រាវជ្រាវ ផ្នែកវិទ្យាសាស្ត្រទៅលើផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ និងយុទ្ធសាស្ត្របន្សាំ ដែលទាក់ទងនឹងការធ្វើ វិមជ្ឈការនៃការគ្រប់គ្រងធនធានទឹក និងដីធ្លី នៅក្នុងតំបន់មេគង្គ ដោយរួមសហការជាមួយគណៈកម្មាធិការទន្លេមេគង្គ។ តាម Tyler, S., and L. Fajber (2009) បានស្នើថាការផ្តួចផ្តើមគំនិតទាំងនេះបានផ្តល់នូវឱកាសសំរាប់ ការពង្រឹងសមត្ថភាពនៃការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុថ្នាក់តំបន់តាមរយៈកិច្ចសហប្រតិបត្តិការ និង ការរៀនសូត្រ –ដែលពេលបច្ចុប្បន្ននេះមានកំរិតនូវទំហំ និងបរិមាណ ដោយសារកំរិតនៃគំនិតឆ្លើយតបថ្នាក់ជាតិលើការចែករំលែកព័ត៌មានទាក់ទងដល់ធនធានទឹក។ គ្រប់គ្រង។វាជាកង្វះខាតនូវប្រព័ន្ធមួយក្នុងការកសាង ភាពដើម្បីបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុនៅប្រទេសក្នុងអាងទន្លេមេគង្គ។ ដោយឡែកគណៈកម្មាធិការទន្លេមេគង្គក៏មានការប្រឈមផងដែរក្នុងការធ្វើឲ្យមានតុល្យភាពរវាងការអភិវឌ្ឍធនធាន និងការកសាង ផែនការរបស់ខ្លួនជាមួយនឹងតំរូវការដើម្បីគ្រប់គ្រងផលប៉ះពាល់។ ការលំបាកទាំងនោះមានជាពិសេសលើការ ចាត់ចែង ពិព្រោះគណៈកម្មាធិការនេះមិនមានការទទួលខុសត្រូវផ្នែកនយោបាយជាផ្លូវការចំពោះអ្នកដែលរង ផលប៉ះពាល់ដោយ គំរោងអភិវឌ្ឍន៍ធនធានរបស់ខ្លួនទេ។ (Tyler, S., and L. Fajber, 2009)។

សំរាប់មួយភាគធំនៃឯកសារដែលយើងបានពិនិត្យសិក្សា និងពិគ្រោះបានស្នើឡើងជាញយៗអំពីតំរូវការឲ្យមានជា "រចនាសម្ព័ន្ធ" ច្បាស់លាស់នូវអ្នកទាំងឡាយដែលមានសមត្ថភាពអនុវត្ត និងគាំទ្រដល់ការបង្កើត និងបង្វែរចំណេះ ដឹងអំពីការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ។ បច្ចុប្បន្ននេះ នៅមិនទាន់មានបណ្តាញ និងវេទិកាគ្រប់គ្រាន់នៅឡើយនៅកម្ពុជា សំរាប់ការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុដែលភ្នាក់ងារអភិវឌ្ឍន៍អាចប្រើប្រាស់ក្នុង ការជួបជុំគ្នា ឬចូលរួមធ្វើសកម្មភាព។

វេទិកា និងបណ្ដាញខ្លះដែលមានហាក់ដូចជាសំរាប់តែអ្នកជំនាញ និងមិន មែនសំរាប់អ្នកដែលបំពេញ "តួនាទីប្រចាំថ្ងៃ"នៅក្នុងការអភិវឌ្ឍន៍ជនបទ ក្រៅទីក្រុងភ្នំពេញទេ។ យើងអាច កំណត់សំគាល់ថា វាមិនត្រឹមតែជារបនាសម្ព័ន្ធដើម្បីរក្សាទុកព័ត៌មានតែប៉ុណ្ណោះទេ ប៉ុន្តែ វាក៏អាចប្រើសំរាប់សំរប សំរួលការកសាងសមត្ថភាពនៅថ្នាក់ជាតិជាពិសេសថ្នាក់ឃុំដើម្បីកែលំអភាពទទួលបាន និងការឆ្លើយតបចំពោះ ការគ្រោងនៃគំរោងបន្សុាំទៅនឹងការប្រែប្រួលអាកាសធាតុ និងដំណើរការសំរេចចិត្ត (pers com., collective consultation response)។ បើស្ថានភាពនេះអាចកើតឡើងបាន នោះគេសូមផ្ដល់អនុសាសន៍ថាវាគួរតែទទួលបានការណែនាំដោយ"គោលនយោបាយ" ដើម្បីធានាថាគ្រប់ស្ថាប័នពាក់ព័ន្ធទាំងអស់ចំពោះគំនិតបន្សុាំទៅនឹងការប្រែប្រួលអាកាសធាតុ ឬអ្នកទាំងឡាយណាដែលដាក់ស្នើគំនិតទៅសហគមន៍អ្នកផ្ដល់ជំនួយ ពិតជាមានជំនាញ និង សមត្ថភាពគ្រប់គ្រាន់ដើម្បីបំពេញមុខងាររបស់ខ្លួនមានដូចជា ការធ្វើឲ្យមានភាពជាស្ថាប័ន សហគមន៍អ្នកប្រតិបត្តិ (COP) ដែលមានគុណវុឌ្ឍិគ្រប់គ្រាន់ (pers com., CBNRM LI)។

## ៤.០ យុទ្ធសាស្ត្រកសាងសមត្ថភាព

### ៤.១ ការកំណត់កង្វះខាតសមត្ថភាព និងអាទិភាព

ដើម្បីកំណត់នូវកង្វះខាតផ្នែកសមត្ថភាពក្នុងការបន្សុាំទៅនឹងការប្រែប្រួលអាកាសធាតុដោយផ្ទាល់ ការសិក្សានេះ បានរៀបចំធ្វើសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិមួយ–ដោយផ្អែកលើខ្លឹមសារឯកសារដែលបានពិនិត្យស្រាវ ជ្រាវ និងលទ្ធផលនៃការសំភាសន៍ជាមួយបុគ្គលសំខាន់ៗ។ ក្រុមអ្នកចូលរួមក្នុងសិក្ខាសាលានេះក៏បានចោទសួរឡើងអំពី ១. តើសមត្ថភាពអ្វីខ្លះដែលត្រូវការដើម្បី ដោះស្រាយគោលបំណងបំពេញកង្វះខាតនេះ ទី ២.តើនរណា ដែលគេត្រូវផ្ដោតការយកចិត្តទុកដាក់ដើម្បីកសាងសមត្ថភាព ទី ៣. នរណាជាអ្នកប្រើប្រាស់ចំណេះដឹង ,សមត្ថ ភាពទាំងនេះនិងទី ៤.វិធីសាស្ត្រដែលតំរូវការកសាងសមត្ថភាពទាំងនេះត្រូវអនុវត្ត។ បើទោះជាដំណើរនៃការ ពិគ្រោះនេះត្រូវបានគេយល់ដឹងក្ដី ក៏មានភស្តុតាងខ្លះដែលបង្ហាញថាមានកង្វះខាតផ្នែកចំណេះដឹងមូលដ្ឋានអំពីការប្រែប្រួលអាកាសធាតុនិងចំណេះដឹងអំពីការបន្សុាំក្នុងចំណោមអ្នកចូលរួមក្នុងសិក្ខាសាលានេះ ដើម្បីផ្ដល់ ព័ត៌មានជាក់លាក់អំពីអ្វីដែលកំពុងចោទសួរឡើងដោយវេទិកាបន្សុាំនេះ។

ប្រការនេះបានបញ្ជាក់ឲ្យកាន់តែច្បាស់ពី តំរូវការសំរាប់ឲ្យមាន “វេទិកា” ព្រមទាំងបានបញ្ជូនសារយ៉ាងច្បាស់ក្រឡែតមួយថា ការបង្កើតនូវវេទិកាអំពីការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុណាមួយសំរាប់ប្រទេសកម្ពុជា គួរធ្វើឡើងជាជំហានៗ និងត្រូវឲ្យស្របជាមួយកំរិតចំណេះដឹងរបស់ប្រជាជនកម្ពុជាដែលកំពុងមាន–ហើយត្រូវចាត់ទុកវាជាចំណុចចាប់ផ្តើម។

“ការសិក្សាទំហំមួយអំពីការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុនៅកម្ពុជា: ការពិនិត្យស្រាវជ្រាវផ្នែកអក្សរសាស្ត្រ និងទស្សនៈរបស់អ្នកចូលរួម” ធ្វើឡើងសំរាប់វេទិកាបន្សាំ កង្វះខាតផ្នែកកសាងសមត្ថភាពដើម្បី បន្សាំទៅ នឹងការប្រែប្រួលអាកាសធាតុត្រូវបានរកឃើញ និងចាត់ចូលជាក្រុមរួមមាន ក្រុមចំណេះដឹង ក្រុមប្រព័ន្ធនិងក្រុមគោលនយោបាយ។ ដើម្បីឲ្យកាន់តែច្បាស់ ខាងក្រោមនេះជាការណែនាំ ដើម្បីកំណត់ជា បរិបទអំពីរបៀបដែល ក្រុមទាំងនេះត្រូវបានបកស្រាយក្នុងបរិបទនៃឯកសារសិក្សានេះ និងជាមួយអ្នកដែលយើងបានពិគ្រោះយោបល់:

- ចំណេះដឹងអំពីការបន្សាំ: ព័ត៌មានដែលកសាងលើមូលដ្ឋានយុទ្ធសាស្ត្រសំរាលនោះគឺការកាត់បន្ថយផល ប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ
- ប្រព័ន្ធអំពីការបន្សាំ:ជាប្រព័ន្ធកសាងឡើង និងដាក់ចំណេះដឹងអំពីការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ ទៅក្នុងការប្រើប្រាស់ទូលំទូលាយ និងប្រកបដោយប្រសិទ្ធិផល និងជាប្រព័ន្ធ។
- រចនាសម្ព័ន្ធអំពីការបន្សាំ:ផ្នែកមួយដែលបំពេញមុខងារដូចជាកន្លែងផ្ទុកចំណេះដឹងអំពីការបន្សាំទៅនឹង ការប្រែប្រួលអាកាសធាតុ និងជាចំណុចរួមនៃការសំរបសំរួល និងធ្វើអន្តរកម្មសំរាប់ការចែករំលែកចំណេះ ដឹង និងការកសាងសមត្ថភាពដោយផ្ទាល់ និង
- គោលនយោបាយអំពីការបន្សាំ: ជាគោលនយោបាយដែលគាំទ្រការបង្កើតការចែករំលែក ការប្រើប្រាស់ និងអភិបាលលើចំណេះដឹងអំពីការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ –រួមទាំងតំរូវការឲ្យមានការ បង្កើតនូវគោលនយោបាយថ្មីៗបន្ថែមទៀតផង។

ខាងក្រោមនេះជាការបង្ហាញអំពី "កង្វះខាត" សមត្ថភាពដែលជាអាទិភាព ដែលរកឃើញអំឡុងពេលនៃសិក្ខាសាលាពិគ្រោះយោបល់និងការពិភាក្សាជាបន្តបន្ទាប់មកទៀត។

## កង្វះខាតផ្នែកចំណេះដឹងបន្សាំជាអាទិភាព និងគោលបំណង

១. មានតំរូវការដើម្បីកសាងនូវការយល់ដឹងឲ្យច្បាស់អំពីរបៀបដែលបណ្តាញសង្គម និងស្ថាប័នក្រៅផ្លូវការ ត្រូវប្រតិបត្តិ។ ការយល់ដឹងនេះនឹងធានាថាវិធានការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុដែលបាន អនុវត្ត យ៉ាងហោចណាស់បានគិតគូរដល់សមធម៌សង្គម និងយេនឌ័រ និងបាននាំយកប្រសិទ្ធិផល ចិរភាព និងភាពអាចអនុវត្តបានទៅក្នុងដំណើរការនៃការបន្សាំនេះ។

២. នៅមានកង្វះខាតផ្នែកចំណេះដឹងដែលសមស្របសំរាប់ពង្រឹងប្រព័ន្ធដំណាំស្រូវនៅកម្ពុជា ក្នុងបរិបទបំរែបំរួលអាកាសធាតុនៅឡើយ។ ការបំពេញកង្វះខាតនេះនាំមកនូវការធានានូវសុវត្ថិភាពនៃ "ការដាំដុះ" ក្នុងបរិបទចំនួន ២ –នោះគឺបរិបទប្រែប្រួលអាកាសធាតុ និងការអភិវឌ្ឍប្រកបដោយចិរភាព។

៣. អវត្តមានផ្នែកចំណេះដឹងអំពីការបញ្ចូលទិន្នន័យអាកាសធាតុដែលងាយប្រើប្រាស់ជាមួយលក្ខណ:ទាំងឡាយផ្នែកជលសាស្ត្រ និងធាតុអាកាស។ ភាពអាចរកបាននូវទិន្នន័យនេះនឹងសំរួលដល់ការបង្កើត និងកែ លំអការព្យាករ និងសេនារីយូប្រែប្រួលអាកាសធាតុ ដើម្បីសំរបសំរួល ,ដឹកនាំការចាត់អាទិភាព និងការ អនុវត្តតំរូវការនៃការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ នៅនឹងកន្លែង។

៤. មានតំរូវការដើម្បីកំណត់ឧបសគ្គរារាំងមិនឲ្យទទួលជោគជ័យចំពោះការធ្វើផែនការគ្រប់គ្រងធនធានធម្មជាតិ និងសុខភាព និងការបន្សាំដោយស្វ័យប្រវត្តិទៅនឹងការប្រែប្រួលអាកាសធាតុ។ ដោយការកំណត់ និងកាត់បន្ថយឧបសគ្គទាំងនេះជាបន្តបន្ទាប់ការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុអាចនឹងដំណើរការទៅមុខលឿន និងរបៀបដែលវាដំណើរការ អាចធានានូវការទទួលផលប្រយោជន៍ប្រកបដោយ សមធម៌នៃសហគមន៍មូលដ្ឋាន ដែលឆ្លុះបញ្ចាំងពីការគោរពសិទ្ធមនុស្ស និងចិរភាពផ្នែកបរិស្ថាន។

## កង្វះខាតផ្នែកប្រព័ន្ធបន្សាំជាអាទិភាព និងគោលបំណង

១. បច្ចុប្បន្ននៅមិនទាន់មានប្រព័ន្ធសមស្របណាមួយដើម្បី ដាក់បញ្ចូលការព្យាករធាតុអាកាស និងអាកាសធាតុជាមួយទំរង់ជលសាស្ត្រសំរាប់ការប្រើប្រាស់ថ្នាក់ជាតិ ខេត្ត និងសហគមន៍-ឲ្យទៅជាប្រព័ន្ធតែមួយ នៅឡើយ។ ធ្វើដូច្នេះដើម្បីធានាថាចំណេះដឹងដែលបានបង្កើតទាក់ទងនឹងប្រធានបទនេះ ត្រូវបាននាំយក ទៅដល់កិរិតអនុវត្តប្រកបដោយប្រសិទ្ធិផល និងជាប់លាប់ ដោយសារប្រព័ន្ធនេះត្រូវបានគេបង្កើត និង ប្រើ ហើយកែលំអក្នុងចំណោមក្រុមអ្នកពាក់ព័ន្ធចំពោះការកសាងចំណេះដឹងទាំងឡាយ។

២. ដើម្បីធានាឲ្យមានការបន្សាំប្រកបដោយវិជ្ជមាន និងសមធម៌ នោះតំរូវឲ្យមានការបង្កើតនូវការផ្តួចផ្តើមគំនិត បង្កើតប្រព័ន្ធមួយដែលសំរបសំរួលការវិភាគទិន្នន័យឆ្លងវិស័យ ការចែករំលែចំណេះដឹង ការធ្វើផែន ការ និងការអនុវត្តការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ។ គេបានរំពឹងទុកថា ខណ:ពេលដែល ចំណេះដឹងបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុត្រូវបានបង្កើត នោះខ្លឹមសារ និងការប្រើប្រាស់ចំណេះ ដឹងទាំងនេះនឹងត្រូវរក្សាទុកតាមផ្នែកនិមួយៗ។ ប្រការនេះ អាចនាំឲ្យការបន្សាំតាមផ្នែកដែលបង្កការ រារាំងដល់តំរូវការនៃផ្នែកផ្សេងទៀត ឬវាមិនបានសំរួលដល់ការបន្សាំជាសមូហភាព និងទូលំ ទូលាយ។

៣. តំរូវការឲ្យមានការបង្កើតនូវប្រព័ន្ធមួយដើម្បីបញ្ជ្រាបបរិស្ថាន ការចិញ្ចឹមជីវិត ការអប់រំ សុខភាព និងអាហារូបត្ថម្ភទៅក្នុងផែនការ និងការឆ្លើយតបទៅនឹងការគ្រប់គ្រងគ្រោះមហន្តរាយ។ គុណតម្លៃត្រូវបាន គេឃើញមានប្រើប្រាស់ក្នុងក្របខ័ណ្ឌនៃការគ្រប់គ្រងគ្រោះមហន្តរាយ ប៉ុន្តែនៅមិនទាន់មានការបញ្ជ្រាបទៅគ្រប់វិស័យនៅឡើយ កង្វះខាតជាបន្តអំពីការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ និងកង្វះខាត យុទ្ធសាស្ត្រ ដើម្បីសំរាលផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុក៏ប្រហែលជានៅកើតមាន ឬមិនទាន់ បានកំណត់នៅឡើយ។ ប្រការនេះ នាំបណ្តាលឲ្យមានការប្រមើលមើលចំពោះសមត្ថភាពរបស់កម្ពុជាក្នុងការបន្សាំទៅនឹងការប្រែប្រួល អាកាសធាតុទៅអនាគតថាមានកិរិតមួយខ្សោយនៅឡើយ។

៤. ព័ត៌មានផ្នែកវិទ្យាសាស្ត្រអំពីការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុអាចរកបានប៉ុន្តែសំរាប់ករណីជាច្រើន ការស្វែងរក និងប្រើប្រាស់ព័ត៌មានអំពីធាតុអាកាស សណ្ឋាននៃអាកាសធាតុ និងការបន្សាំទៅ នឹងការប្រែប្រួលអាកាសធាតុនៅកំរិតមូលដ្ឋានត្រូវបានគេមើលឃើញថាមានលក្ខណៈអរូបីយ៍ និងគ្មានការបទបែន។ មានតំរូវការឲ្យមានប្រព័ន្ធដែលធ្វើបច្ចុប្បន្នកម្មនិងបកស្រាយនូវព័ត៌មានដែលទទួលបានឲ្យ មានភាពងាយស្រួលយល់ និងអាចប្រើប្រាស់បានដោយអ្នកប្រើប្រាស់ទូលំទូលាយ។ ធ្វើរបៀបនេះ ត្រូវគេ រំពឹងថា ក៏នឹងអាចលើកទឹកចិត្តឲ្យមានការប្រើប្រាស់នូវព័ត៌មានទាំងនេះសំរាប់ធ្វើការសំរេចចិត្តនៅថ្នាក់មូលដ្ឋាន និងកំរិតជាតិ។

៥. ការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុត្រូវគេមើលឃើញថាមានការស្របគ្នាយ៉ាងខ្លាំងទៅនឹងការអភិវឌ្ឍន៍ប្រកបដោយចិរភាពនៃប្រជាជនក្រីក្រនៅជនបទកម្ពុជា។ ដោយហេតុថា កម្មវិធីអភិវឌ្ឍន៍ជាច្រើន ការរួមបញ្ចូលនូវការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ សមធម៌យេនឌ័រ នៅមិនទាន់មានភាពច្បាស់លាស់នៅឡើយ។ អាស្រ័យហេតុនេះ ការណែនាំអំពីដំណើរការតាំងពីផ្តើមដំបូងនូវវេទិកាសំរប មួយ ដែលលើកកំពស់ការទទួលបានរបស់ស្ត្រីលើសិទ្ធិប្រើប្រាស់ដីធ្លី និងការកាន់កាប់ឥណទាន ការវិនិយោគផ្នែកកសិកម្ម បច្ចេកវិជ្ជា និងទីកន្លែងទុកដាក់ផលិតផល វាមិនត្រឹមតែនឹងនាំសំរេចតែការបន្សាំទៅ នឹងការប្រែប្រួលអាកាសធាតុតែប៉ុណ្ណោះតេ ប៉ុន្តែ វានៅអាចជៀសវាងបាននូវវិសមធម៌ដែលក្របខ័ណ្ឌអភិវឌ្ឍន៍ជាច្រើននៅមិនទាន់អាចកែតំរូវបាននៅឡើយ។

៦. អ្វីដែលច្បាស់នៅទីនេះគឺថាការបង្កើតនូវការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុដែលសមស្រប និងអាចអនុវត្តបាននឹងតំរូវឲ្យមានការចូលរួមពីគ្រប់អ្នកពាក់ព័ន្ធទាំងអស់–រាប់ចាប់តាំងពីដំណើរការធ្វើផែន ការរហូតដល់ការអនុវត្តការផ្តល់មតិឆ្លើយតបដើម្បីវាយតម្លៃលើវិធានការដែលអនុវត្តជាដើម។ គេក៏ប្រាកដផងដែរថា ឧបស័គ្គដែលរារាំងពីសង្គម បច្ចេកទេស ស្ថាប័ន និងគោលនយោបាយក្នុងការចូលរួម ដោយពេញលេញពីសំណាក់អ្នកពាក់ព័ន្ធទាំងអស់នៅបន្តកើតមាននៅឡើយ។ ខណៈពេលដែលឧបសគ្គ ទាំងនេះមានមកពីប្រភពផ្សេងៗគ្នានោះតំរូវឲ្យមានការចាត់វិធានការជាប្រព័ន្ធ ដើម្បីលុបបំបាត់ធ្វើឲ្យការបន្សាំត្រូវបានធ្វើឡើងត្រឹមត្រូវ និងទទួលបានផលប្រកបដោយសមធម៌។

៧. នាពេលបច្ចុប្បន្ននេះ នៅមិនទាន់មាន "ក្រុមបទដ្ឋាន" សំរបសំរួលអំពីវិធីសាស្រ្ត ,បទដ្ឋានស្រាវជ្រាវសំរាប់ឲ្យអ្នកទាំងឡាយណាដែលត្រូវការស្រាវជ្រាវអំពីការបន្សុាំទៅនឹងការប្រែប្រួលអាកាសធាតុអនុវត្ត តាមនៅឡើយ។ ប្រការនេះ សូមស្នើបង្កើត នូវរបៀបជាប្រព័ន្ធមួយ ដើម្បីធានាថា គេបានគោរពតាមបទដ្ឋានស្រាវជ្រាវ និងខ្លឹមសារស្រាវជ្រាវទៀតសោតត្រូវសាមញ្ញ ,ងាយស្រួលប្រើដោយវិស័យ និងក្រុមអ្នកចាប់អារម្មណ៍ផ្សេងៗគ្នា។

## កង្វះខាតផ្នែករចនាសម្ព័ន្ធបន្សុាំជាអាទិភាព និងគោលបំណង

១. បើទោះជា អ្នកខ្លះបាននិយាយថា មានព័ត៌មានគ្រប់គ្រាន់អំពីការបន្សុាំទៅនឹងការប្រែប្រួលអាកាសធាតុ ក៏ដោយ ប៉ុន្តែ ព័ត៌មានទាំងនោះ ភាគច្រើនមានការលំបាកស្វែងរក សូម្បីជាព័ត៌មានមូលដ្ឋាន ឬព័ត៌មាន ដែលទើបបង្កើតថ្មីៗដែលត្រូវទៅនឹងសេចក្តីត្រូវការរបស់គេ។ ស្ថានភាពបែបនេះជាញឹកញាប់បង្កជាឧបសគ្គចំពោះការប្រើប្រាស់ចំណេះដឹងសមស្រប និងដាក់កំរិតដល់ការបង្កើតថ្មីនូវបរិបទជាក់លាក់។ មាន តំរូវការដើម្បីបង្កើតនូវចំណេះដឹងអំពីការបន្សុាំទៅនឹងការប្រែប្រួលអាកាសធាតុ និងការរួមបញ្ចូលនូវ ចំណេះដឹងទាំងនោះទៅជា "ចំណេះដឹងតែមួយ" ដែលអាចអនុវត្ត និងគាំទ្រដល់ការបង្កើត កែច្នៃ និងបញ្ជូនចំណេះដឹងអំពីការបន្សុាំទៅនឹងការប្រែប្រួលអាកាសធាតុ។

២. តាមស្មារតីមួយ "វេទិកាបន្សុាំទៅនឹងការប្រែប្រួលអាកាសធាតុ" សំរាប់កម្ពុជាត្រូវបានគេចាត់ទុកជា ក្រុមប្រឹក្សា,តួអង្គមួយ ដែលសំរបសំរួល និងជួយដល់កិច្ចសន្ទនាអំពីការបន្សុាំទៅនឹងការប្រែប្រួលអាកាស ធាតុ និងកសាងសមត្ថភាពនៅថ្នាក់ជាតិ និងថ្នាក់ឃុំ។ នេះជាភារកិច្ចយ៉ាងធំធេង ពោលគឺពុំមែនគ្រាន់តែជាប្រព័ន្ធមួយដែលមិនអាចធានាប្រសិទ្ធិភាពនៃការអនុវត្តនោះទេ។ "វេទិកា" នេះក៏នឹងប្រតិបត្តិផងដែរ ក្នុងនាមជារចនាសម្ព័ន្ធ ដែលអាចរួមបញ្ចូលនូវតំរូវការកសាងសមត្ថភាព ដោយសារវាជាធាតុតែមួយគត់ ដែលជាប់ទាក់ទងយ៉ាងស្អិតទៅនឹងវិស័យដែលពាក់ព័ន្ធទាំងអស់។ ប្រហែលដោយសារវាជា តួនាទី មួយហើយ ទើបរចនាសម្ព័ន្ធ អាចមានការឆ្លើយតបបន្ថែមទៅនឹងការរៀបចំនៃគំរោងបន្សុាំទៅនឹងការប្រែប្រួលអាកាសធាតុ និងកែលំអចំពោះការសំរេចចិត្តអំពីដំណើរការនៃការបន្សុាំទៅនឹងការប្រែប្រួលអាកាសធាតុ។

### កង្វះខាតផ្នែកគោលនយោបាយបន្សាំជាអាទិភាព និងគោលបំណង

១. មានកង្វះខាតផ្នែកគោលនយោបាយដើម្បីគាំទ្រដល់ការបញ្ជ្រាបការបន្សាំទៅនឹងការប្រែប្រួលអាកាស ធាតុទៅក្នុងគោលនយោបាយថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិការធ្វើផែនការ និងដំណើរការគ្រោងថវិកា។ ដោយបញ្ចូលនូវគោលនយោបាយទាំងនោះ វានឹងជួយធានាថា គោលបំណងនៃចំណេះដឹងអំពីការបន្សាំ ទៅនឹងការប្រែប្រួលអាកាសធាតុ ប្រព័ន្ធ និងរចនាសម្ព័ន្ធទាំងឡាយនឹងទទួលនូវការផ្តល់ថវិកា និងអនុវត្ត ប្រកបដោយប្រសិទ្ធិភាព និងចិរភាព។

២. គោលនយោបាយមួយពិតជាត្រូវការដើម្បីគាំទ្រចំពោះការចូលរួមពីសំណាក់សហគមន៍ កសិករ និងប្រជា នេសាទតូចតាច ក្នុងការធ្វើផែនការសេដ្ឋកិច្ចថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ ធ្វើរបៀបនេះ នឹងនាំឲ្យមាន ការនាំយក "គោលនយោបាយ" ឲ្យកៀកទៅនឹងការអនុវត្ត និងគាំទ្រដល់ការអនុវត្តការបន្សាំនៅមូលដ្ឋាន ដែលនឹងនាំឲ្យមានការកែលំអទំនាក់ទំនងទៅនឹងតំរូវការ និងចិរភាពនៃអន្តរាគមន៍។

៣. ត្រូវការគោលនយោបាយដើម្បីបញ្ចូលនូវការទាញយកមកប្រើនូវការសំរេចចិត្តដែលផ្អែកលើការស្រាវ ជ្រាវទាំងផ្លូវការ និងក្រៅផ្លូវការ ,មូលដ្ឋាន នៅគ្រប់ការសិក្សាទាំងអស់។ ធ្វើយ៉ាងនេះ នឹងបន្ថយនូវការ ចាប់អារម្មណ៍ដោយឡែកពីគ្នាចំពោះការគាំទ្រតាមវិស័យ ការសំរេចចិត្តទាំងឡាយនឹងធ្វើឡើងផ្អែកលើ ព័ត៌មានត្រឹមត្រូវ និងឯកភាពគ្នា និងជារួមធ្វើឲ្យប្រសើរឡើងនូវប្រសិទ្ធិភាពឆ្លើយតប។

៤. នាពេលបច្ចុប្បន្ននេះនៅប្រទេសកម្ពុជាមានបណ្តាញប្រែប្រួលអាកាសធាតុបណ្តាញ និងវេទិកាផ្សេងៗទៀតដែលជាប់ទាក់ទងកំពុងរីកចំរើនជាលំដាប់។ ដោយហេតុនេះ ការយល់ច្រឡំអំពីបំណង និងកិច្ចខិត ខំប្រឹងប្រែងដែលត្រួតលើគ្នាផ្សេងៗ នឹងនាំឲ្យមានការដើរខុសទិសដៅ និងកង្វះប្រសិទ្ធិភាពនៃការប្រើ ប្រាស់ធនធាន។ ត្រូវមានគោលនយោបាយមួយ ដែលផ្តល់នូវការណែនាំដល់ភ្នាក់ងាររដ្ឋាភិបាល គ្រឹះស្ថាន ស្រាវជ្រាវ អង្គការមិនមែនរដ្ឋាភិបាល ជាតិ និងអន្តរជាតិ និងសហគមន៍ អំពីរបៀបដែលធនធានត្រូវប្រើ ដែលសមស្រប និងមានទំនាក់ទំនងគ្នាល្អ។ (ចូរកត់សំគាល់ថា "គោលនយោបាយ" នោះមិនចាំបាច់ត្រូវ តែធ្វើឡើងតែជាមួយរដ្ឋាភិបាលទេ ពោលគឺវាអាចជាកិច្ចព្រមព្រៀងសហប្រតិបត្តិការ ដែលមើលខុសត្រូវ ដោយស្ថាប័នមួយដែលជ្រើសតាំងឡើងជាចំពោះកិច្ច)។

៥. ត្រូវមានគោលនយោបាយមួយដែលគាំទ្រការរួមបញ្ចូលនូវផែនការបន្សាំសំរាប់អនុវិស័យទាំងឡាយ រួមមាន ជលផល និងវារីវប្បកម្ម ទៅក្នុងកម្មវិធីសកម្មភាពជាតិដើម្បីបន្សាំទៅនឹងការប្រែប្រួលអាកាស ធាតុ។ ធ្វើរបៀបនេះ នឹងបង្កើននូវប្រសិទ្ធិភាពចំពោះតំរូវការធនធាននៃវិស័យ និងផ្នែក ដែលត្រូវបាន "មើលរំលង" ពីការចាត់អាទិភាពគាំទ្រថវិកា ដែលជារួមធានានូវសមធម៌ក្នុងការឆ្លើយតបនិងកំរិតឧបសគ្គដែលបណ្តាលមកពីកង្វះខាតនេះ ក្នុងតំរូវការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុចំពោះវិស័យពាក់ព័ន្ធ។

៦. ត្រូវមានគោលនយោបាយមួយដើម្បីផ្តល់ការគាំទ្រចំពោះការរួមបញ្ចូលនូវផ្នែកគ្រប់គ្រងធនធានធម្មជាតិ ទៅក្នុងគោលនយោបាយឆ្លើយតបចំពោះគ្រោះមហន្តរាយ និងផែនការអភិវឌ្ឍន៍។ ធ្វើរបៀបនេះ នឹង បង្កើននូវគុណតម្លៃចំពោះកិច្ចខិតខំប្រឹងប្រែងគ្រប់គ្រងធនធានធម្មជាតិ និងការពារចំពោះសេវាបរិស្ថានផ្អែកលើមូលដ្ឋានប្រព័ន្ធអេកូធម្មជាតិដ៏មានសារៈសំខាន់អំឡុងពេលនៃការឆ្លើយតបចំពោះគ្រោះមហន្តរាយ–ជាសេវាដ៏សំខាន់បំផុតចំពោះដំណាក់កាលស្តារឡើងវិញពីផលប៉ះពាល់បណ្តាលពី "គ្រោះមហន្តរាយ"។

៧. ត្រូវមានគោលនយោបាយគាំទ្រដល់ការលើកទឹកចិត្តចំពោះផ្នែកឯកជនឲ្យចូលរួមក្នុងការបន្សាំទៅនឹងការ ប្រែប្រួលអាកាសធាតុ។ ធ្វើយ៉ាងនេះគំនិតច្នៃប្រឌិតក្នុងការបន្សាំ និងតំរូវការផ្នែកធនធានសំរាប់គាំទ្រគំនិតច្នៃប្រឌិតទាំងនេះអាចប្រមូលបានយ៉ាងប្រសិទ្ធិផល ព្រមទាំងផ្តល់នូវយន្តការប្រកបដោយចិរភាពដើម្បីជំរុញការបន្សាំឆ្ពោះទៅមុខយ៉ាងជាប់លាប់។

## ៤.២ យុទ្ធសាស្ត្រសំរាប់កសាងសមត្ថភាពបន្សាំ ទៅនឹងការប្រែប្រួលអាកាសធាតុ

បើទោះជាតំរូវការកសាងសមត្ថភាពត្រូវបានរកឃើញជាពិស្តារខ្លះនៅក្នុងវិស័យ ច្នងវិស័យ និងវេទិកានៃតំរូវការ ប្រតិបត្តិទាំងឡាយក៏ដោយ ក៏គេត្រូវកត់សំគាល់ថាមានតំរូវការ ដើម្បីងាកមើលត្រលប់ក្រោយ និងកសាងនូវការ យល់ដឹងឲ្យបានទូលំទូលាយថែមទៀត សំរាប់អ្នកខ្លះ និងត្រូវពង្រឹងចំណេះដឹងលើអ្នកឯទៀតអំពី ការសំរាលផល នាំឲ្យមានការប្រែប្រួលអាកាសធាតុ ការសំរាលផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុនិងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ។ យោងតាមទស្សនៈផ្សេងៗនៅ ឧបសម្ព័ន្ធ ២.៣.៤ និង ៥ អំពីការកសាងសមត្ថភាព និងចំណេះដឹងត្រូវធ្វើ ឡើងនៅទីណា ជាមួយនរណា ភាគច្រើនហាក់ដូចជាមានការស្របគ្នា ទៅនឹងអ្នកប្រើប្រាស់ចុងក្រោយនៃចំណេះដឹងនេះ។ លើសពីនេះទៀត មួយភាគធំនៃអ្នកប្រើប្រាស់ចំណេះដឹងចុងក្រោយ ស្ថិតនៅមូលដ្ឋាន–ខេត្ត ស្រុក ឃុំ និងកិរិតសហគមន៍។ ប្រការនេះ នាំឲ្យយើងយល់កាន់តែច្បាស់ថាការកសាងសមត្ថភាព បន្សាំត្រូវចាប់ផ្តើមធ្វើ នៅទីណា និងដោយរបៀបណា។

នៅឆ្នាំដំបូងនៃការយល់ឃើញរបស់ "វេទិកាកម្ពុជាស្តីពីការប្រែប្រួលអាកាសធាតុ" ដែលជាដំណាក់កាលរៀបចំ រចនាសម្ព័ន្ធនៅឡើយ នោះយើងស្នើ ឲ្យមានការផ្តល់នូវកញ្ចប់សាងសមត្ថភាពអំពីការប្រែប្រួលអាកាសធតុមួយមាននូវចំណេះដឹងទូទៅអំពីការសំរាលសកម្មភាពនាំឲ្យមានការប្រែប្រួលអាកាសធាតុ ការសំរាលផលប៉ះ ពាល់ ពីការប្រែប្រួលអាកាសធាតុ និងទស្សនាទានអំពីការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ យុទ្ធសាស្ត្រ និង ក្របខ័ណ្ឌសកម្មភាពផ្សេងៗ។ វេទិកាទាំងឡាយគួរធ្វើឡើងតាមរយៈការរួមបញ្ចូលគ្នារវាងសិក្ខាសាលា និងដំណើរ ការតាំងបង្ហាញថ្នាក់ខេត្ត ដែលមានការចូលរួមពីអ្នកពាក់ព័ន្ធក្នុងខេត្ត ស្រុក និងឃុំ រួមជាមួយអង្គការមិនមែន រដ្ឋាភិ បាលទាំងឡាយ ដែលបាន ឬមានសក្តានុពលខ្ពស់ក្នុងការបញ្ជ្រាបការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ ក្នុងកម្មវិធីអភិវឌ្ឍន៍បច្ចុប្បន្នរបស់គេ។ គោលបំណងនៃដំណើរការនេះ មិនត្រឹមតែជាការកសាងការយល់ដឹងអំពី ប្រធានបទទាំងឡាយនៅគ្របវិស័យពីអ្នកចូលរួមប៉ុណ្ណោះទេ ប៉ុន្តែ ក៏ជាការរៀបចំអ្នកពាក់ព័ន្ធទាំងនោះដើម្បីធ្វើ ទំនាក់ទំនងជាមួយគ្នាក្នុងវេទិកាបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុកម្ពុជា CCCAP ប្រយោជន៍ឲ្យឆន្ទៈ និងការយល់ដឹងរួមគ្នា។ ជាយុទ្ធសាស្ត្រជាស្វ័យប្រវត្តិដ៏សំខាន់សំរាប់ការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ។

ម្យ៉ាងវិញទៀត សំរាប់អ្នកធ្វើសេចក្តីសំរេចចិត្ត , អ្នកធ្វើគោលនយោបាយ អង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិសំខាន់ៗអនុវត្តក្នុងកំរិតជាតិ គប្បីត្រូវមានចំណេះដឹងទូទៅហួសពីខ្លឹមសារទាំងនេះបន្ថែមទៀត ដើម្បីធានាថា ពួកគេត្រូវបញ្ចូលការគាំទ្រផ្នែកគោលនយោបាយ និងការអភិវឌ្ឍប្រកបដោយចិរភាពទៅ គ្របវិស័យទាំងអស់។ ដោយហេតុថាការងារនេះអាចនឹងមានលក្ខណៈជាត្រីវិស័យមួយនោះតំរូវឲ្យមាននូវដំណើរការនៃការបន្តរៀន សូត្រជាហូរហែ និងសិក្ខាសាលាផ្អែកលើមូលដ្ឋានវិភាគមួយចំនួន។

ចលករនៃការកសាងចំណេះដឹងនិមួយៗដែលលើកឡើងខាងលើ គួរតែធ្វើឡើងលើមូលដ្ឋាននៃការប៉ាន់ប្រមាណ ស្ថាប័ន ដោយខ្លួនឯងអំពីសមត្ថភាព និងលទ្ធភាពរបស់គេក្នុងការបញ្ជ្រាបសកម្មភាពបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុទៅក្នុងក្របខ័ណ្ឌនៃស្ថាប័ន និងប្រតិបត្តិការរបស់គេ។ ធ្វើបែបនេះ នឹងជួយនាំយកនូវភាពជាក់លាក់ នៃការកំណត់តំរូវការកសាងសមត្ថភាពក្នុងចំណោមក្រុមអ្នកពាក់ព័ន្ធផ្សេងៗ។ ដើម្បីឲ្យការងារនេះកាន់តែមាន ប្រសិទ្ធិភាព គេគប្បីបង្កើតនូវឧបករណ៍ប៉ាន់ប្រមាណស្ថាប័នដោយខ្លួនឯងសំរាប់ក្រុមអ្នកពាក់ព័ន្ធ និងណែនាំប្រើ ប្រាស់ ឧបករណ៍ទាំងនេះក្នុងពេលដំណាលគ្នាជាមួយការកសាងសមត្ថភាព។ ដំណើរការអនុវត្ត គួរតែផ្អែកទៅតាម ក្រុមអ្នកពាក់ព័ន្ធផ្សេងៗគ្នា ឧទាហរណ៍ ក្រុមប្រឹក្សាគ្រប់គ្រងគ្រោះមហន្តរាយខេត្ត ស្រុក និងឃុំ អង្គការមិនមែនរដ្ឋាភិបាល ជាតិ និងអន្តរជាតិតាមវិស័យផ្សេងៗ និងក្រសួងពាក់ព័ន្ធ ដែលគាំទ្រផ្នែកបច្ចេកទេស ដោយអ្នកប្រតិបត្តិការបន្សាំ ទៅនឹងការប្រែប្រួលអាកាសធាតុប្រកបដោយបទពិសោធន៍មួយក្រុម ដើយតបតាមសំណើពី អ្នកត្រូវការសេវា។ ជាលទ្ធផល តំរូវការកសាងសមត្ថភាពខ្លី ហើយច្បាស់លាស់នឹងត្រូវរកឃើញ ហើយសមត្ថភាព និងជំនាញទាំងឡាយរបស់អ្នកចូលរួមនឹងអាចចែករំលែកគ្នាទៅវិញទៅមក។

ការកសាងសមត្ថភាពដែលសមស្របមួយពិតជាត្រូវការជាចាំបាច់ ហើយការកសាងសមត្ថភាពនេះទៀតសោត គួរធ្វើឡើងក្នុងរបៀបដែលមានការសំរបសំរួល និងត្រឹមត្រូវផ្អែកតាមប្រភពធនធានអ្នកជំនាញផ្ទៃក្នុង។ ធ្វើបែប នេះវាកាន់តែនាំមកនូវរូបភាពកាន់តែច្បាស់បន្ថែមដល់វេទិកា CCCAP ។

គួរមានការឯកភាពគ្នាមួយដើម្បីកសាងនូវ ក្រុមអ្នកសំរបសំរួលដំបូងគេមួយ ធ្វើតួនាទីជាតំណាងវេទិកាហាត់ការ ក្នុងការឆ្លើយតបចំពោះតំរូវការកសាង ចំណេះដឹងទូទៅ–ដែលអ្នកសំរបសំរួលហាត់ការទាំងនោះបន្ទាប់មកអាចក្លាយជាក្រុមការងារបច្ចេកទេសពហុអ្នកពាក់ព័ន្ធ ដោយបង្រួមចូលគ្នានូវតំរូវការសំរាប់ផ្តល់ជំនួយបច្ចេកទេស ឧទាហរណ៏លើប្រធានបទ គ្រប់គ្រងគ្រោះ មហន្តរាយ និងការបន្សុាំទៅនឹងការប្រែប្រួលអាកាសធាតុការបញ្ជ្រាបយេនឌ័រ និងការបន្សុាំទៅនឹងការប្រែប្រួល អាកាសធាតុ និងការវិភាគលើគោលនយោបាយ និងអភិបាលកិច្ចធ្លងវិស័យជាដើម។ ក្នុងបណ្តាសកម្មភាពទាំងនេះក្របខ័ណ្ឌរៀនសូត្រមួយអាចធ្វើឲ្យដំណើរការបាន ដើម្បីបង្កើតជាឫសគល់ក្នុងគោលដៅវេទិកា និងយុទ្ធសាស្រ្ត កសាងសមត្ថភាព ដែលត្រូវគេចាត់ទុកថាជាយុទ្ធសាស្រ្តប្រសើរមួយដោយហេតុថា អ្នកភាគច្រើនចាត់ទុក វេទិកា នេះជាកំលាំង ជំរុញការប្រមូល និងចែករំលែកចំណេះដឹង ប៉ុន្តែអ្វីៗទាំងអស់នេះ នឹងត្រូវធ្វើឡើងក្នុងរបៀបជា "បែបផែនផ្តេរផ្តោះទៅកាន់ការធ្វើឲ្យមានការរៀនសូត្រប្រកបដោយការសហការគ្នានៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

ការចាត់ទុកជាយុទ្ធសាស្រ្តនូវរបៀបកសាងសមត្ថភាពបន្សុាំសំរាប់តំរូវការ ប្រមូលចំណេះដឹងត្រូវបានរកឃើញ មិន ថាជាតំរូវការផ្នែកចំណេះដឹងជាក់លាក់ ឬចំណេះដឹងទូទៅមួយឡើយដោយសារវាហាក់ដូចជាឆាប់ពេកក្នុងការ កំណត់វានាដំណាក់កាលនេះដើម្បីសំរេចគោលដៅនេះ គេអាចចាប់ផ្តើមដោយការកំណត់តំរូវការដើម្បី ទី១ កសាងជំនាញអ្នកស្រាវជ្រាវ ដើម្បីធ្វើការស្រាវជ្រាវ និងសំរបសំរួលនូវការយកទៅអនុវត្តលទ្ធផលស្រាវជ្រាវ ដែលសមស្របមួយ។ ទី ២ ដោយសំអាងលើទស្សនៈដែលថា មិនទាន់មានការយល់ដឹងគ្រប់គ្រាន់នៅឡើយអំពី របៀបដែល "អ្នកពាក់ព័ន្ធនៅមូលដ្ឋាន" ត្រូវធ្វើសកម្មភាពជាមួយរបៀបកសាងចំណេះដឹង និងលទ្ធផលរបស់វា សិក្ខាសាលាបណ្តុះបណ្តាលរួមគ្នាដើម្បីកសាងចំណេះដឹងបែបផ្លាស់ប្តូរ និងការអនុវត្តដំណើរការដែលស្នើឡើងដើម្បីធានាឲ្យមាន ១. វិធីសាស្រ្តចូលរួមក្នុងការបញ្ជ្រាបយេនឌ័រ ២. វិធីសាស្រ្តចូលរួមក្នុងការចលនាសហគមន៏ និងទី ៣ វិធីសាស្រ្តដើម្បីបញ្ចូល និងវិភាគលើបណ្តាញសង្គម និងស្ថាប័នក្រៅផ្លូវក្នុងការបន្សុាំទៅនឹងការប្រែប្រួលអាកាស ធាតុ។ ជាថ្មីម្តងទៀតយុទ្ធសាស្រ្តនេះត្រូវការឲ្យមានការអនុវត្តផ្ទាល់និងបង្កើតរួមគ្នានូវចំណេះដឹងទាំងឡាយជា កំលាំងជំរុញទៅកាន់តំរូវការដ៏ធំធេង។

ដើម្បីយល់ដឹងកាន់តែច្បាស់លើបរិបទចំណេះដឹងដាក់លាក់នៅកម្ពុជា នោះយុទ្ធសាស្រ្ត ដែលត្រូវអនុវត្ត នឹងតំរូវឲ្យមានការគាំទ្រផ្នែកថវិកា ដើម្បីអនុវត្តគំរោងស្រាវជ្រាវសកម្ម ខ្នាតតូចៗមួយ ចំនួនដែលមានគោលដៅក្នុងការផ្តល់នូវមាិគាអំពីរបៀបកសាងសមត្ថ ភាពប្រើប្រាស់ ជាឯកទេសសំរាប់ផ្នែក ដាក់លាក់ និងឆ្លងវិស័យ ដាក់ស្តែងបានយកចិត្តទុក ដាក់សំខាន់ដល់អ្នកប្រើប្រាស់ចុងក្រោយ។

ទាក់ទងនឹងការបំពេញកង្វះខាតផ្នែកចំណេះដឹងអំពីការបន្សុាំទៅនឹងការប្រែប្រួលអាកាសធាតុ ឧទាហរណ៏ គំរូធាតុ អាកាស និងអាកាសធាតុ ជាដើមមិនត្រូវបានគេចាត់ទុកថា ជាចំណេះដឹងថ្មីដែលត្រូវការបង្កើត ប៉ុន្តែ វាគ្រាន់តែជា ឱកាសដើម្បីទទួលបាននូវបទ ពិសោធន៏ប្រមូលនូវចំណេះដឹង និងប្រព័ន្ធដែលប្រើប្រាស់ក្នុងតំបន់ដែល "ប្រហាក់ ប្រហែលគ្នា"–ហើយបន្ទាប់មកសំរបទៅតាមតំរូវការរបស់កម្ពុជា។ដើម្បីសំរេចការងារនេះ គេគ្រាន់តែរៀបចំការផ្លាស់ប្តូរដំណើរទស្សនកិច្ច និងណែនាំគ្នាទៅវិញទៅមកក្នុងចំណោ មក្រសួងពាក់ព័ន្ធ ឧទាហរណ៏ ការផ្លាស់ប្តូរ ទស្សនកិច្ចគ្នា រវាងភាគខាងត្បូងទៅភាគ ជើង និងពីភាគខាងត្បូងដូចគ្នា។ អ្វីដែលគួរចងចាំ គឺថា តំរូវការដើម្បីនាំយកចំណេះ ដឹងដែលទទួលបាន ទៅអនុវត្តនៅមូលដ្ឋានគួរតែជាការទទួលខុសត្រូវរួមគ្នាក្នុងបណ្តា អ្នកចូលរួមទាំងអស់។ ប្រការទាំងឡាយដែលលើកឡើងខាងលើ គ្រាន់តែជារបៀបអនុវត្ត ដែលជាក់លាក់ទៅនឹងឧទាហរណ៏ដែលផ្តល់ នោះប៉ុណ្ណោះ ពោលគឺមួយចំណែកធំនៃកា បំពេញកង្វះខាតផ្នែកចំណេះដឹងទាក់ទងនឹងការបន្សុាំទៅនឹងការប្រែ ប្រួលអាកាសធាតុ វាស្ថិតនៅលើរបៀបដែលចំណេះដឹងទាំងនោះត្រូវរៀបចំបង្កើត។ តាមទស្សនៈយុទ្ធសាស្រ្ត ការ កសាងសមត្ថភាពអាចធ្វើឡើងដោយការបង្កើនកំរិតនៃការចូលរួមប្រកបដោយ អត្ថន័យក្នុងចំណោម "អ្នកស្រាវ ជ្រាវ" និង "ខ្ទឹមសារស្រាវជ្រាវ"។ គេអាចសំរេចរឿង នេះតាមការលើកទឹកចិត្ត ,ពង្រឹងការអភិវឌ្ឍគោលការណ៏ ណែនាំអំពីការផ្តល់ជំនួយក្នុង ចំណោម "អ្នកផ្តល់ជំនួយ" និងសហគមន៏"អ្នកស្រាវជ្រាវ" ដើម្បីបញ្ជូលតំរូវការជាយុទ្ធ សាស្រ ដោយផ្អែកលើរបៀបដែលស្ថាប័នទាំងនោះ បញ្ជូល និងបំពេញនូវតំរូវការបង្កើត ចំណេះដឹង ការកសាង សមត្ថភាព និងផលដែលបានពីការចូលរួមរបស់ក្រុមអ្នកពាក់ព័ន្ធ និងភាពអាចប្រើប្រាស់បាននៃចំណេះដឹងជាក់ ស្តែង។ តាមស្មារតីនេះ វានឹងជួយបង្កើន នូវប្រសិទ្ធភាពនៃបណ្តាញ និងក្របខ័ណ្ឌនៃការរៀនសូត្រផ្នែកសង្គម_ដែល បន្ថែមទៅ លើទស្សនៈរៀបរយមួយអំពីវេទិកាបន្សុាំទៅនឹងការប្រែប្រួលអាកាសធាតុសំរាប់កម្ពុជា។

ដើម្បីសំរេចនូវយុទ្ធសាស្ត្រសមស្របមួយក្នុងការបំពេញ កង្វះខាតផ្នែកប្រព័ន្ធ ទាក់ទងនឹងការបន្សុាំទៅនឹងការប្រែ ប្រួលអាកាសធាតុ អាចជារឿងស្មុគ្រស្មាញមួយ ដោយសារវាជាតំរូវការក្នុងវិស័យជាក់លាក់ ឆ្លងកាត់គ្របវិស័យ និងជាចំណុចចាប់ផ្តើមនៃការកសាងសមត្ថភាព (សូមមើលសេចក្តីលំអិតជាក់លាក់នៅឧបសម្ព័ន្ធ ៣)។ វាច្បាស់ណាស់ថាវាពុំមែនជាសេនារីយូដែលមានតែមួយ។ ជាទូទៅ សំរាប់កង្វះខាតផ្នែកប្រព័ន្ធដែលតំរូវឲ្យមានការរួម បញ្ចូលគ្នាពីគ្របវិស័យជាក់លាក់នូវចំណេះដឹង និងសកម្មភាព ផែនការយុទ្ធសាស្ត្រសកម្មភាពជាតិ ត្រូវបានគេចាត់ ទុកថាជាចំណុចដែលសមទំនងបំផុត ដែលយុទ្ធសាស្ត្រកសាងសមត្ថភាព អាចធ្វើជាមូលដ្ឋានសំរាប់ផ្តើមផែនការ និងអនុវត្ត។ ធ្វើបែបនេះអាចឲ្យយើងបាននាំយកនូវការគាំទ្រប្រើប្រាស់ក្រុមការងារបច្ចេកទេស ដើម្បីសំរបសំរួលការរួបញ្ចូលគ្នានៃតំរូវការរបស់ផ្នែកផ្សេងៗ តាមរយៈសិក្ខាសាលាបច្ចេកទេសដើម្បីកំនត់រកការផ្តល់យោបល់ ឧទាហរណ៍ ដោយធ្វើទិន្នន័យប្រដូច និងការរៀបចំការរៀនសូត្រ ដោយអនុវត្តនៅកន្លែងដើម្បីឆ្លើយតបគោល បំណងងាយស្រួលអនុវត្ត។ ខណៈពេលដែលក្រុមការងារបច្ចេកទេស បំពេញការងាររបស់ខ្លួនជាមួយផ្នែកផ្សេងៗក្នុងនាមជាគ្រូបណ្តុះបណ្តាល និងជាអ្នកផ្តល់ការណែនាំ ឧទាហរណលើការកាត់បន្ថយគ្រោះមហន្តរាយ ឬលើវិស័យ កសិកម្ម និងធនធានទឹកនោះតំរូវការកសាងសមត្ថភាពបន្ថែមទៀតអាចនឹងត្រូវកំណត់បានជាក់លាក់ និងរកយុទ្ធ សាស្ត្រឆ្លើយតបជាបន្តបន្ទាប់។ គំនិតដូចពោលមកនេះធ្វើឡើង ជាមួយនឹងគំនិតតូចៗសំរាប់ការបញ្ចូលគ្នាហើយ ប្រើប្រាស់ជាយន្តការនៃការរៀនសូត្រ ហើយឆ្លើយតបចំពោះតំរូវការប្រតិបត្តិ និងការពង្រីកវិសាលភាព។

កង្វះខាតផ្នែកប្រព័ន្ធជាអាទិភាពដែលបានរំលេចឲ្យឃើញនោះគឺ តំរូវការដើម្បីឲ្យមានដំណើរការជាប្រព័ន្ធ នៃការ វិភាគទិន្នន័យគ្របវិស័យ ការធ្វើផែនការ និងការអនុវត្តនូវគំនិតផ្តួចផ្តើម និងការចែករំលែកចំណេះដឹងអំពី ការបន្សុាំទៅនឹងការប្រែប្រួលអាកាសធាតុ។ ដោយហេតុថា វាជាតំរូវការទូទៅមួយនាពេលបច្ចុប្បន្ននេះ និងម្យ៉ាង វិញទៀត វាមិនទាន់បានធ្វើឡើងក្នុងរបៀបជាក់លាក់ជាគោលការណ៍វាជាតួនាទីនិងការទទួលខុសត្រូវរបស់នាយកដ្ឋានប្រែប្រួលអាកាសធាតុ នៃក្រសួងបរិស្ថានដើម្បី រៀបចំបង្កើតនិងថែរក្សារបនាសម្ព័ន្ធទាំងនេះ។

ដើម្បី ធានាឲ្យមានការរៀនសូត្រពីគ្នាក្នុងចំណោម “សហគមន៍អ្នកបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ” គេអាច បង្កើតគេហទំព័រដែលប្រើសំរាប់ការទំនាក់ទំនងគ្នារវាងនាយកដ្ឋានប្រែប្រួលអាកាសធាតុ និងវេទិកាបន្សាំទៅនឹង ការប្រែប្រួលអាកាសធាតុ – រំលេចឲ្យឃើញនូវការបង្កើតឡើងនូវគោលការណ៍ណែនាំ និងវិធីសាស្ត្រដាក់បញ្ចូលគ្នានូវការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុពីគ្របវិស័យការស្នើ និងអនុម័តគំនិតដាក់បន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ និងការប៉ាន់ប្រមាណផលប៉ះពាល់ផ្នែកបរិស្ថានផ្សេងៗទៀត។ល។ ប៉ុន្តែ តើនេះពិតជាគ្រប់គ្រាន់ ហើយឬនៅ?

ដោយផ្តើមចេញពីការបង្កើតឲ្យមានផលផ្លែផ្កានៃការបញ្ជ្រាបវិស័យបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុជាមួយនឹងទស្សនៈនៃគោលការណ៍អភិវឌ្ឍន៍ប្រកបដោយចិរភាពដូចជាសមធម៌នៃការចិញ្ចឹមជីវិត និងសមធម៌យេនឌ័រ ជាដើម ដែលរឿងនេះក៏ត្រូវបង្កើតយុទ្ធសាស្ត្រកសាងសមត្ថភាពបន្សាំស្រដៀងគ្នាទៅនឹងយុទ្ធសាស្ត្រទាំងឡាយ ដែលបានលើកឡើងខាងលើ ទោះជាយ៉ាងនេះក្តី គេបានគិតថាការធ្វើបែបនេះ តំរូវឲ្យមានការអនុវត្តវិធីសាស្ត្រ រៀនសូត្រ តាមរបៀបផ្ទេរចំណេះដឹងដល់ពហុអ្នកពាក់ព័ន្ធធ្វើឡើងនៅ “មូលដ្ឋាន” ឧទាហរណ៍ការកសាងសមត្ថភាពរួមគ្នាដែលដឹកនាំដោយក្រុមអ្នកសំរបសំរួលដោយរួមសហការជាមួយស្ថាប័ននៅថ្នាក់ខេត្ត និងថ្នាក់ឃុំ ជាទី ដែលការបញ្ជ្រាប តំរូវការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុត្រូវប្រែក្លាឲ្យទៅជាស្ថាប័ន។

បើគេពិនិត្យមើលក្នុងបរិបទនៃការបញ្ជ្រាបការគ្រប់គ្រងគ្រោះមហន្តរាយ ទៅគ្របវិស័យទាំងអស់ នោះយុទ្ធ សាស្ត្រនៃការកសាងសមត្ថភាពណាមួយ ដែលត្រូវអនុវត្ត គួរចាប់ផ្តើមដោយធ្វើឲ្យប្រាកដថា ក្នុងបណ្តាអ្នកពាក់ ព័ន្ធទាំងអស់ទទួលបានចំណេះដឹងទូទៅអំពីការសំរាលហេតុនាំឲ្យមានការប្រែប្រួលអាកាសធាតុ និងទស្សនាទានបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ ក្របខ័ណ្ឌយុទ្ធសាស្ត្រ និងសកម្មភាព។ ប្រការនេះអាចសំរេចបានតាមការ អនុវត្តនូវវេទិកាចែករំលែកចំណេះដឹង និងការរៀនសូត្រមួយចំនួននៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ។

វេទិកាវៀន សូត្រទាំងនេះក៏គួរតែមានរួមបញ្ចូលនូវការចែករំលែកបទពិសោធន៍ដែលកំពុង បន្ត និងគំនិតច្នៃប្រឌិតទាំងឡាយនៅ ក្នុងប្រទេស និងនៅថ្នាក់តំបន់។ វេទិកាទាំងនោះ ក៏អាចធ្វើនៅក្នុងសិក្ខាសាលាខ្នាតមធ្យម ដែលធ្វើឡើងដើម្បីសាកល្បងគំរោងរៀនសូត្រ អំពី ការគ្រប់គ្រងគ្រោះមហន្តរាយ_បន្សាំទៅនឹងការប្រែប្រួលអាកាសធាតុក្នុងចំណោម អ្នកពាក់ព័ន្ធ ដែលចង់ច្នៃប្រឌិតក្នុងទស្សនាទាននេះ ឧទាហរណ៍ អំពីរបៀបដែលការចូល រួមពហុភីរតត្រូវផ្ទះបញ្ចាំង និងរបៀបដែល បច្ចេកទេស និងឧបករណ៍ថ្មីៗត្រូវធ្វើឲ្យត្រូវនឹង តំរូវការអ្នកប្រើប្រាស់។ មធ្យោបាយមួយនៃការគាំ ទ្រដំណើរការសកម្មភាពនេះ –ពោល គឺគំនិតច្នៃប្រឌិត –និងការបន្តរៀនសូត្រ គឺត្រូវធានាថា គំនិតផ្តួចផ្តើមទាំង ឡាយអំពីការ "គ្រប់គ្រងគ្រោះមហន្តរាយ_ការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ"ទទួលបាននូវការ ជួយឧបត្ថម្ភផ្នែកថវិកាពីថ្នាក់ខេត្ត និងស្រុក–ដែលជាភារៈកិច្ចផ្នែកស្ថាប័ន។

គេអាចកត់សំគាល់ឃើញថា ដំណើរការទាំងឡាយដូចដែលបានបរិយាយខាងលើសំដៅ ទទួលយកចំណេះដឹងមូល ដ្ឋាន ការគៀងគរចំណេះដឹងតាមការចែករំលែក និងរៀនពីការ អនុវត្ត និងការលើកដំកើងគំនិតច្នៃប្រឌិតទាំងឡាយ តាមការផ្តល់ដំបូន្មាននិងការគាំទ្រ ថវិកាជាស្ថាប័ន ជាថ្មីម្តងទៀត ត្រូវបានអ្នកចូលរួមក្នុងសិក្ខាសាលាចាត់ទុកជាយុទ្ធសាស្ត្រ កសាងសមត្ថភាព ជាជំរើសក្នុងការបំពេញកង្វះខាតផ្នែកប្រព័ន្ធអ្វីដែលខុសពីនេះ គឺ ចំណុចចាប់ផ្តើម ដូចដែលបានលើកឡើងក្នុងឧទាហរណ៍មុនៗថាវាប្រហែលជាកត្តា សំរបសំរួលជាគន្លឹះមួយ។ ដើម្បីសបញ្ជាក់បន្ថែម ចំពោះឧទាហរណ៍ទីពីរខាងលើ បើការកសាងសមត្ថភាពធ្វើឡើង សំដៅធានាការបញ្ជ្រាបបញ្ហាយេនឌ័រទៅក្នុង គំនិត បន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ ថាជាកង្វះខាតផ្នែកប្រព័ន្ធដែលត្រូវបំពេញ នោះអ្វីដែលត្រូវផ្លាស់ប្តូរ គឺគោលការណ៍ ដែលអ្នកសំរបសំរួល, ក្រុមការងារបច្ចេកទេ ត្រូវសំអាងលើចំណេះដឹងនៃអ្នកមូលដ្ឋាន និង ចំណែកពាក់ព័ន្ធរបស់ពួកគេជាមួយតំរូវ ការនៃការបញ្ជ្រាប។ ក្នុងករណីនេះ យើងសូមផ្តល់អនុសាសន៍ថា គំនិត បញ្ជ្រាបទាំង ឡាយគួរធ្វើឡើងដោយដឹកនាំរួមគ្នាដោយសហគមន៍អង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ រួមសហការ ជាមួយអាជ្ញាធរខេត្ត ស្រុក និងគណៈកម្មការយេនឌ័រឃុំ ក្នុងនោះមាន សមាសភាពពហុអ្នកពាក់ព័ន្ធក្នុងក្រុមការងារ បច្ចេកទេសជាដើម។ ប៉ុន្តែ គេត្រូវចំណាំ ផងដែរថា ដើម្បីរក្សាការអនុវត្តដែលរហ័សរហួន និងសមស្រប គេគប្បី ធានា ឲ្យមានការ រួមបញ្ចូលគ្នា និងបញ្ជ្រាបទៅគ្រប់វិស័យទាំងអស់ជាពហុភាពនៃអ្នកជំនាញមកពីផ្នែក ផ្សេងៗគ្នា។

ដើម្បី ជំរុញការរៀនសូត្រ និងនវានុវត្តថ្មីៗ -ដោយហេតុថា ទស្សនៈពីគ្រប់វិស័យតែងតែត្រូវគេចាត់ទុកថាជា ប្រការដ៏ល្អមួយ ក្នុងការកសាងក្រុមអ្នកសំរបសំរួល។ ហើយដូចដែលបានលើកឡើងខាងលើ –ការភ្ជាប់ទំនាក់ ទំនងចែករំលែក ព័ត៌មានត្រូវតែជាភាពចាំបាច់ ហើយដែលត្រូវផ្តល់ការគាំទ្រទាំងស្មារតី និងថវិកា។ ការរួមបញ្ចូល គ្នានូវមនុស្សនិងបច្ចេកវិទ្យាព័ត៌មានត្រូវបានគេមើលឃើញថាជាតួនាទីសមស្រប និងយុទ្ធសាស្រ្តបំផុតសំរាប់ វេទិកាបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ។ដើម្បីជំរុញការរៀនសូត្រនិងនវានុវតថ្មីៗ-ដោយហេតុថា ទស្សនៈពីគ្រប់វិស័យតែងតែត្រូវគេចាត់ទុកថាជា ប្រការដ៏ល្អមួយ ក្នុងការកសាងក្រុមអ្នកសំរបសំរួល។ ហើយដូចដែលបានលើកឡើងខាងលើ_ការភ្ជាប់ទំនាក់ទំនងចែករំលែក ព័ត៌មានត្រូវតែជាភាពចាំបាច់ ហើយដែលត្រូវផ្តល់ការគាំទ្រទាំងស្មារតី និងថវិកា។ ការរួមបញ្ចូល គ្នានូវមនុស្ស និងបច្ចេកវិទ្យាព័ត៌មានត្រូវបានគេមើលឃើញថាជាតួនាទីសមស្រប និងយុទ្ធសាស្រ្តបំផុតសំរាប់ វេទិកាបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ។

ការធ្វើឲ្យដំណើរការកសាងសមត្ថភាពបន្សាំទៅជាយុទ្ធសាស្រ្តសំរាប់បំពេញកង្វះខាតផ្នែករចនសម្ព័ន្ធ ដែលត្រូវ ការដើម្បីសំរបសំរួលការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុគ្រាន់តែជាដំណើរការទៅមុខត្រង់មួយ ដែលគេ អាចផ្តើមចេញដំណើរជាមួយនឹងការកសាងសមត្ថភាពគ្រប់គ្រងហិរញ្ញវត្ថុ និងភស្តុភា។ ដោយសារ កង្វះខាតចំបង ដែលត្រូវបំពេញមានទាក់ទងទៅនឹងទីកន្លែង អង្គភាពដែលរចនសម្ព័ន្ធទាំងនេះស្ថិតនៅជាចំណុះ -ត្រូវបានគេយល់ ថាជាចំណុចសំរបសំរួលកណ្តាល និងជាបន្តបន្ទាប់មកទៀត រចនាសម្ព័ន្ធនៅថ្នាក់ខេត្ត (មណ្ឌលមូលដ្ឋាន) ដែលសមស្របសំរាប់ការអនុវត្តជំនាញ និងសមត្ថភាពនៃរចនាសម្ព័ន្ធដែលមានស្រាប់ចំពោះប្រធានបទដែលជាប់ទាក់ទងឧទហរណ៏ នាយកដ្ឋានប្រែប្រួលអាកាសធាតុកម្ពុជា។ បើទោះជា ដំណើរការនោះជាដំណើរការត្រង់មួយក៏ដោយ វាពិតជាតំរូវឲ្យមានការបង្កើតគណៈកម្មាធិការនាំមុខចូលរួមពីពហុអ្នកពាក់ព័ន្ធបណ្តោះអាសន្នមួយ ដើម្បី សំរបសំរួលការបង្កើតគោលការណ៏ណែនាំ និងគោលនយោបាយប្រតិបត្តិ។ អ្វីដែលសំខាន់ និងដែលមានការលើក ឡើងជាញឹកញាប់គឺ "សហគមន៏ចាប់អារម្មណ៏ចំពោះការប្រែប្រួលអាកាសធាតុ" ចង់ស្ថិតនៅជិតជាមួយ នាយកដ្ឋាន ប្រែប្រួលអាកាសធាតុ បើទោះជាគេបំពេញតួនាទីគ្រាន់តែជាអ្នកគាំទ្រក៏ដោយ..

ជាយុទ្ធសាស្រ្តជាស្វ័យប្រវត្តិដ៏សំខាន់សំរាប់ការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ។

–ដែលនេះបង្ហាញពីសារៈសំខាន់ នៃការនាំយកអភិបាលកិច្ច គោលនយោបាយនិង សកម្មភាពអនុវត្តឲ្យកៀកជាមួយអ្នកទទួលផលដោយហេតុថាវេទិកាស្តីពីការបន្សុាំទៅនឹង ការប្រែប្រួលអាកាសធាតុពហុអ្នកពាក់ព័ន្ធចំណុះក្នុងនាយកដ្ឋានប្រែប្រួលអាកាសធាតុ ទទួលបានការឧបត្ថម្ភ និងពង្រឹងសមត្ថភាពដោយគណៈកម្មការអ្នកតំណាងអ្នកពាក់ព័ន្ធ –ក្នុងពេលជាមួយគ្នានេះបាននាំយកភាពស្ទាត់ជំនាញ សកម្ម និងតួនាទីដែលផ្តល់សារៈ សំខាន់លើមនុស្ស ចូលទៅកាន់នាយកដ្ឋានប្រែប្រួល អាកាសធាតុ។ គេគិតថា ជាដំបូង ការបញ្ចូលវេទិកានេះ ទៅក្នុងរចនាសម្ព័ន្ធរបស់នាយកដ្ឋានគួរមានការឧបត្ថម្ភ ពីអ្នកខាង ក្រៅ ហើយក្រោយមកទៀត មូលនិធិ ,ការឧបត្ថម្ភធនពីខាងក្នុង តាមរយៈការផ្តល់សេវា ដល់អតិថិជន (មើលឧបសម្ព័ន្ធ ៤ សំរាប់សកម្មភាពកសាងសមត្ថភាពពិស្តារ)។

យុទ្ធសាស្ត្រកសាងសមត្ថភាពដើម្បីបំពេញ កង្វះខាតផ្នែកគោលនយោបាយ ដែលគាំទ្រ ដល់ការបន្សុាំទៅនឹងការ ប្រែប្រួលអាកាសធាតុ អាចធ្វើទៅបាន ដោយប្រើប្រាស់ផែន ការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ជាច្រកចាប់ផ្តើម និង ប្រហែលជាចំណុចផ្តើមយ៉ាងល្អក្នុងការ ធ្វើឲ្យទៅជាការអនុវត្តផ្នែកស្ថាប័ននូវក្របខ័ណ្ឌច្បាប់បន្សុាំ សំរាប់បន្តការឆ្លើយតបផ្នែក គោលនយោបាយ ចំពោះសេនារីយ៉ូប្រែប្រួលអាកាសធាតុ និងការអភិវឌ្ឍ។ ដើម្បីឈាន ដល់ចំណុច នេះ គេតំរូវឲ្យការសំរេចចិត្ត ក៏ដូចជាអ្នកធ្វើគោលនយោបាយដឹកលំឲ្យបាន ខ្ពស់នូវការយល់ដឹងអំពីបញ្ហាប្រឈមទាំងឡាយដែលចោទលើការបន្សុាំទៅនឹងការប្រែ ប្រួលអាកាសធាតុ ការសំរាលហេតុនាំឲ្យមានការប្រែប្រួល អាកាសធាតុ និងការសំរាល ផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ។ ជាញឹកញាប់មានការលើកឡើងដោយអ្នកចូល រួមក្នុងសិក្ខាសាលាថា “យើងត្រូវតែធ្វើឲ្យបានត្រឹមត្រូវបំផុតពីដំបូង”–ដោយសង្កត់ធ្ងន់ថា ការគាំទ្រផ្នែកគោលនយោបាយជាគន្លឹះមួយឈានទៅសំរេចជោគជ័យនេះ។ដោយហេតុថា ដើម្បីអនុវត្ត គេគប្បីដឹកនាំការបណ្តុះ បណ្តាលអ្នកពាក់ព័ន្ធសំខាន់ៗអំពីដំណើរការ និង ប្រើប្រាស់ការលើកកំពស់ការយល់ដឹង និងសកម្មភាពជ្រុះបញ្ច្រាំង ដែលមានជាប់ជាមួយ នូវការអនុម័តក្របខ័ណ្ឌច្បាប់ដាក់បន្សុាំមួយនោះ ទើបគេត្រូវការឲ្យមានគោលនយោបាយ មួយដែលអាចត្រួតពិនិត្យ និងកែតំរូវការគាំទ្រការបន្សុាំទៅនឹងការប្រែប្រួលអាកាសធាតុ ហើយប្រហែលជាការរៀបបញ្ចូលគ្នានៃវេទិកាបន្សុាំពហុអ្នកពាក់ព័ន្ធមួយចំណុះនាយក ដ្ឋានប្រែប្រួលអាកាសធាតុ (មើលឧបសម្ព័ន្ធ ៥ សំរាប់តំរូវការ និងដំណើរការពិស្តារ)។

គេគួរកត់សំគាល់ថា ការកសាងសមត្ថភាពដូចដែលបានលើកឡើងខាងលើអាចធ្វើទៅបានដោយ ទី១ ធ្វើឲ្យមាន ការអនុវត្តជាស្ថាប័ននូវយន្តការត្រួតពិនិត្យ និងកែលំអប្រកបដោយការចូលរួមសំរាប់ការផ្តួចផ្តើមគំនិតបន្សុាំទៅ នឹងការប្រែប្រួលអាកាសធាតុស្ថិតក្នុងផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ និងទី ២ ដំណើរការពិនិត្យមើលឡើងវិញ ជាដៃគូដែលលើកកំពស់ការរៀនសូត្រជាយុទ្ធសាស្រ្ត ឧទាហរណ៍ ដោយជំរុញការសំរេចចិត្ត និងអ្នកធ្វើគោលនយោ បាយក្នុងការរៀបចំ និងអនុវត្តគំរោងជាគំរូអំពីការបន្សុាំទៅនឹងការប្រែប្រួលអាកាសធាតុ –ពោលគឺមិនមែនគ្រាន់ តែធ្វើទស្សនកិច្ចទៅមូលដ្ឋានគំរោង ដូចដែលធ្លាប់ធ្វើកន្លងមកទេ។ ការចូលរួមដ៏សកម្មនេះ អាចធ្វើឲ្យទៅជាប្រព័ន្ធ មួយក្នុងអាណត្តិរបស់ក្រសួងពាក់ព័ន្ធជាមួយនឹងតួនាទីជាគន្លឹះដែលផ្តល់ឲ្យដល់បណ្តារដ្ឋមន្រ្តី មន្រ្តីរាជការជាន់ខ្ពស់ និងសហគមន៍មូលដ្ឋានប្រកបដោយសមធម៌–ពោលគឺវាមានជាប់ទងយ៉ាងមានប្រសិទ្ធិភាព រវាងមនុស្សជាមួយ គោលនយោបាយ។ តាមរយៈនេះ ដំណើរការដូចដែលបានលើកឡើង គួរតែប្រើប្រាស់ផងដែរដើម្បីធ្វើឲ្យមានភាព រឹងមាំនូវគំរូវការផ្អែកឆន្ទៈដើម្បីធ្វើការសំរេចចិត្តផ្អែកលើទិន្នន័យស្រាវជ្រាវ និងការអនុវត្តជាស្ថាប័ននៃយន្តការត្រួតពិនិត្យ និងកែតំរូវដោយមានការចូលរួមពីពហុអ្នកពាក់ព័ន្ធ លើលទ្ធផល–ឥទ្ធិពលនៃការប៉ាន់ប្រមាណផ្អែក គោលនយោបាយ និងការសំរេចចិត្តអំពីអភិបាលកិច្ចផ្ទៃក្នុង។

អ្វីដូចពោលខាងលើ មិនមែនជាដំណើរការដែលងាយស្រួលអនុវត្តជាស្ថាប័ននោះទេដើម្បីសំរេចជោគជ័យ គេត្រូវមានការកសាងសមត្ថភាពជំនាញដល់គ្រប់អ្នកពាក់ព័ន្ធទាំងអស់ ដើម្បីធានាថា ការអនុវត្តពហុអ្នកពាក់ព័ន្ធធ្វើឡើង ប្រកបដោយសមធម៌មានអត្ថន័យ និងផ្អែកលើលទ្ធផល។ ដំណើរការនៃការអនុវត្តកសាងសមត្ថភាពដើម្បីធានាចំពោះស្ថានភាពនេះគេគួរធ្វើឡើងក្នុងរូបភាពជាវេទិកាបន្សុាំ –ដែលវេទិកានេះត្រូវចាត់ទុកថាជាកន្លែងកសាង សមត្ថភាពដល់អ្នកពាក់ព័ន្ធទាំងអស់ដើម្បីធានាឲ្យមានការយល់ថា "វាជាកន្លែង"មួយ ដូចនេះ វេទិកាបន្សុាំត្រូវ ការថវិកាគាំទ្រពីខាងក្នុង និងពីខាងក្រៅដើម្បីសំរបសំរួលតំរូវការកសាងសមត្ថភាព ក៏ដូចជាការឧបត្ថម្ភថវិកា ដល់ការពិនិត្យមើលឡើងវិញលើលទ្ធផល–ឥទ្ធិពលគោលនយោបាយលើអ្នកពាក់ព័ន្ធជាប្រចាំ ដើម្បីជៀសវាងការ រងសំពាធ ពីក្រុមពិសេសណាមួយ និងការរំខានផ្សេងៗចំពោះតំរូវការឲ្យមានតំលាភាព។

គេក៏ត្រូវកត់សំគាល់ផងដែរថា គោលនយោបាយទាំងឡាយពិតជាត្រូវការ ដើម្បីគាំទ្រដល់ការរួមបញ្ចូលផែនការ បន្សុាំទៅនឹងការប្រែប្រួលអាកាសធាតុក្នុងផែនការអនុវិស័យនានា រួមមានដូចជា ជលផល និងវារីវប្បកម្មទៅ ក្នុងកម្មវិធីសកម្មភាពជាតិដើម្បីបន្សុាំទៅនឹងការប្រែប្រួលអាកាសធាតុ និងវិស័យគ្រប់គ្រងធនធានធម្មជាតិទៅក្នុង គោលនយោបាយ ក្របខ័ណ្ឌផែនការ និងការផ្តួចផ្តើមគំនិតទាំងឡាយដើម្បីឆ្លើយតបចំពោះគ្រោះមហន្តរាយ។ អនុសាសន៍ សំរាប់យុទ្ធសាស្រ្តបំពេញកង្វះខាតផ្នែកគោលនយោបាយនេះ ទី ១ កំណត់ឲ្យបានច្បាស់នូវសកម្មភាព ជាយុទ្ធសាស្រ្តថ្នាក់ជាតិ ឬផែនការអភិវឌ្ឍន៍ទាំងឡាយទុកជាប្រកបចូលមួយក្នុងការបំផុសការទំនាក់ទំនងគ្នា និង ទាក់ទាញយកនូវការគាំទ្រសំរាប់ការកសាងសមត្ថភាព។ ការឧបត្ថម្ភផ្នែកថវិកា នឹងត្រូវការជាចាំបាច់ដើម្បីផ្តោត ការប៉ាន់ប្រមាណការកសាងសមត្ថភាព និងបំពេញតំរូវការដែលកំនត់ ឧទាហរណ៏ តំរូវការដើម្បីភ្ជាប់ទំនាក់ទំនង មនុស្ស និងគោលនយោបាយ តាមរយៈគំរោងបង្ហាញ និងដើម្បី សំរបសំរួលសកម្មភាពផ្នែកច្បាប់ដូចដែលបាន បរិយាយខាងលើ។ គេក៏ត្រូវសំគាល់ផងដែរថា មិនមែនគ្រប់កង្វះខាតផ្នែកគោលនយោបាយទាំងអស់សុទ្ធតែ ត្រូវ ធ្វើអន្តរាគមន៏ដោយរដ្ឋាភិបាលនោះទេ។ ពិព្រោះ ករណីភាគច្រើននៃសិក្ខសាលាដោយមានការចូលរួមត្រូវសំរបសំរួលដោយ “វេទិកា” អាចជួយក្នុងការបង្កើតនូវក្របខ័ណ្ឌកិច្ចសហការរវាងភាគីពាក់ព័ន្ធ និងវិស័យផ្សេងៗ និង រវាងបណ្តាញ និងវេទិកា “ស្តីពីការប្រែប្រួលអាកាសធាតុទាំងអស់”។ ដោយហេតុថា មានការលើកក្នុងសិក្ខាសាលា ពិគ្រោះយោបល់ថា គោលនយោបាយមួយមិនប្រាកដជាត្រូវការដើម្បីធានាឲ្យកិច្ចការសំរេចបានត្រឹមត្រូវនោះទេហើយក៏មិនប្រាកដថាអាចទទួលបានលទ្ធផលដូចដែលសង្ឃឹមទុកដែរ ប៉ុន្តែ វាពិតជាជួយធានាថាសមត្ថភាពដែល ទទួលបានពិតជាបានប្រើប្រាស់ជាបណ្តើរៗ។ ដើម្បីសំរេចកិច្ចការនេះ សូមស្នើឲ្យមានដំណើរការដើម្បីឆ្លុះបញ្ចាំង តំរូវការសំរាប់កសាងសមត្ថភាពក្រុមអ្នកពាក់ព័ន្ធអំពីគោលនយោបាយ និងការតស៊ូមតិគោលនយោបាយ_មែន យើងពិតជាត្រូវការសិក្ខាសាលា គំរោងស្រាវជ្រាវដោយមានការចូលរួមធ្វើសកម្មភាពបន្ថែមទៀតសំរាប់ “វេទិកា” នេះ។

## ៤.៣ បង្កើតវេទិកាស្តីពីការបន្សុាំទៅនឹងការប្រែប្រួលអាកាសធាតុ

មានការស្នើយោបល់ជាច្រើនទាក់ទងទៅនឹងការអភិវឌ្ឍយន្តការជាស្ថាប័នសំរាប់ការប្រតិបត្តិវេទិកាបន្សុាំទៅនឹង ការប្រែប្រួលអាកាសធាតុសាកល្បងមួយ។ តាមរយៈការពិគ្រោះយោបល់ និងសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ ជាតិដែលធ្វើឡើងកន្លងមក មានការលើកឡើងជាយោបល់ថា ដំណើរការនេះត្រូវចាប់ផ្តើមដោយការបង្កប់នូវការ ទទួលខុសត្រូវនៃនាយកដ្ឋានប្រែប្រួលអាកាសធាតុ ក្នុងក្រសួងបរិស្ថាន ចំណែកអ្នកផ្សេងទៀត បានស្នើថាដំណើរការនេះត្រូវចាប់ផ្តើមជាមួយផ្នែកពាក់ព័ន្ធ_វិស័យគ្រប់គ្រងគ្រោះមហន្តរាយឬវិស័យធនធានទឹក។ មតិភាគច្រើន បានចង្អុលបង្ហាញថា "វេទិកា"គួរធ្វើឡើងតែឯង ឬធ្វើឡើងរួមគ្នាពីសំណាក់ក្រុមអ្នកពាក់ព័ន្ធពីគ្របវិស័យទាំងអស់ និងពីគ្រប់កំរិតនៃតំរូវការដែលធ្វើឡើងពីខាងក្នុងរចនាសម្ព័ន្ធរដ្ឋាភិបាល។

មានការពិគ្រោះយោបល់ និងការខិតខំប្រឹងប្រែងក្នុងអំឡុងពេលនៃសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិ អំពីការ បង្កើតវេទិកា ដែលផ្តោតសារសំខាន់ថា "កម្ពុជា"នៅមិនទាន់សំរេចបានជោគជ័យអំពីរបៀបកសាងចំណេះដឹង បន្សុាំទៅនឹងការប្រែប្រួលអាកាសធាតុនៅឡើយ។ បន្តការយល់ដឹងបន្ថែមលើបញ្ហានេះ និងជួយជំរុញអ្នកពាក់ព័ន្ធ ទៅនិងការបន្សុាំទៅនឹងការប្រែប្រួលអាកាសធាតុ បង្កើតយ៉ាងច្បាស់នូវគោលបំណង តួនាទី និងការទទួលខុសត្រូវ ដែលវេទិកាគួរអនុវត្តប្រកបដោយប្រសិទ្ធិផល និងអាចអនុវត្តបាន។ មកដល់ត្រឹមពេលនេះ ក្រុមអ្នកពាក់ព័ន្ធដែល យើងបានពិគ្រោះយោបល់ជាមួយមានយោបល់ទូលំទូលាយមួយអំពីរបៀប និងទីកន្លែងណាដែលវេទិកានេះត្រូវ អនុវត្ត ប៉ុន្តែក៏បានពិនិត្យមើលផងដែរនូវការប្តេជ្ញាចិត្តជាក់លាក់ដើម្បីគាំទ្រ ក្នុងការធានាថាពេលវេលារបស់ពួក គេត្រូវបានប្រើប្រាស់យ៉ាងល្អ ហើយ "វេទិកា"នេះទៀតសោត មិនស្ថិតនៅត្រឹមតែជាគំនិតដែលផ្តល់ក្នុងសិក្ខាសា លាតែប៉ុណ្ណោះទេ។

គោលបំណងរបស់វេទិកា ត្រូវបានកំណត់ថា ជាកន្លែងដែលចំណេះដឹងត្រូវបានគេចែករំលែក ប៉ុន្តែ អ្វីដែលរិតតែ សំខាន់ជាងនេះទៀតនោះ គឺជាកន្លែងដែលចំណេះដឹងថ្មីៗអាចត្រូវបានគេប្រមូលគៀងគរ។ វេទិកានេះគួរតែអាច នាំមករួមបញ្ចូល និងចែករំលែកដល់អ្នកពាក់ព័ន្ធទាំងឡាយ _បង្កើតនូវការផ្សព្វភ្ជាប់គ្នាយ៉ាងមានប្រសិទ្ធិភាពរវាងចំណេះ..

ការប្រតិបត្តិ និងគោលនយោបាយនានា។ ការផ្សារភ្ជាប់គ្នានេះត្រូវគេចាត់ទុកថា ជាការកសាងជាបឋម នៃវេទិកា ដើម្បីបង្កើតឥទ្ធិពលលើគោលនយោបាយ និងការផ្សារភ្ជាប់គំនិតផ្តួចផ្តើមនៅថ្នាក់ជាតិឲ្យស៊ីគ្នាទៅនឹងតំរូវ ការទាំងឡាយនៅមូលដ្ឋាន។

ដោយសារវេទិកានេះភាគច្រើនពិនិត្យមើលលើការប្រមូលចំណេះដឹង នោះគោលបំណងនេះ ត្រូវតែសកម្មក្នុងការ លើកដំកើងការស្រាវជ្រាវអំពីការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ និងរបៀបដែលវាផ្សារភ្ជាប់ទៅនឹងកិច្ច សន្ទនារវាងការប្រតិបត្តិការងារអភិវឌ្ឍន៍នៅថ្នាក់មូលដ្ឋាន ដែលក្នុងពេលជាមួយគ្នានេះក៏បានលើកកំពស់ប្រសិទ្ធិភាពនៃការបង្កើតគោលនយោបាយផងដែរ។ ដោយហេតុថា គោលបំណងនៃវេទិកាធ្វើឡើងដើម្បីបង្កើតនូវស្ពាន ចំលងព័ត៌មានដ៏សកម្ម រវាងអ្នកប្រតិបត្តិការងារអភិវឌ្ឍន៍ទាំងឡាយ-ពោលគឺរវាងរដ្ឋាភិបាល -និងក្រុមសង្គម ស៊ីវិល ដើម្បីធានាថា "គោលនយោបាយ" ត្រូវបានគេពិចារណាអំពីស្ថានភាពពិតនៅមូលដ្ឋាន និងទទួលខុសត្រូវ ចំពោះតំរូវការនៃការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុក្នុងចំណោមសហគមន៍នានា។ គោលការណ៍ណែនាំ ចំពោះវេទិកាក៏ត្រូវបានបង្ហាញផងដែរ។ មានការលើកឡើងថា ការពិគ្រោះយោបល់ពេញ លេញជាមួយបណ្តាអ្នកពាក់ព័ន្ធត្រូវតែជាធាតុដ៏សំខាន់មួយ ហើយជំរើសនៃប្រធានបទរួម ធ្វើឡើងដើម្បីលើក ដំកើង និងជំរុញនូវរបៀបដែលវេទិកានេះ ត្រូវធ្វើឲ្យស៊ីគ្នាជាមួយវេទិកា និងការអភិវឌ្ឍការបន្សាំទៅនឹងការប្រែ ប្រួលអាកាសធាតុនៅថ្នាក់ជាតិ និងថ្នាក់តំបន់។ ជាគោលការណ៍ វេទិកានេះគួរជាវេទិកាដែលគាំទ្រដល់គំនិតផ្តួចផ្តើមរបស់ក្រសួង-ពោលគឺវាធានាថា វាឆ្លើយតបចំពោះតំរូវការនៅមូលដ្ឋាន ជាមួយនឹងដំណោះស្រាយជាក់ ស្តែង និងការគាំទ្រការកសាងសមត្ថភាពសមស្រប។ សំខាន់បំផុតវេទិកាគួរតែបំពាក់នូវស្មារតីនៃការស្ម័គ្រចិត្ត។ ដើម្បីកសាងលើគោលដៅនិងគោលករណ៍ណែនាំ មានការផ្តល់យោបល់ថា ការប៉ាន់ប្រមាណចំពោះបណ្តាញដែល មានស្រាប់ និងយន្តការអភិវឌ្ឍន៍គ្របវិស័យនៅកម្ពុជា ធ្វើឡើងដើម្បីកំណត់បទពិសោធន៍អំពីការ "ប្រតិបត្តិដែល គាប់ប្រសើរ"មួយ។

តួនាទីរបស់វេទិកា ត្រូវបានលើកយកមកពិភាក្សាយ៉ាងពិស្តារ ដើម្បីពិនិត្យមើលលើមុខងារ និងការប្រតិបត្តិ។ សំរាប់អ្នកមួយចំនួនធំដែលបានពិគោះ បាននិយាយថា តួនាទីដ៏សែនសំខាន់របស់វេទិកាគឺ បង្កើតឥទ្ធិពលចំពោះអ្នក ធ្វើសេចក្តីសំរេចចិត្ត តាមរយៈបទពិសោធន៍ផ្អែកតាមភស្តុតាង។ ដើម្បីសំរេចគោលដៅនេះ គេគួរចាប់ផ្តើមជាមួយការបង្កើតនូវគោលដៅរួមមួយ ពិនិត្យមើលរបៀបដែលវាលើកកំពស់ការចូលរួមដ៏ទូលំទូលាយ និងអំពីរបៀបដែល វាសំរបសំរួលអ្នកពាក់ព័ន្ធឲ្យនៅរក្សាការយកចិត្តទុកដាក់អំពីអ្វីដែលជាបំណងដែលវេទិកាចង់ឲ្យសំរេច។ ដើម្បី អនុវត្តសកម្មភាពនេះ អ្នកពាក់ព័ន្ធបានស្នើថា "ក្បួនច្បាប់ដើម្បីអនុវត្ត" គប្បីត្រូវបង្កើត និងប្រើប្រាស់ដោយគណៈ កម្មការបណ្តោះអាសន្នមួយ ដើម្បីកំណត់ថា ពេលណា និងរបៀបណាដែលអ្នកពាក់ព័ន្ធត្រូវអនុវត្តនៅក្នុងវេទិកា។ វេទិកាគួរបំពេញមុខងារផងដែរក្នុងនាមជាអ្នកបង្រួបបង្រួមរវាងបទពិសោធន៍នៅមូលដ្ឋាន និងអ្នកធ្វើសេចក្តីសំរេច ចិត្ត ដោយធានាថា ដំណើរការពិគ្រោះ –ក្នុងនាមជាគោលការណ៍មួយ –ជាមួយនឹងអ្នកពាក់ព័ន្ធសំខាន់ៗ និងអ្នក ធ្វើសេចក្តីសំរេចចិត្តត្រូវប្រកាន់យក។

ស្តែងចេញពីទិដ្ឋភាពនៃគំនិតម្ខាងទៀត វេទិកាគួរសំរបសំរួលការផ្តល់ព័ត៌មានឆ្លើយតបពីកិច្ចសន្ទនា ដែលធ្វើឡើង សំដៅផ្សាភ្ជាប់មនុស្សជាមួយគោលនយោបាយ។ ប្រការនេះក៏តំរូវឲ្យវេទិកាបំពេញមុខងារក្នុងនាមជាយន្តការ ទំនាក់ទំនង អំពីអ្វីដែលអ្នកខ្លះបរិយាយថាជា "ចំណេះដឹងដែលងាយយល់" –ជាចំណេះដឹងដែលអាចឲ្យមនុស្ស ទូទៅ ងាយយល់ដឹង ដោយមិនចាំបាច់ត្រូវការចំណេះដឹងបច្ចេកទេសពិសេស។ មុខងារនៃការ "ប្រាស្រ័យទាក់ទង" នេះគួរតែត្រូវពង្រីកដល់កំរិតតំបន់ផងដែរ។ ទាក់ទងដល់ការប្រតិបត្តិ យុទ្ធសាស្រ្តដែលមានការចូលរួម ដែលធ្វើឡើងដោយមានការរៀនសូត្រ និងផ្លាស់ប្តូរ គំនិតគ្នាជាទៀងទាត់គួរជាគោលគ្រឹះមួយ។ សកម្មភាពនេះ ធ្វើឡើងហួសពីការដែលគ្រាន់តែប្រមូល និងចែក រំលែកឯកសារ។ មានការស្នើថា ការប្រើប្រាស់ប្រព័ន្ធព័ត៌មានដោយមានការចូលរួម ដើម្បីបញ្ចូលគំនិត ការប្រើ ប្រាស់ចំណេះដឹងមូលដ្ឋាន និងវេទិកាកសាងសមត្ថភាពនៅសហគមន៍មូលដ្ឋាន រួមជាមួយព្រឹត្តិការណ៍តស៊ូមតិ ទាំង អស់នេះ នឹងដាក់ឲ្យអនុវត្តជាក់ស្តែងដោយ "ក្រុមការងារបច្ចេកទេសតាមវិស័យ និងប្រធានបទ" របស់វេទិកាក្នុងនាមជាយុទ្ធសាស្រ្តប្រតិបត្តិការមួយ។ ដោយសារថា មនុស្សជាច្រើនចង់ឲ្យវេទិកាប្រតិបត្តិភាគច្រើននៅពិភពខាង ក្រៅ ,និងផ្អែកលើគេហទំព័រ អ្នកឯទៀត ចង់ឲ្យមុខងាររបស់វេទិកាមានលក្ខណៈសកម្ម និងអាចចូលរួមបានពីក្រុម អ្នកពាក់ព័ន្ធទាំងអស់។

ការទទួលខុសត្រូវរបស់វេទិកា មានច្រើនៈ ទី ១ ផ្តល់អនុសាសន៍ ទី ២ សំរបសំរួលការបញ្ចូលនិងចែករំលែកកិច្ច ខិតខំប្រឹងប្រែងកសាងសមត្ថភាព គំរោង និងកម្មវិធីផ្សេងៗក្នុងចំណោមអ្នកពាក់ព័ន្ធប្រកបដោយប្រសិទ្ធិភាពជាក់ស្តែង ធ្វើជាកន្លែងមួយសំរាប់ក្រុមអ្នកផ្តល់ជំនួយ អ្នកគាំទ្រ អ្នកអនុវត្ត និងអ្នកដែលកំពុងត្រូវការ ទី ៣ សំរបសំរួលក្នុងនាមជាចំណុចធនធានសំរាប់អ្នកឯកទេសកសាងសមត្ថភាពអនុវត្តទី៤សំរបសំរួលការកំណត់និងបង្កើត ការបំពេញការងារជាដៃគូ និងទី ៥ ផ្តល់នូវព័ត៌មានតបជាប្រព័ន្ធដល់អ្នកពាក់ព័ន្ធអនុវត្ត លទ្ធផល គោលបំណង និងការរៀនសូត្រអំពីការបន្សុាំទៅនឹងការប្រែប្រួលអាកាសធាត។

ភារកិច្ចទាំងអម្បាលម៉ានខាងដែលលើកឡើងខាងលើ ជាភារកិច្ចដ៏ធំធេង ដែលតំរូវឲ្យដំបូង តែងតាំងគណៈកម្ម ការបណ្តោះអាសន្នមួយ ដើម្បីកំណត់ លក្ខខណ្ឌយោងសំរាប់ការប្រតិបត្តិតួនាទី និងការទទួលខុសត្រូវរបស់គំរោង និងសំខាន់កំណត់ និងគៀងគរ យន្តការហិរញ្ញវត្ថុសំរាប់ប្រតិបត្តិការ និងការបំពេញមុខងាររបស់វេទិកា។ មានការ ស្នើថាវេទិកាគប្បីចាប់ "ដៃគូ" ជាមួយអ្នកចាប់អារម្មណ៍សំខាន់ៗចំពោះវេទិកា និងតំរូវការសមត្ថភាព ដើម្បីដើរ តួនាទីជាលេខាធិការដ្ឋានមួយ ដើម្បីចាប់ផ្តើម ជំហានដំបូងនៃកិច្ចពិគ្រោះយោបល់ បង្កើត និងធ្វើឲ្យប្រាកដថាវេទិ កាដំណើរការជាប់ៗ។ ធ្វើបែបនេះ ជាធម្មជាតិនឹងនាំឲ្យមានការចូលរួមពីសំណាក់អ្នកពាក់ព័ន្ធ_ដែលជាតួនាទី និង ការទទួលខុសត្រូវរបស់ពួកគេ។

ការចូលរួមរបស់អ្នកពាក់ព័ន្ធ ក្នុងវេទិការួមមានមកពីបណ្តាក្រសួងដែលមានការពាក់ព័ន្ធចំពោះការផ្តួចផ្តើមគំនិត បន្សុាំទៅនឹងការប្រែប្រួលអាកាសធាតុ ភ្នាក់ងាររដ្ឋាភិបាលពាក់ព័ន្ធ អង្គការសង្គមស៊ីវិល គ្រឹះស្ថានសិក្សាស្រាវជ្រាវ និងអង្គការសហគមន៍ទាំងឡាយដែលពាក់ព័ន្ធនឹងសហគមន៍នេសាទ សហគមន៏ព្រៃឈើ សហគមន៏គ្រប់គ្រងតំបន់ អភិរក្ស និងសហគមន៍អេកូធម្មជាតិ _ទុកដូចជាចំណុចចាប់ផ្តើម។ ទីប្រឹក្សាបច្ចេកទេសក្នុងវេទិកានេះរួមមានអ្នក ស្រាវជ្រាវវិទ្យាសាស្ត្រពីគ្រឹះស្ថានសិក្សាស្រាវជ្រាវ (បច្ចេកទេស និងជំនាញសង្គម) និងអ្នកស្រាវជ្រាវរបស់អង្គ ការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិដែលតែងតាំងចូលក្នុងក្រុមការងារបច្ចេកទេសដែលពាក់ព័ន្ធ ដើម្បីសំរបសំរួលអង្គការមូលដ្ឋាន និងការលើកកំពស់ការយល់ដឹងនៅថ្នាក់ស្រុក និងថ្នាក់ឃុំ និងតំរូវការកសាងសមត្ថភាព។

ខណៈពេលដែលការចូលរួមក្នុងវេទិកាចាប់ផ្តើមអនុវត្ត នោះវាជាប្រការសំខាន់ដែលត្រូវមានគោលគំនិតមួយអំពី មូលហេតុចំបងនៃសារសំខាន់នៃការចូលរួមរបស់អ្នកពាក់ព័ន្ធ ហើយគោលបំណងរបស់វាទៀតសោត នឹងកំណត់ ផងដែរនូវតួនាទី និងការទទួលខុសត្រូវរបស់អ្នកពាក់ព័ន្ធ។ ដូចដែលបានបញ្ជាក់ពីខាងដើម ការចូលរួមពីពហុអ្នកពាក់ព័ន្ធ ធ្វើឡើងដើម្បីផ្តល់នូវការរួមបញ្ចូលគ្នាដែលសមស្រប និងអាចអនុវត្តបាននូវគោលគំនិតដែលមានចរិត បច្ចេកវិជ្ជាវិទ្យាសាស្ត្រ និងវិទ្យាសាស្ត្រសង្គម ដើម្បីបង្កើនភាពអាចប្រើប្រាស់បាននៃចំណេះដឹងដែលបានប្រមូល ក៏ដូចជាធានាថា ស្ថាប័នថ្នាក់សហគមន៍បានយល់ដឹងអំពីគំនិតផ្តួចផ្តើមបន្សុំាទៅនឹងការប្រែប្រួលអាកាសធាតុ និងផលប្រយោជន៍ទាំងឡាយដែលពួកគេអាចទទួលបាន។ ការចូលរួមពីពហុអ្នកពាក់ព័ន្ធ ក៏គួរធានាផងដែរនូវសមធម៌ នៃការ “បញ្ចេញមតិ” ក្នុងចំណោមអ្នកពាក់ព័ន្ធដែលសកម្ម និងអ្នកពាក់ព័ន្ធដែលមិនសូវហ៊ានមាត់ក ឧទាហរណ៍ ក្រុមជនជាតិភាគតិច អ្នកភូមិ និងស្ត្រី។ ជាចុងក្រោយការចូលរួមពីពហុអ្នកពាក់ព័ន្ធត្រូវគេអំពាវនាវឲ្យមាន ដើម្បី ធានានូវការចែករំលែកគោលគំនិត ធនធាន និងការប្រតិបត្តិល្អៗ និងយ៉ាងបរិបូរពីគ្រប់វិស័យ ដែលនាំមកនូវការរៀនសូត្រ និងនវានុវត្តថ្មីៗ។

តួនាទីរបស់អ្នកពាក់ព័ន្ធក្នុងវេទិកាត្រូវបានគេកំណត់ដោយងាយថា: ទី១ ជាអ្នករួមចំណែកចំពោះការលូតលាស់ ផ្នែកចំណេះដឹងអំពីការបន្សុំា និងការប្រើប្រាស់វាក្នុងការអភិវឌ្ឍគំរោង ការស្រាវជ្រាវ ករណីសិក្សា គោលនយោ បាយ និងការបង្កើតនូវក្របខ័ណ្ឌច្បាប់សំរាប់វេទិកា និងការគាំទ្រការបន្សុំា ទី២ ជាអ្នកបញ្ជាក់ និងផ្តល់សុពលភាព នៃព័ត៌មាន ទី៣ តស៊ូមតិសំរាប់គំនិតផ្តួចផ្តើមបន្សុំា ដែលស្របតាមការយល់ឃើញនិងតំរូវការរបស់ក្រុមមនុស្ស ដែលត្រូវគេមើលរំលង ទី៤ ជាអ្នកភ្ជាប់ទំនាក់ទំនងព័ត៌មាន រវាងក្រុមការងារបច្ចេកទេសបន្សុំា និងក្រុមអ្នកប្រើ ប្រាស់នៅមូលដ្ឋាន និង ទី៥ ជាអ្នកភ្ជាប់វេទិកាទៅនឹងស្ថាប័នទទួលបន្ទុកការប្រែប្រួលអាកាសធាតុផ្សេងទៀត។

ដោយសារតែវេទិកា ទើបតែត្រូវបានបង្កើតនាពេលនេះ ហើយមួយចំណែកធំត្រូវធ្វើឡើងក្នុងរបៀបជាការកសាង សមត្ថភាពជាមូលដ្ឋាន នោះការជំរុញវេទិកាឲ្យដំណើរការទៅមុខ និងទទួលបានជោគជ័យ នឹងត្រូវតំរង់ទិសដៅ ពីប្រភពមួយជាក់លាក់។..

និយាយដោយត្រង់ ដោយសារតែវិសាលភាពនៃចំណេះដឹងបន្សុំ និងការសំរបសំរួលក្នុងចំណោមអ្នកពាក់ព័ន្ធអំពីការបន្សុំ អ្នកជាច្រើននៅមិនទាន់មានចំណេះដឹងអំពី "របៀបធ្វើ" នៅឡើយ។ ការពិគ្រោះយោបល់បន្ថែម ពិតជាត្រូវការនាពេលនេះ ជាមួយអ្នកពាក់ព័ន្ធសំខាន់ៗដែលអាចចំណាយពេលវេលា និង ចំណេះដឹង ដើម្បីកំណត់ឲ្យច្បាស់ថាទីណាដែលវេទិកាត្រូវស្ថិតនៅ និងរបៀបដែល _អភិបាលកិច្ច ការសំរេចចិត្ត ការចូលរួម ប្រព័ន្ធហិរញ្ញវត្ថុ និងចំណុចចាប់ផ្តើមដែលវេទិកាត្រូវផ្តោតការយកចិត្តទុកដាក់លើ។ ខណ:ពេលដែល ស្ថានភាពទាំងនេះចាប់ចេញដំណើរហើយ នោះការកំណត់តួនាទី និងការទទួលខុសត្រូវ នឹងរួមបញ្ចូលគ្នាតាមការ ចូលរួមធ្វើសកម្មភាព _ដូចដែលបានលើកឡើងខាងលើ _វាជាគោលការណ៍ណែនាំចំពោះការបង្កើតវេទិកា។

## ផ្នែក ៥.0 សេចក្តីសន្និដ្ឋានបញ្ចប់ និងជំហានបន្ទាប់

ក្នុងសេចក្តីសន្និដ្ឋានបញ្ចប់នៃការសិក្សានេះ វាបានបង្ហាញយ៉ាងច្បាស់ថា មិនមានដំណោះស្រាយ ឬរបៀប ដោះស្រាយតែមួយ ដែលនឹងសមស្របសំរាប់តំរូវការនៃការបន្សុំទៅនឹងការប្រែប្រួលអាកាសធាតុនៅកម្ពុជាទេ។ក្នុងការប្រឈមចំពោះផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ អ្វីដែលសំខាន់ នោះត្រូវកសាងភាពស៊ាំក្នុងកំរិតសហគមន៍ដើម្បីសំរេចបាននូវភាពស៊ាំនេះ គេត្រូវកសាងមូលដ្ឋានចំណេះដឹងដែលមានអ្នកប្រើប្រាស់ច្រើនការបង្កើតគោលនយោបាយដែលបញ្ចូលគ្រប់វិស័យ និងការអនុវត្តជាស្ថាប័ននៃប្រព័ន្ធ ដែលអាចឆ្លើយតបនិងសំរបទៅនឹងការផ្លាស់ប្តូរនិងលក្ខខណ្ឌដែលកើតឡើងមិនទៀងទាតញឹកញាប់ បណ្តាលពីការប្រែប្រួលអាកាសធាតុ។

តាមរយ:ការពិនិត្យមើលផ្នែកអក្សរសាស្រ្ត និងយោបល់ទាំងឡាយរបស់អ្នកដែលយើងពិគ្រោះជាមួយ បង្ហាញថា ការយល់ដឹងរបស់កម្ពុជាអំពីការបន្សុំទៅនឹងការប្រែប្រួលអាកាសធាតុ នៅក្មេងខ្ចីនៅឡើយ ថ្វីបើកំពុងមានការ លេចឡើងនូវអ្នកជំនាញខ្លះៗ ប៉ុន្តែបើយើងពិនិត្យមើលក្នុងទូទាំងប្រទេស នោះយើងអាចមើលឃើញថា សូម្បីតែ ការងារស្រាវជ្រាវអំពីតំរូវការបន្សុំ និងគំនិតផ្តួចផ្តើមអនុវត្តការបន្សុំ ក៏នៅមានចំណោទជាច្រើនដែលត្រូវស្វែង រកការបញ្ជាក់បន្ថែមទៀតផងដែរ។ ភាគច្រើននៃចំណេះដឹងស្ថិតនៅអ្នកដែលប្រមូល និងបង្កើតប៉ុណ្ណោះ។..

នេះយើងមិនទាន់និយាយដល់ការបរាជ័យនៃប្រព័ន្ធ ដោយគ្រាន់តែរំលេចឲ្យឃើញនូវប្រធានបទ “ថ្មីៗ” នៅថ្នាក់ ជាតិ និងពិភពលោកប៉ុណ្ណោះផង។

ការសិក្សានេះបង្ហាញថាសកម្មភាពភាគច្រើនរបស់កម្មវិធីសកម្មភាពជាតិដើម្បីបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ ផ្តោតសំខាន់លើការលើកកំពស់សមត្ថភាពគ្រប់គ្រងធនធានទឹក ដើម្បីបង្កើនផលិតភាពកសិកម្មសកម្មភាព ទាក់ទងនឹងការយល់ដឹងអំពីមុខសញ្ញាងាយរងគ្រោះពីការប្រែប្រួលអាកាសធាតុនៅក្នុងប្រទេស ការគ្រប់គ្រង គ្រោះមហន្តរាយ និងមានសកម្មភាពក៏វិតតូចៗទាក់ទងនឹងការ ការពារតំបន់ឆ្នេរ។ មានការស្នើថាអ្នកធ្វើគោលនយោបាយត្រូវ ចូលរួមវាយតម្លៃកម្មវិធីបច្ចុប្បន្នដើម្បីដោះស្រាយហានិយភ័យពីអាកាសធាតុ ដើម្បីឲ្យប្រធានបទ ស្រាវជ្រាវថ្មីៗ អាចបង្កើតឡើងនិងប្រើប្រាស់ក្នុងការរៀបចំការធ្វើឲ្យប្រសើរ ឬស្តារឡើងវិញនូវ កំលាំងជំរុញនៃកម្មវិធីបច្ចុប្បន្ន។ ការសិក្សានេះបានគូសបញ្ជាក់ នូវស្មារតីពីគ្របវិស័យទាំងអស់ដែលមានភាពមិនច្បាស់លាស់នៅឡើយអំពីស្ថានភាពប្រែប្រួលអាកាសធាតុក្នុងរយៈពេល ១០ ឆ្នាំ ឬសូម្បី ២០ឆ្នាំទៀត។ ហេតុនេះ តើអ្វីទៅជា ការបន្សាំទៅថ្ងៃ អនាគត?

ការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ ពិតជាសំខាន់សំរាប់ កម្ពុជា ជាពិសេសលើរបៀបដោះស្រាយកង្វះខាតធនធានទឹក ដែលនាំអន្តរាយដល់ប្រភពទឹកស្អាតនិងកសិកម្មផ្ទុយពីនេះអំពីរបៀប ដែលគេត្រូវដោះស្រាយចំពោះទឹកជំនន់ផងទៀត។ ពិតមែនហើយស្ថានភាពនេះនាំឲ្យមានតំរូវការដើម្បីមាន ហេត្ថារចនាសម្ព័ន្ធបន្ថែម ការសំរបសំរួលរវាងភ្នាក់ងារនានាបន្ថែម ការស្រាវជ្រាវបន្ថែម ចេញពីទស្សនៈអ្នកប្រើចំណេះដឹង និងសមត្ថភាពបន្ថែមទៀត។ ខាងក្រោមនេះជាវិស័យជាអាទិភាពសំរាប់កសាង សមត្ថភាព ដែលរកឃើញក្នុងការស្រាវជ្រាវលើ ចំណេះដឹង ប្រព័ន្ធ រចនាសម្ព័ន្ធ និងគោលនយោបាយ។

### កសាងចំណេះដឹងដែល:

- បង្កើតនូវទិន្នន័យប្រកបដោយគុណភាព និងងាយស្រួល ប្រើប្រាស់អំពីអាកាសធាតុ រួមគ្នាជាមួយលក្ខខណ្ឌ ផ្នែក ធាតុអាកាស និងជលសាស្ត្រ ដើម្បីសំរបសំរួលដល់ការកែលំអសេនារីយ៉ូនិងការព្យាករការប្រែប្រួលអាកាសធាតុជាជំហានឆ្ពោះទៅកាន់ការប្រើប្រាស់ក្នុងកំរិតជាតិ និងមូលដ្ឋាន។
- អភិវឌ្ឍជាបន្តនូវសមត្ថភាពនៃប្រជាជនកម្ពុជាទាក់ទងនឹងប្រព័ន្ធរបរកសិកម្មផ្អែកលើដំណាំស្រូវ ដើម្បីឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ ឧទាហរណ៍ ការធ្វើជាគំរូអំពី ការដាំដុះលើកសិដ្ឋាន ការបង្ហាញពូជដំណាំដែលធន់ទ្រាំទៅនឹងទឹកជំនន់ និងការរាំងស្ងួត ការប្រើប្រាស់ បច្ចេកទេសសំណើម_ដូចជាការត្រងយកទឹកភ្លៀងចុងរដូវ ឬការប្រើប្រាស់ធារាសាស្ត្របង្រ្គប់ ព្រមទាំងការ គ្រប់គ្រងទឹកដីជាតដី និងធនធានដី។
- ពង្រឹងប្រព័ន្ធសំអាតទឹកភ្លាវនិងមានជាតអាសេនិចជាផលិតភាពដែលស្របតាមតំរូវការផ្នែកអេកូឡូស៊ី បច្ចេកវិទ្យា ការកាន់កាប់ និងភាពជាស្ថាប័ន។
- ការយល់ដឹងយ៉ាងច្បាស់អំពីរបៀបដែលបណ្តាញសង្គម និងស្ថាប័នក្រៅផ្លូវការប្រតិបត្តិ ដើម្បីសំរបសំរួល នូវវិធានការបន្សុំា ឧទាហរណ៍ សមធមិសង្គមបញ្ហាចោទលើភាពយុត្តិធមិ និងវិសមភាពយេនឌ័រក្នុង បរិបទដាក់បន្សុំា និង:
- កំណត់កត្តារាំងស្ទះ មិនឲ្យទទួលបានជោគជ័យ ចំពោះការធ្វើផែនការគ្រប់គ្រងសុខភាព និងធនធាន ធម្មជាតិ និងការបន្សុំាជាស្វ័យប្រវត្តិទៅនឹងផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ។

### បង្កើតប្រព័ន្ធដែល:

- ដាក់បញ្ចូលគ្នានូវការព្យាករធាតុអាកាស និងអាកាសធាតុជាមួយការព្យាករជលសាស្ត្រដែលងាយប្រើ ប្រាស់ និងអាចអនុវត្តបានទាំងស្ថាប័ននៅថ្នាក់ជាតិ ថ្នាក់ខេត្ត និងថ្នាក់សហគមន៏មូលដ្ឋាន។
- ធានាឲ្យមានការវិភាគទិន្នន័យ ការធ្វើផែនការ និងការអនុវត្តគំនិតផ្តួចផ្តើមបន្សុំាទៅនឹងការប្រែប្រួលអា កាសធាតុ និងការចែករំលែកចំណេះដឹងឆ្លងកាត់គ្របវិស័យទាំងអស់។
- ធានាការចូលរួមពហុអ្នកពាក់ព័ន្ធក្នុងការធ្វើផែនការ និងការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រក្នុកំរិតខេត្ត និងឃុំ។

- រួមបញ្ចូលនូវរឿងរ៉ាវផ្នែកបរិស្ថាន ការប្រកបមុខរបរចិញ្ចឹមជីវិត ការអប់រំ សុខាភិបាល និងអាហារូបត្ថម្ភ ទៅក្នុងការ ធ្វើផែនការ និងឆ្លើយតបចំពោះគ្រោះហន្តរាយធម្មជាតិ។
- ធ្វើឲ្យមានភាពជាស្ថាប័ននូវ "ក្រមបទដ្ឋាន" ចំពោះវិធីសាស្ត្រស្រាវជ្រាវនិងសំរាប់អ្នកទាំងឡាយណា ដែលកំពុងប្រតិបត្តិការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ
- បង្កើនភាពអាចទទួលបាន និងអាចប្រើប្រាស់នូវព័ត៌មានផ្នែកវិទ្យាសាស្ត្រអំពីអាកាសធាតុ និងលក្ខខណ្ឌ ធាតុអាកាសនៅថ្នាក់មូលដ្ឋាន និងសំរាប់គោលបំណងធ្វើការសំរេចចិត្តនៅថ្នាក់ជាតិ។
- បង្កើតលទ្ធភាពប្រើប្រាស់ដី និងការកាន់កាប់ឥណទាន ការវិនិយោគផ្នែកកសិកម្ម ការទុកដាក់បំរុង និង បច្ចេកវិទ្យាផ្សេងៗ ពីសំណាក់ស្ត្រី
- ពង្រឹងស្ថាប័ន និងភាពជាអ្នកដឹកនាំរបស់ស្ត្រី ក្នុងអង្គការនានា ប្រយោជន៍ដើម្បីឲ្យពួកគេអាចទទួល បានផលប្រយោជន៍ និងការរួមចំណែកក្នុងការបង្កើតយុទ្ធសាស្ត្របន្សាំ។
- ធ្វើឲ្យទៅជាស្ថាប័ននូវសម្បទានសហគមន៍ ដែលនាំមកនូវការបន្សាំកំរិតមូលដ្ឋាន ក្នុងយន្តការអភិវឌ្ឍន៍ ស្អាត និង
- ស្ថាបនានូវវិធានការផ្នែកសង្គម បច្ចេកវិទ្យា ភាពជាស្ថាប័ន និងគោលនយោបាយ ដើម្បីដោះស្រាយ ចំពោះ ឧបសគ្គដែលរារាំងការចូលរួមពីសំណាក់អ្នកពាក់ព័ន្ធទាំងអស់។

## រៀបចំវេទិកាសម្ព័ន្ធ:

- ដែលមានសមត្ថភាពអនុវត្ត និងគាំទ្រដល់ការបង្កើត ផ្សព្វផ្សាយបន្តនូវចំណេះដឹងអំពីការបន្សាំទៅនឹងការ ប្រែប្រួលអាកាសធាតុ
- ដែលផ្តល់នូវវេទិកា និងបណ្តាញយ៉ាងជាប់លាប់ដើម្បីប្រតិបត្តិ_ដែលវេទិកា និងបណ្តាញនិមួយៗផ្តោត ការយកចិត្តទុកដាក់ចំបងលើការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ សំរាប់អ្នកបំរើការងារផ្នែក អភិវឌ្ឍន៍ ដើម្បីធ្វើសកម្មភាពជាមួយ និងអ្នកធ្វើគោនយោបាយ និង
- សំរបសំរួល និងរៀបចំការកសាងសមត្ថភាព រាប់តាំងពីថ្នាក់ជាតិ រហូតដល់ថ្នាក់ឃុំ ក្នុងគោលបំណង ដើម្បីកែលំអលទ្ធភាពទទួលបាន និងមានសមត្ថភាពគ្រោងគំរោងឆ្លើយតបចំពោះការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ និងការធ្វើការសំរេចចិត្ត។

### រៀបចំគោលនយោបាយដែល:

- គាំទ្រដល់ការដាក់បញ្ចូលនូវការបន្សុាំទៅនឹងការប្រែប្រួលអាកាសធាតុ ទៅក្នុងគោលនយោបាយ ថ្នាក់ ជាតិ និងថ្នាក់ក្រោមជាតិ ការធ្វើផែនការ និងដំណើរការរៀបចំថវិកា។
- លើកទឹកចិត្តផ្នែកឯកជនឲ្យចូលរួមក្នុងការបន្សុាំទៅនឹងការប្រែប្រួលអាកាសធាតុ
- គាំទ្រការរួមបញ្ចូលនូវផែនការបន្សុាំសំរាប់អនុផ្នែកនានា ដូចជា ជលផល និងវារីវប្បកម្ម ទៅក្នុងផែនការ ជាតិសំរាប់ការបន្សុាំទៅនឹងការប្រែប្រួលអាកាសធាតុ។
- គាំទ្រការចូលរួមរបស់សហគមន៍ដែលពឹងផ្អែកលើមុខរបរកសិកម្ម និងនេសាទ ទៅក្នុងការធ្វើផែនការ សេដ្ឋកិច្ចជាតិ និងផែនការវិមជ្ឈការ។
- ដាក់ការរួមបញ្ចូលគ្នានូវវិស័យគ្រប់គ្រងធនធានធម្មជាតិ ទៅក្នុងគោលនយោបាយឆ្លើយតបចំពោះគ្រោះ មហន្តរាយ និងផែនការអភិវឌ្ឍន៍។
- បញ្ចូលការសំរេចចិត្តផ្អែកលើមូលដ្ឋានស្រាវជ្រាវបានពីការស្រាវជ្រាវផ្លូវការ និងមិនផ្លូវការអនុវត្តនៅថ្នាក់ មូលដ្ឋានទៅគ្រប់វិស័យសិក្សាទាំងអស់ និង
- ធានាថាមានកិច្ចសហការ និងការចែករំលែកព័ត៌មានក្នុងចំណោមអ្នកពាក់ព័ន្ធក្នុងការបន្សុាំទៅនឹងការប្រែ ប្រួលអាកាសធាតុទាំងអស់_រាប់ចាប់ពីមន្ទីរវិស័យរហូតដល់គ្រឹះស្ថានសិក្សាស្រាវជ្រាវ អង្គការមិនមែន រដ្ឋាភិបាល និងសហគមន៍មូលដ្ឋាន។

វិធានការទាំងឡាយដូចបានលើកឡើងខាងលើ នឹងនាំមកនូវភាពចាំបាច់ចំពោះការបន្ថយហានិយភ័យតាមការ លើកកំពស់ការអនុវត្តវិស័យកសិកម្ម និងធ្វើឲ្យមានភាពចំរុះនូវការចិញ្ចឹមជីវិតក្នុងវិស័យកសិកម្ម ការកែលំអប្រព័ន្ធ សុខាភិបាលដើម្បីដោះស្រាវជម្ងឺទាំងឡាយទាក់ទងនឹងអាកាសធាតុ និងផលប៉ះពាល់ផ្នែកសុខភាពផ្សេងៗទៀត និងជាពិសេស ការស្វែងរកមធ្យោបាយដោះស្រាយផលប៉ះពាល់ផ្នែកសង្គមបណ្តាលពីការប្រឈទៅនឹងធាតុអាកាស រួមមានទាំងបញ្ហាចំណាកស្រុក និងទំនាស់អំពីធនធានធម្មជាតិផង។

ការកសាងភាពស៊ាំមានន័យថា ជាការពង្រឹងនូវយុទ្ធសាស្ត្រអភិវឌ្ឍន៍ដែលមានស្រាប់។ ការសិក្សានេះបានរកឃើញ នូវក្តីបារម្ភទាក់ទងនឹងការរួមបញ្ចូលគ្នានៃការបន្សុាំទៅនឹងការប្រែប្រួលអាកាសធាតុ ជាមួយបញ្ហាសន្តិសុខស្បៀង និងក្របខ័ណ្ឌ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍មុខរបរចិញ្ចឹមជីវិត។ សំណួរដែលចោទសួរថា តើសហគមន៍អាចទទួលយកបាននូវភាពទីទៃពីគ្នានៃយុទ្ធសាស្ត្រ ដែលរៀបចំសំរបសំរួលការអភិវឌ្ឍរបស់គេឬទេ? ឬវាជាចំណោទសួរលើ ប្រសិទ្ធិភាពនៃកិច្ចសហប្រតិបត្តិការអន្តក្រសួង និងការបញ្ចូលគ្នាទាំងនេះ? ការប្រឈមទាំងឡាយ ជាការ ប្រឈមថ្មី និងផ្សេងៗពីគ្នា។ សហគមន៍ខ្លះត្រូវសំរបខ្លួនទៅនឹងគ្រោះទឹកជំនន់ដែលមិនអាចទាយទុកជាមុន កង្វះខាតការផ្គត់ផ្គង់ទឹកសំរាប់បរិភោគ រីឯសហគមន៍ដទៃទៀត ទទួលបានភាពសំបូរបែបនៃមុខរបរជាជំរើសក្រៅពីមុខរបរធម្មតារបស់គេ។ សហគមន៍នឹងត្រូវឆ្លើយតបចំពោះលក្ខខណ្ឌមិនធម្មតាតាមរយៈប្រព័ន្ធផ្តល់ដំណឹងជាមុន ,ព្យាករអាកាសធាតុ ចំណែកឯភ្នាក់ងាររដ្ឋាភិបាលវិញនឹងត្រូវឆ្លើយតប ដោយនាំយកនូវចំណេះដឹង និងសមត្ថភាព ផ្នែកវិទ្យាសាស្ត្រ របស់ពួកគេទៅដល់កំរិតអនុវត្តជាក់ស្តែងធ្វើឡើងដោយសហគមន៍។

ដោយហេតុថាកម្ពុជាកំពុងធ្វើដំណើរឆ្លងកាត់ការឆ្លើយតបក្នុងរយៈពេលខ្លីមួយទៅកាន់ការប្រែប្រួលអាកាសធាតុ នោះ ការផ្តោតសំខាន់ទៅលើតម្រូវការចំណេះដឹងសម្រាប់ផែនការបន្សាំ ក៏ដូចជាការឆ្លើយតបរយៈពេលវែង ឧទាហរណ៍ ការកសាងគំរូអាកាសធាតុឲ្យកាន់តែប្រសើរ ការបង្កើតសូចនាករតាមដានមិនមែនសម្រាប់តែវិស័យដែលរងហានិយភ័យប៉ុណ្ណោះទេ ប៉ុន្តែ វាសម្រាប់តាមដានសមត្ថភាពបន្សាំនៃបុគ្គលិក ស្ថាប័ន និងគណៈកម្មាធិការ នានាផងដែរ។ ចំណុចចាប់ផ្តើមសមស្របមួយគឺ ការកំណត់រកកំលាំងរុញច្រានការប្រែប្រួលផ្នែកសេដ្ឋកិច្ច_សង្គម តាមរយៈការកសាងសេនារីយូដោយមានការចូលរួម និងលើកកំពស់កិច្ចពិភាក្សា និងការលើកផែនការជាមួយអ្នកពាក់ព័ន្ធទាំងអស់ ។

តំរូវការការកសាងវេទិកាបន្សុាំទៅនឹងការប្រែប្រួលអាកាសធាតុថ្នាក់ខេត្តសំរាប់ការសនាធ្វើផែនការ និងធ្វើ សកម្មភាពត្រូវបានលើកឡើងជាញឹកញាប់ ហើយក៏ជាការបញ្ជ្រាបនូវគំនិតនេះចូលទៅក្នុងខ្សែបណ្តាយនៃភ្នាក់ងារ ពាក់ព័ន្ធថ្នាក់ជាតិ។

_មានន័យថាកម្ពុជាមានភារកិច្ចបង្កើតសមត្ថភាព បន្សុំាទៅនឹងការប្រែប្រួលអាកាសធាតុ ប្រកបដោយសមធម៌_ជាភារកិច្ចហួសពីលទ្ធភាពរបស់សហគមន៍ ក្នុងការបន្សុំាទៅនឹងការប្រែប្រួលអាកាសធាតុអាចបំពេញ បើពុំមានការគាំទ្រជារៀបរយបន្តទៅទៀតទេ។ នេះជាអ្វីដែល ធ្វើឲ្យការ "កំណត់" ដំណើរការជាការប្រឈមជាក់ស្តែងមួយ។

"ការសិក្សាស្រាវជ្រាវនេះ" ានទាំមកនូវការចូលរួមផ្នែកសមត្ថភាពពីអ្នកដែលមានចំណេះដឹង និងបទពិសោធន៍ ច្រើនអំពីការបន្សុំាទៅនឹងការប្រែប្រួលអាកាសធាតុ ការពិគ្រោះយោបល់តាមសិក្ខាសាលាថ្នាក់ជាតិដែលចូលរួមពី អ្នកទាំងនោះ និងព្រមទាំងបានពង្រីកវិសាលភាពរបស់វាទៅដល់គ្រប់ប្រជាជនកម្ពុជាដែលត្រូវការ និងជាបណ្តើរៗ នឹងដាក់ឲ្យប្រើវេទិកាមួយទៅអនាគត។ ដោយហេតុថា វាមានសារសំខាន់ដែលមូលដ្ឋានចំណេះដឹងត្រូវការកសាង ជាមុន នោះគំនិតខ្ពីហើយច្បាស់សំរាប់បំពេញកង្វះខាតផ្នែករចនាសម្ព័ន្ធបន្សុំា និងគោលនយោបាយ នឹងត្រូវអនុវត្ត ទៅរួចផងដែរ។ មានការលើកឡើងយ៉ាងទូលំទូលាយថា វេទិកាអាចអនុវត្ត និងចូលរួមបានដោយអ្នកទាំងឡាយ ដែលត្រូវអនុវត្តនៅមូលដ្ឋាន_ជាមួយនឹងការភ្ជាប់ទំនាក់ទំនងជាបន្តដើម្បីកំណត់មូលហេតុចំបងនៃ"វេទិកា" ។ បើដូច្នោះ តើនេះមានន័យថា វេទិកាត្រូវតែធ្វើនៅមូលដ្ឋានដែលអាចឲ្យមានដំណើរការលូតលាស់ជាធម្មជាតិមួយ ឬ ត្រូវរៀចំជារចនាសម្ព័ន្ធតាំងពីផ្តើមដំបូង ដើម្បីឆ្លើយតបទៅនឹងបំណងរបស់មូលដ្ឋាន? វាជាការប្រសើរដែលត្រូវ ស្វែងរកកន្លែងនៅកណ្តាលមួយ ដែលជំរុញសកម្មភាពសាមញ្ញ និងអាចអនុវត្តបាន ពោលគឺមិនមែនសំរាប់តែឆ្នាំ ដំបូងប៉ុណ្ណោះ ប៉ុន្តែ នៅតែបន្តជានិរន្តរ៍។

សំរាប់បច្ចុប្បន្នមិនទាន់មានរចនាសម្ព័ន្ធណាមួយក្នុងការជួយសម្របសម្រួលការងារទាំងនេះហើយក៏មិនទាន់មានយន្តការស្ថាប័នណា និងតម្រូវការកសាងសម្ថភាព និងគាំទ្រប្រតិបត្តិការរឹងមាំណាមួយនៅ ឡើយ។ការកំណត់តម្រូវការគាំទ្រកើតចេញពី មធ្យោបាយកសាងដ៏រឹងមាំមួយ សម្រាប់គណៈកម្មាធិការ ជាតិស្តីពីការប្រែប្រួលអាកាសធាតុ និងក្រសួង បរិស្ថានដឹកនាំការរៀនសូត្រ ការសម្របសម្រួលនិងសកម្មភាព បន្សាំការប្រែប្រួលធាតុអាកាស។ ការរៀនសូត្រណាមួយអាចផ្តើមចេញពីការចែករំលែកព័ត៌មាន សំរបសំរួលដែល អាចជួយដល់ការបង្កើតភាពជាដៃគូ ផ្នែកស្ថាប័នជាផ្លូវការ -ពោលគឺកិច្ចព្រមព្រៀងសហប្រតិបត្តិការ និងការ យោគយល់គ្នាមួយ -ជាមួយអង្គការ មិនមែនរដ្ឋាភិបាលផ្សេងៗ និងសកម្មភាពដែលបណ្តុះឡើងដោយភាពសកម្ម និងការដឹកនាំប្រកបដោយភាពច្នៃប្រឌិត។

ជំហានបន្ទាប់ពីការសិក្សានេះគឺត្រូវកំណត់ "យុទ្ធសាស្ត្រកសាងសមត្ថភាពបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ នៅកម្ពុជា"ទុកជាមហិចតាដ៏ធំមួយ ព្រោះកំរិតនៃចំណេះដឹងរបស់ប្រជាជនកម្ពុជាទាក់ទងនឹងការបន្សាំ នៅខ្សោយ នៅឡើយ"។ អ្វីដែលសំរេចនាពេលនេះគឺកំណត់តំរូវការ និងដំណើរការសមស្របមួយដើម្បីដោះស្រាយតំរូវការ កសាងសមត្ថភាព នៅថ្នាក់ជាតិ ប៉ុន្តែ មិនថាឡើយបញ្ជី ឬសូម្បីដំណើរការណាមួយក៏នៅមិនទាន់ធ្វើចប់សព្វគ្រប់ ឬមិនទាំងបាន កំណត់...ជាចំណុចដែលមិនមានលើកមកនិយាយ។ បើនិយាយឲ្យស្រួលយល់ គឺកម្ពុជានៅមាន សមត្ថភាពបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុទាបនៅឡើយ មូលហេតុមួយចំណែកមកពីមូលដ្ឋាននៃចំណេះ ដឹងបច្ចុប្បន្ន។ ក្នុងឯកសារនេះមានការលើកឡើងថា ត្រូវមានការកសាងចំណេះដឹងអំពីការសំរាលមូលហេតុនៃការ ប្រែប្រួលអាកាសធាតុ ការសំរាលផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុពោលគឺមិនមែនត្រឹមតែជាការបន្សាំ ទៅនឹងការប្រែប្រួលអាកាសធាតុតែប៉ុណ្ណោះទេ។ ធ្វើបែបនេះ វាបានផ្តល់នូវភាពជឿជាក់ចំពោះការទំនាក់ទំនងនៃ មូលដ្ឋានចំណេះដឹងរួមទាំងអាចឆ្លុះបញ្ចាំងថា ពីចំណុចណាដែលកម្ពុជាត្រូវចាប់ផ្តើមដំណើរការកសាងសមត្ថភាព របស់ខ្លួន -ដែលនេះស្ទើរតែជាការចាប់ផ្តើមដំបូង។ នេះមិនទាន់ទាំងនិយាយដល់អ្នកដែលមានជំនាញ និងចំណេះ ដឹងខ្ពស់ៗទាំងនោះពុំមានទីលំនៅ ឬមិនមែនជាជនជាតិកម្ពុជាផង

ទៅនឹង ការប្រែប្រួលអាកាសធាតុជាមួយកម្មវិធីអភិវឌ្ឍន៍ និង ឬ ការសំរួចគោលដៅការអភិវឌ្ឍឲ្យសំរេចបាននូវការបន្ស៊ាំ ទៅនឹងការប្រែប្រួលអាកាសធាតុ។ នាពេលថ្មីៗនេះ អង្គការ CORD Asia អង្គការ DanChurch Aid/ Christian Aid _ និងអង្គការ ForumSyd, បានចាប់ផ្ដើមអនុវត្តគំរោងសាកល្បងមួយអំពីរឿងនេះជាមួយអង្គការដៃគូចំនួន ១០ពោល គឺគេបានអនុវត្តការ កសាងចំណេះដឹង ឧបករណ៍ និងដំណើរការសិក្ខាសាលាអំពីវិស័យទូលំទូលាយមួយ ទាក់ទងនឹងការប្រែប្រួលអាកាសធាតុ ឧទាហរណ៍ ការសំរាលផលបណ្ដាលឲ្យមានការប្រែប្រួលអាកាសធាតុ ការ សំរាលផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ និងការបន្ស៊ាំទៅនឹងការប្រែប្រួលអាកាសធាតុ។ ជាផ្នែក និងជាជំហាន ដ៏សំខាន់ក្នុងគំរោងនេះ មានគំរូវការ និងកាលានុវត្តភាពដែលបង្ហាញថា ការខិតខំប្រឹងប្រែងត្រូវតែពង្រីក និងធ្វើឲ្យទូលំទូលាយទៅដល់ក្រុមប្រឹក្សាឃុំស្រុក និងអាជ្ញាធរខេត្តនិងក្រសួងមន្ទីរនានាជុំវិញខេត្តក្នុងបរិបទរបស់គេ។

មាន "ជំហានបន្ទាប់" ចំនួន ៣ ត្រូវបានលើកឡើង ហើយពិតណាស់វាជាជំហានទីមួយ និងជំហានទីពីរដែលបន្តបន្ទាប់គ្នា។ ជំហានទីបីគួរផ្ដួចផ្ដើមឡើងជាមួយសកម្មភាពកសាងចំណេះដឹង និងជំនាញ។ អនុសាសន៍សំរាប់អនុវត្ត ជំហានទីមួយ និងទីពីរនឹងបង្កើតជាមូលដ្ឋានគ្រឹះសំរាប់មនុស្ស គោលនយោបាយ និងវេទិកាចាប់ផ្ដើមអនុវត្ត និងដំណើរការ។ ទោះជាយ៉ាងណាក៏ដោយ អ្វីដែលសំខាន់នោះគឺ ក្រុមការងារចំពោះកិច្ចអាចអនុវត្តនូវការ ពិគ្រោះយោបល់ សំរាប់ការតស៊ូមតិជាមួយនាយកដ្ឋានប្រែប្រួលអាកាសធាតុដើម្បីស្វែងរកកន្លែង ការគាំទ្រ ទំហំ ការងារ និងចិរភាពសំរាប់វេទិកា។នោះមិនចង់សំដៅថា វេទិកាគួរស្ថិតនៅចំណុះឲ្យនាយកដ្ឋានប្រែប្រួលអាកាស ធាតុទេ ដោយហេតុថា អ្នកផ្ដល់មតិជាច្រើនបង្ហាញថា វាគ្រាន់តែជាការនាំយកអនុសាសន៍ ឬគំនិតទៅឲ្យ នាយកដ្ឋានផ្ដល់យោបល់ជូន និងពិគ្រោះយោបល់ជាមួយបន្តទៅទៀត

វាត្រូវការពេលវេលាខ្លះសំរាប់កម្ពុជាធ្វើសមាហរណកម្មគំនិតផ្តួចផ្តើមគំនិតដាក់បន្សុាំទៅនឹងការប្រែប្រួលអាកាស ធាតុរបស់ខ្លួនក្នុងវេទិកាដែលមានការសំរបសំរួលល្អ ដើម្បីឲ្យវេទិកានេះសំរេចបានតាមផលដែលខ្លួនប្រាថ្នាចង់បាន។ដោយទទួលស្គាល់ចំពោះរឿងនេះ វាពិតជាសំខាន់ដើម្បីចាប់ផ្តើមការរៀបចំដំបូង ហើយអនុវត្តជំហានបន្តបន្ទាប់ មកទៀត។ មានសកម្មភាពគន្លឹះចំនួន៣ដែលគេអាចចាប់ផ្តើមដំណើរការទី១កសាងក្រុមអ្នកជំនាញចំពោះកិច្ចមួយ ដើម្បីផ្តើមសកម្មភាពសំរបសំរួល និងផ្តល់យោបល់ ដែលត្រូវការសំរាប់កំណត់របៀបដែលវេទិកាបន្សុាំទៅ នឹងការប្រែប្រួលអាកាសធាតុត្រូវអនុវត្ត ទី ២ កសាងចំណេះដឹង និងទី ៣ ការពិគ្រោះយោបល់ តាមបែបតស៊ូមតិ ជាមួយនាយកដ្ឋានប្រែប្រួលអាកាសធាតុ និង“ក្រុមអ្នកជំនាញការចំពោះកិច្ច” ឲ្យជំរុញ ដល់ការបង្កើតនូវទីកន្លែងអនុវត្តជាអចិន្ត្រៃ និងសមស្របមួយ។

ដើម្បីជំរុញកិច្ចខិតខំទាំងឡាយក្នុងការអនុវត្តកិច្ចការពិគ្រោះយោបល់ពហុភាគី មានចំណាប់អារម្មណ៍ជាច្រើនក្នុង ចំណោមអ្នកចូលរួមទាំងនោះឲ្យបង្កើតក្រុមចំពោះកិច្ចមួយជំរុញឲ្យវេទិកាសំរេចគោលដៅរបស់ខ្លួន។ ហើយក៏មាន ភាពចាំបាច់ផងដែរ ដើម្បីពិភាក្សាក្នុងចំណោមអ្នកចាប់អារម្មណ៍ ដូចជា រកជំនាញត្រឹមត្រូវសំរាប់អ្នកចូលរួមក្នុងក្រុមពោលគឺអ្នកដើរតួនាទីពិតដែលមានសមត្ថភាពជំរុញចំណាប់អារម្មណ៍និងគៀងគរធនធានដែលត្រូវការជាចាំ បាច់ ចំរាញ់យកគំនិត ដើម្បីជំរុញការងារឲ្យសំរេចទៅមុខ។ ក្រុមការងារចំពោះកិច្ចក៏ត្រូវពិចារណាដាក់កិច្ចខិតខំ ប្រឹងប្រែងរបស់ខ្លួនធ្វើការផ្សព្វផ្សាយ “ខ្លឹមសារទាំងឡាយ...ទាក់ទងនឹងការប្រែប្រួលអាកាសធាតុ និងការបន្សុាំ ទៅនឹងការប្រែប្រួលអាកាសធាតុផងទៀត”។

ដូចដែលបានលើកឡើងម្តងហើយម្តងទៀតថា គេគប្បីមានមូលដ្ឋានចំណេះដឹងដែលប្រសើរជាងនេះក្នុងចំណោម ភាគីពាក់ព័ន្ធផ្សេងៗគ្នា។ ដើម្បីអនុវត្តការងារនេះឲ្យមានប្រសិទ្ធិភាពគេត្រូវបង្កើតនិងចែកចាយចំណេះដឹងអំពីការប្រែប្រួលអាកាសធាតុក្នុងចំណោមអ្នកពាក់ព័ន្ធដំបូងៗ កំណត់ត្រាខ្លឹមកំរាស់ ៤ទំព័រ មួយឈុត ដែលផ្តល់ ដល់អ្នកពាក់ព័ន្ធជាមួយតំរូវការចំណេះដឹង ដើម្បីជំរុញការចាប់អារម្មណ៍ក្នុងការបញ្ចូលសកម្មភាពបន្សុាំ..

ជាក់ស្តែងការពិគ្រោះសំរាប់បំណង តស៊ូមតិ។ សំណួរចោទ សួរជារួមមាន ១. តើកម្ពុជាអាចទទួលបានផលប្រយោជន៏ពីវេទិកាបន្សុាំទៅនឹងការ ប្រែប្រួលអាកាសធាតុដូចម្តេច ទី ២ តើគោលដៅ និងគោលបំណងរបស់នាយកដ្ឋានប្រែប្រួលអាកាសធាតុអាចសំរេចតាមការគាំទ្រ និងបញ្ចូលក្រុម អ្នកពាក់ព័ន្ធ ដូចដែលស្នើឡើងដោយវេទិកាក្នុងរចនាសម្ព័ន្ធរដ្ឋាភិបាលដូចម្តេច? ប្រហែលចំលើយចំពោះសំនួរទាំងពីរនេះហើយជាចំណុចដែល

ដំណើរការពិគ្រោះយោបល់ត្រូវចាប់ផ្តើម...និង បន្ត ដំណើរទៅមុខ។

# តារាងឧបសម្ព័ន្ធ

## ឧបសម្ព័ន្ធ១ បញ្ជីឈ្មោះអ្នកចូលរួមសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិ

| No | Name | Sex | Position | Institution | Contact |
|---|---|---|---|---|---|
| 1 | Am Phirum | M | Deputy Director | MAFF | 011 927 862 |
| 2 | Aquilar, Macareuc | F | Advisor | UNDP | Macareuc.aquilar@undp.org |
| 3 | Atun Brad | M | Director | WFC | N/A |
| 4 | Cecila Aipra | F | Project Advisor | UNDP | Cealia.aipra@undp.org |
| 5 | Chhoeng Sotheavan | F | Volunteer | CBNRM LI | 092 797 377 |
| 6 | Friad, Richard | M | Consultant | UNDP | 017 609 207 |
| 7 | Frieson, Kate | F | Research Advisor | CBNRM LI | 012 392 920 |
| 8 | Ham KimKong | M | Lecturer | RUPP/DES | 012 406 716 |
| 9 | Heng Chan Thoeun | M | National Team Leader V & A Assessment | MoE/SNC | 016 726 668 |
| 10 | Hy Beangchy | F | Admin Volunteer | CBNRM LI | N/A |
| 11 | Keam Han | M | Project Manager | CBNRM LI | 017 951 223 |
| 12 | Kheang Seangly | F | Climate Change Intern | Oxfam America | 011 206 364 |
| 13 | Leng Bunlong | M | Environment Specialist | World Bank | 012 946 161 |
| 14 | Lic Vuthy | M | Program Staff | Danida | 012 967 865 |
| 15 | Ly Vuthy | M | Deputy Director | CFDD/FiA | 011 660 840 |
| 16 | Ma Veasna | M | Project Officer | CEDAC | 012 672 721 |
| 17 | Meng Monyrak | M | Learning Forum Coordinator | CBNRM LI | 012 943 909 |
| 18 | Oum Sopharo | M | Research Officer | CBNRM LI | 011 251 176 |
| 19 | Pok PeuvThola | M | ED | WDO | 012 756 906 |
| 20 | Pok Sokunthea | F | Admin Assistant | CBNRM LI | 012 340 135 |
| 21 | Por Soma | F | Project Officer | Sida | 016 544 271 |
| 22 | Solar, Robert | M | NRM Consultant | CBNRM LI | 077 844 323 |
| 23 | Teng Srey | F | Vice Director | CDC/MoH | 012 836 868 |
| 24 | Thol Buntha | M | Online Forum Officer | CBNRM LI | N/A |
| 25 | Tin Ponlok | M | SNC Project Coordinator | SNC Project | 012 915 351 |
| 26 | Sam Chanthy | M | Researcher | SEI | 011 931 982 |
| 27 | Sim Sambath | M | Capacity Development Advisor | Forum Syd | 012 836 650 |
| 28 | Thuon Try | M | - | UNDP | 012 439 693 |
| 29 | Tol Sokchea | M | CMLN Manager | CBNRM LI | 012 322 496 |
| 30 | Touch Panha | M | Communication Volunteer | CBNRM LI | 012 281 652 |

Acronyms used: M – male, F – female; CBNRM LI – Community Based Natural Resource Management Learning Institute, CDC/ MoH - Communicable Disease Control / Ministry of Health, CEDAC - Cambodian Center for Study and Development in Agriculture, CFDD/ FiA – Community Fisheries Development Division/ Fisheries Administration, MAFF – Ministry of Agriculture Forestry and Fisheries, MoE – Ministry of Environment, RUPP/DES – Royal University of Phnom Penh/ Department of Environmental Science, SEI – Stockholm Environment Institute, SNC – Second National Communication, ¬¬¬¬¬¬UNDP – United Nations Development Programme, V & A - Vulnerability and Adaptation, WDO – Wholistic Development Organization, WFC – World Fish Center.

## ឧបសម្ព័ន្ធ២: គម្លាតផ្នែកចំណេះដឹងអំពីការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ តម្រូវការកសាងសមត្ថភាពនិងដំណើរការ ដូចដែលបាន កំណត់តាមរយៈការពិគ្រោះយោបល់ និងដំណើរការសិក្ខាសាលា

កង្វះខាតជាអាទិភាព និងគោលបំណង១: មានតំរូវការដើម្បីកសាងនូវការយល់ដឹងឲ្យច្បាស់អំពីរបៀបដែលបណ្តាញសង្គម និងស្ថាប័នក្រៅផ្លូវការ ត្រូវប្រតិបត្តិ។ ការយល់ដឹងនេះនឹងធានាថាវិធានការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុដែលបានអនុវត្ត យ៉ាងហោចណាស់បានគិតគូរដល់សមធមិសង្គម និងយេនឌ័រ និងបាននាំយក ប្រសិទ្ធិផល ចិរភាព និងភាពអាចអនុវត្តបានទៅក្នុងដំណើរការនៃការបន្សាំនេះ។

| តម្រូវការកសាងសមត្ថភាព... | គោលដៅបថមសំរាប់ការកសាងសមត្ថភាព | អ្នកប្រើប្រាស់បថមចំណេះដឹងដែលបង្កើត |
|---|---|---|
| - ចំណេះដឹងទូទៅស្តីពីការបន្ធូរបន្ថយទៅនឹងការប្រែប្រួលអាកាសធាតុ និងបន្ធូរបន្ថយ ពីផលប៉ះពាល់ទៅនឹងការ ប្រែប្រួលអាកាសធាតុ ទស្សនៈបន្សាំទៅនឹងការប្រែប្រួល អាកាសធាតុក្នុងក្របខ័ណ្ឌ សកម្មភាព និងយុទ្ធសាស្ត្រជាតិ។ | - អង្គការក្នុងស្រុក | - អង្គការក្នុងស្រុក |
| - ការពង្រឹង និងធ្វើអោយទៅជាស្ថាប័ន ដោយ ប្រើ ចំណេះដឹង ពហុវិស័យតាមរយ ទស្សនៈបន្សាំ ១ជជាថ<br>- កែលំអដំណើរការបញ្ជ្រាបយេនឌ័រទៅគ្រប់កំរិត និងគ្រប់វិស័យ | - អាជ្ញាធរថ្នាក់ស្រុក និងមូលដ្ឋានអ្នកធ្វើផែនការ អ្នកសម្របសម្រួល អ្នកផ្តល់សេវាបច្ចេកទេស និងអ្នកធ្វើសេចក្តីសម្រេចចិត្ត | - អាជ្ញាធរថ្នាក់ស្រុក និងមូលដ្ឋានអ្នកធ្វើផែនការ អ្នកសម្របសម្រួល អ្នកផ្តល់សេវាបច្ចេកទេស និងអ្នកធ្វើសេចក្តីសម្រេចចិត្ត |
| - កែលំអការប្រើប្រាស់ការស្រាវជ្រាវដោយមានការចូលរួមធ្វើសកម្មភាពក្នុង គំនិតផ្តួចផ្តើម ១ជជាថ<br>- កែលំអសមត្ថភាព អ្នកប្រតិបត្តិការងារអភិវឌ្ឍន៍ ដើម្បីសម្របសម្រួល សហគមន៍នានា ក្នុងមូលដ្ឋាន ក្នុងការផ្សារភ្ជាប់គំនិតផ្តួចផ្តើម ពហុអ្នកពាក់ព័ន្ធ ប្រកបដោយប្រសិទ្ធិភាព ដូចជា កសាងសម្ព័ភាពពួកគេ ។ | - សហគមន៍ដែលពាក់ពន្ធ័ទៅនឹងគំនិងផ្តួចផ្តើម (CCA) | - សហគមន៍ដែលពាក់ពន្ធ័ទៅនឹងគំនិងផ្តួចផ្តើម (CCA) |

### ដំណើការនៃការកសាងសមត្ថភាព

- សិក្ខាសាលាបណ្តុះបណ្តាលរួមគ្នាដើម្បីកសាងចំណេះដឹងបែបផ្លាស់ប្តូរ និងការអនុវត្តដំណើរការដែលស្នើឡើងដើម្បីធានាឲ្យមាន ១. វិធីសាស្ត្រចូលរួមក្នុងការបញ្ជ្រាប យេនឌ័រ ២. វិធីសាស្ត្រចូលរួមក្នុងការចលនាសហគមន៍ និង ទី ៣ វិធីសាស្ត្រដើម្បីបញ្ចូល និងវិភាគលើបណ្តាញសង្គមនិងស្ថាប័នក្រៅផ្លូវការក្នុងការ បន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ។

- ការកសាងក្របខ័ណ្ឌសិក្សាសង្គមមួយទៅក្នុងទស្សនៈនៃវេទិកាបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុកម្ពុជា។

កង្វះខាតជាអាទិភាព និងគោលបំណង២: នៅមានកង្វះខាតផ្នែកចំណេះដឹងដែលសមស្របសំរាប់ពង្រឹងប្រព័ន្ធដំណាំស្រូវនៅកម្ពុជា ក្នុងបរិបទបំរែ បំរួលអាកាសធាតុនៅឡើយ។ ការបំពេញកង្វះខាតនេះនាំមកនូវការធានានូវសុវត្ថិភាពនៃ "ការដាំដុះ" ក្នុងបរិបទចំនួន ២ -នោះគឺបរិបទប្រែប្រួលអាកាសធាតុ និងការអភិវឌ្ឍប្រកបដោយចិរភាព។

| តម្រូវការកសាងសមត្ថភាព... | គោលដៅបថមសំរាប់ការកសាងសមត្ថភាព | អ្នកប្រើប្រាស់បឋមចំណេះដឹងដែលបង្កើត |
|---|---|---|
| - ការធ្វើបង្ហាញក្នុងកសិដ្ឋានអំពីសេនារីយូ ក្នុងខ្វឹមសារអាកាសធាតុ<br>- ជំនាញស្រាវជ្រាវ និងសមត្ថភាពនានាដែលឈានដល់ការអភិវឌ្ឍន៍ នូវគ្រាប់ពូជដំណាំដែលធន់នឹងការរាំងស្ងួត និងទឹកជំនន់<br>- កែលំអចំណេះដឹងពីការប្រើប្រាស់ទឹកអោយមានប្រសិទ្ធិភាព ឧទាហរណ៍ បច្ចេកទេសជ្រើមនឹងធារាសាស្ត្រ និង<br>- ការអនុវត្តការគ្រប់គ្រងទឹក ដី និងជីជាតិ សមស្រប និង<br>- ជំនាញនៃការស្រាវជ្រាវផ្នែក បច្ចេកទេស និងសង្គម | -ភ្នាក់ងារផ្សព្វផ្សាយនៃក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ<br>-អ្នកស្រាវជ្រាវមកពីគ្រឹះស្ថានសិក្សាស្រាវជ្រាវ | - ភ្នាក់ងារផ្សព្វផ្សាយនៃក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ<br>- អ្នកស្រាវជ្រាវមកពីគ្រឹះស្ថានសិក្សាស្រាវជ្រាវ<br>- កសិករ និងប្រជានេសាទ |

ដំណើការនៃការកសាងសមត្ថភាព:

- ការទទួលស្គាល់ដែលកំណត់តាមរយៈសិក្ខាសាលាកសាងសមត្ថភាព អំពីការអនុវត្ត និងបញ្ចូលការស្រាវជ្រាវ និងតម្រូវទៅតាមបទដ្ឋានស្រាវជ្រាវ

- កែលំអការកសាងការពិគ្រោះយោបល់ និងកិច្ចសហការរវាង ការស្រាវជ្រាវផ្លូវការ ជាមួយស្ថាប័នសិក្សា និងកសិករនៅថ្នាក់មូលដ្ឋាន និង

- លើកទឹកចិត្តអោយមានការផ្តល់មូលនិធិប្រកបដោយការប្រកួតប្រជែង ដែលផ្អែកលើរបៀបដែលស្ថាប័នទាំងនោះត្រូវរួមបញ្ចូលគ្នា និងការឆ្លើយតបទៅនឹងតំរូវការកសាង សមត្ថភាព និងលទ្ធផលរបស់ក្រុមអ្នកពាក់ព័ន្ធ។

*កង្វះខាតជាអាទិភាព និងគោលបំណង ៣:* អវត្តមានផ្នែកចំណេះដឹងអំពីការបញ្ចូលទិន្នន័យអាកាសធាតុដែលងាយប្រើប្រាស់ជាមួយលក្ខណ:ទាំង ឡាយផ្នែកជលសាស្រ្ត និងធាតុអាកាស។ ភាពអាចរកបាននូវទិន្នន័យនេះនឹងសំរួលដល់ការបង្កើត និងកែ លំអការព្យាករ និងសេនារីយ៉ូប្រែប្រួលអាកាសធាតុ ដើម្បីសំរបសំរួល ,ដឹកនាំការចាត់អាទិភាព និងការអនុវត្តតំរូវការនៃការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ នៅនឹងកន្លែង។

| តម្រូវការកសាងសមត្ថភាព... | គោលដៅបឋមសំរាប់ការកសាងសមត្ថភាព | អ្នកប្រើប្រាស់បឋមចំណេះដឹងដែលបង្កើត |
| --- | --- | --- |
| - បង្កើនចំណេះដឹងទិន្នន័យ និងឧបករណ៍ ដែលត្រូវការដើម្បីវាស់វែងលក្ខខ័ណ ផ្សេងៗនៃធាតុអាកាស ក្នុងពេលវេលាជាក់លាក់មួយ<br>- បញ្ចូលចំណេះដឹងរួមគ្នា និងការបក ស្រាយ ក្នុងទិន្នន័យដែលជា ប្រយោជន៏ដល់តម្រូវការក្នុងកំរិតជាតិ និងមូលដ្ឋាន ក្នុងរយ:ពេលខ្លី និងវែង<br>- ធ្វើអោយជោគជ័យផ្នែកហិរញ្ញវត្ថុរយ:ពេលវែងដើម្បីធានានូវចលនា ចំណេះដឹងដែលបានបង្កើតទៅក្នុងប្រព័ន្ធ ប្រើប្រាស់រួមបញ្ចូលគ្នាមួយ | • ក្រសួងធនធានទឹក និងឧតុនិយម<br>• អ្នកធ្វើផែនការ អ្នកសម្របសម្រួល អ្នកផ្តល់សេវាបច្ចេកទេសនិងអ្នកធ្វើសេចក្តីសម្រេចចិត្ត | • គណ:កម្មាធិការទន្លេមេគង្គ<br>- ក្រសួងបរិស្ថាន<br>- កសួងធនធានទឹក និងឧតុនិយម<br>- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ<br>- ក្រុមប្រឹក្សាស្រុក និងឃុំ<br>- គ្រឹះស្ថានសិក្សាស្រាវជ្រាវ<br>- ប្រជាកសិករ និងប្រជានេសាទ |

*ដំណើរការនៃការកសាងសមត្ថភាព:*

- ការផ្លាស់ប្តូរបទពិសោធន៏ដែល "ប្រហាក់ប្រហែលគ្នា" និងប្រព័ន្ធចំណេះដឹងប្រើប្រាស់ក្នុងតំបន់ ទស្សន:កិច្ចសិក្សា និងផ្លាស់ប្តូរការណែនាំយោបល់គ្នាទៅវិញទៅមក
- ការពិភាក្សាជាមួយក្រុមគោលដៅបឋម និងអាចជាអ្នកណែនាំអំពីការកសាងសមត្ថភាព ដើម្បីកំណត់ថាតើចំណេះដឹង និងឧបករណ៏ និងចំណេះដឹងអ្វីដែលអាចរកបាន សេចក្តី ត្រូវការ និងសមត្ថភាពរបស់អ្នកប្រើប្រាស់ដែលត្រូវការអាចអនុវត្តន៏បាន ដោយផ្អែកលើកំរិតមួយដែលបានកំណត់សម្រាប់ប្រទេសកម្ពុជា
- វិធីសាស្រ្តរៀនសូត្រតាមរយ:ការចូលរួមពីពហុអ្នកពាក់ព័ន្ធក្នុងការពិសោធន៏កម្មវិធីរៀនបណ្តើរធ្វើបណ្តើរ និងទទួលបានតាមតំរូវការ
- សិក្ខាសាលាកសាងសមត្ថភាពសម្រាប់ក្រុមគោលដៅប្រើប្រាស់ចុងក្រោយ -ដែលអចិន្រ្តៃយ៏ អាចប្រើឡើងវិញ និងធ្វើការកែលំអជារៀងរាល់ឆ្នាំ ។

*កង្វះខាតជាអាទិភាព និងគោលបំណង ៤:* មានតំរូវការដើម្បីកំណត់ឧបសគ្គរាំងមិនឲ្យទទួលជោគជ័យចំពោះការធ្វើផែនការគ្រប់គ្រងធនធានធម្មជាតិ និងសុខភាព និងការបន្សាំដោយស្វ័យប្រវត្តិទៅនឹងការប្រែប្រួលអាកាសធាតុ។ ដោយការកំណត់ និងកាត់បន្ថយឧបសគ្គទាំងនេះជាបន្តបន្ទាប់ ការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុអាច នឹងដំណើរការទៅមុខលឿន និងរបៀបដែលវាដំណើរការ អាចធានានូវការទទួលផលប្រយោជន៍ប្រកបដោយ សមធម៌នៃសហគមន៍មូលដ្ឋាន ដែលឆ្លុះបញ្ចាំងពីការគោរព សិទ្ធមនុស្ស និងចិរភាពផ្នែកបរិស្ថាន។

| តម្រូវការកសាងសមត្ថភាព... | គោលដៅបចមសំរាប់ការកសាងសមត្ថភាព | អ្នកប្រើប្រាស់បចមចំណេះដឹងដែលបង្កើត |
|---|---|---|
| - ចំណេះដឹង ទូទៅស្តីពីការសម្រាល ហេតុនាំឲ្យមានការប្រែប្រួល អាកាសធាតុ ការសម្រាល ការប៉ះពាល់ទៅនឹងការប្រែប្រួលអាកាសធាតុ និងការបន្សាំ ក្របខ័ណ្ឌសម្មភាព និងយុទ្ធសាស្រ្តជាតិ<br>- ក្របខណ្ឌស្រាវជ្រាវដោយមានការចូលរួម ធ្វើសកម្មភាពនិងវិធីសាស្រ្តនៃការរៀនសូត្រ<br>- ការប្រើប្រាស់ការវិភាគលើការស្រាវជ្រាវ ដើម្បីធ្វើការសម្រេច ចិត្តក្នុងកំរិតមូលដ្ឋាន និងថ្នាក់ជាតិ | • តួអង្គនានាក្នុងវិស័យពាក់ព័ន្ធ អង្គការមិនមែនរដ្ឋាភិបាលក្នុង ស្រុកអាជ្ញាធរ មូលដ្ឋាន និងខេត្ត មានដូចជា អ្នកធ្វើផែនការ អ្នកសម្របសម្រួល អ្នកធ្វើការសម្រេចចិត្ត សហគមន៍ ពាក់ពន្ធ័នឹងគំនិតផ្តួចផ្តើម បន្សាំ និង អង្គការតស៊ូមតិទាំងឡាយ | • តួអង្គនានាក្នុងវិស័យពាក់ព័ន្ធ អង្គការមិនមែនរដ្ឋាភិបាលក្នុង ស្រុកអាជ្ញាធរ មូលដ្ឋាន និងខេត្ត មានដូចជា អ្នកធ្វើផែនការ អ្នកសម្របសម្រួល អ្នកធ្វើការសម្រេចចិត្ត សហគមន៍ ពាក់ពន្ធ័នឹងគំនិតផ្តួចផ្តើម បន្សាំ និង អង្គការតស៊ូមតិទាំងឡាយ |

*ដំណើរការនៃការកសាងសមត្ថភាព:*

- ផ្តល់វគ្គបណ្តុះបណ្តាលដោយផ្ទាល់ដល់វិស័យ និងស្ថាប័នដែលជ្រើសរើសដូចបានលើកឡើងខាងលើ និង
- ផ្តល់ការគាំទ្រផ្នែកហិរញ្ញវត្ថុជាយុទ្ធសាស្រ្ត និងការណែនាំ ដើម្បីប្រែក្លាយការធ្វើបណ្តើរសិក្សាបណ្តើរផ្អែកតាមកម្មវិធីឲ្យទៅជាការពិតជាក់ស្តែង

## ឧបសម្ព័ន្ធ៣: គម្លាតផ្នែកប្រព័ន្ធនៃការបន្សាំទៅនឹងការប្រែប្រួលធាតុអាកាសធាតុ និងតម្រូវការដំណើរការនៃការកសាងសមត្ថភាព ដូចបានកំណត់តាម រយៈការពិគ្រោះយោបល់ និងដំណើរការសិក្ខាសិលា

*កង្វះខាតជាអាទិភាព និងគោលបំណង ១:* បច្ចុប្បន្ននៅមិនទាន់មានប្រព័ន្ធសមស្របណាមួយដើម្បីដាក់បញ្ចូលការព្យាករធាតុអាកាស និងអាកាសធាតុជាមួយទំរង់ផល សាស្ត្រសំរាប់ការប្រើប្រាស់ថ្នាក់ជាតិ ខេត្ត និងសហគមន៍_ឲ្យទៅជាប្រព័ន្ធតែមួយ នៅឡើយ។ ធ្វើដូច្នេះ ដើម្បីធានាថាចំណេះដឹងដែលបានបង្កើតទាក់ទងនឹងប្រធានបទនេះ ត្រូវបាននាំយក ទៅដល់កសិករអនុវត្តប្រកបដោយប្រសិទ្ធិផល និងជាប់លាប់ ដោយសារប្រព័ន្ធនេះត្រូវបានគេបង្កើត និងប្រើ ហើយកែលំអក្នុងចំណោម ក្រុមអ្នកពាក់ព័ន្ធ ចំពោះការកសាងចំណេះដឹងទាំងឡាយ។

| តម្រូវការកសាងសមត្ថភាព... | គោលដៅបថមសំរាប់ការកសាងសមត្ថភាព | អ្នកប្រើប្រាស់បថមចំណេះដឹងដែលបង្កើត |
|---|---|---|
| • ប្រតិបត្តិការ និងការពង្រឹងប្រព័ន្ធគ្រប់គ្រងចំណេះដឹង ឧទាហរណ៍ ការគ្រប់គ្រងលើខ្លឹមសារចំណេះដឹង<br>• កែសម្រួលចំណេះដឹងគំរូអោយមានលក្ខណ:សាមញ្ញ និងកញ្ចប់ គំរូដែលផ្តល់ពី ការរួមបញ្ចូលគ្នា និង ការចែករំលែកព័ត៌មានច្បាស់លាស់មួយ<br>• ឧបករណ៍សម្រាប់បង្កើតទិន្នន័យក្នុងមូលដ្ឋាន<br>• សមត្ថភាពចំរុះវិស័យ ដើម្បីបកស្រាយទិន្នន័យទទួលបាន ពីថ្នាក់ខេត្ត និងឃុំ<br>• សមត្ថភាពថវិកា ដើម្បីធានាគ្រប់ការប្រមូលផល ទិន្នន័យ ពីកសិករជាតិ ដល់ ឃុំ | • មន្ទីរឧតុនិយម<br>• ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ<br>• ក្រសួងធនធានទឹក និងឧតុនិយម<br>• គណ:កម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ<br>• គណ:កម្មាធិការឃុំគ្រប់គ្រងគ្រោះមហន្តរាយ<br>• កសិករជនបទ | • មន្ទីរឧតុនិយម<br>• ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ<br>• ក្រសួងធនធានទឹក និងឧតុនិយម<br>• គណ:កម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ<br>• គណ:កម្មាធិការឃុំគ្រប់គ្រងគ្រោះមហន្តរាយ<br>• កសិករជនបទ |

*ដំណើរការនៃការកសាងសមត្ថភាព:*

- អាចមានច្រកចូលពីរ ដើម្បី ផ្តល់ការគាំទ្រ និងកសាងសម្ថភាពដោយផ្ទាល់ (១)ផែនការយុទ្ធសាស្ត្រសកម្មភាពជាតិ ពោលគឺក្រុមការងារបច្ចេកទេសកាត់បន្ថយគ្រោះមហន្តរាយ និង (២)ក្រុមការងារបច្ចេកទេសកសិកម្ម និងធនធានទឹក។
- ការកំណត់ពីតម្រូវការសម្ថភាពជាក់លាក់ចំពោះកសិករនិមួយៗ នៃអ្នកពាក់ព័ន្ធនានា ជាពិសេសការប្រើប្រាស់ ឧបករណ៍ និងទិន្នន័យ ពោលគឺវគ្គសិក្ខាសាលាថ្នាក់ជាតិ និងកំលាំង លើទឹកចិត្តផ្នែកហិរញ្ញវត្ថុ ដើម្បីបំពេញតម្រូវការរយ:ពេលខ្លី និងមធ្យម
- បើកវគ្គសិក្ខាសាលាដើម្បីតម្រែតម្រង់ទិសចំពោះលទ្ធផល ទិន្នន័យត្រូវការ និងសម្រួលទិន្នន័យទៅក្នុងប្រព័ន្ធ

ចំណេះដឹង

- ការបង្កើតវគ្គបណ្តុះបណ្តាលទូលំទូលាយដើម្បីធ្វើប្រតិបត្តិការប្រព័ន្ធ
- សិក្សាតាមវិធីសាស្ត្រធ្វើផង រៀនផងតាមរយៈគាំទ្រ គម្រោងសាកល្បងនិង
- ការឧបត្ថម្ភជំនួយថវិកាអោយបន្តធ្វើប្រតិបត្តិការ ។

កង្វះខាតជាអាទិភាព និងគោលបំណង ២: ដើម្បីធានាឲ្យមានការបន្សាំប្រកបដោយវិជ្ជមាន និងសមធម៌នោះតំរូវឲ្យមានការបង្កើតនូវការផ្តួចផ្តើមគំនិត បង្កើតប្រព័ន្ធ មួយដែលសំរបសំរួលការវិភាគទិន្នន័យឆ្លងវិស័យ ការចែករំលែកចំណេះដឹង ការធ្វើផែនការ និងការអនុវត្តការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ។ គេបានរំពឹងទុកថា ខណៈពេលដែលចំណេះដឹងបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុត្រូវបានបង្កើត នោះខ្លឹមសារ និងការប្រើប្រាស់ចំណេះដឹងទាំងនេះនឹងត្រូវរក្សាទុកតាមផ្នែកនិមួយៗ។ ប្រការនេះ អាចនាំឲ្យការបន្សាំតាមផ្នែកដែលបង្កការរារាំងដល់តំរូវការនៃផ្នែកផ្សេងទៀត ឬវាមិនបានសំរួលដល់ការបន្សាំជាសមូហភាព និងទូលំ ទូលាយ។

| តម្រូវការកសាងសមត្ថភាព... | គោលដៅបថមសំរាប់ការកសាងសមត្ថភាព | អ្នកប្រើប្រាស់បឋមចំណេះដឹងដែលបង្កើត |
|---|---|---|
| • ពិនិត្យឡើងវិញនូវស្ថាប័នបន្សាំនិងគណៈប្រព័ន្ធរួមបញ្ចូលគ្នាដែល មានសមាសភាពមកពីវិស័យ CCA ខុសគ្នាៗ ឧទាហរណ៍ ការគ្រប់គ្រង គ្រោះមហន្តរាយ ធនធានទឹក និង កសិកម្ម អប់រំ សុខភាព ។ល។<br>• ក្រុមអ្នកឯកទេសមួយក្រុមផ្តល់ជំនួយបច្ចេកទេស បញ្ចូលតម្រូវការទាំងឡាយសម្រាប់ការ អភិវឌ្ឍន៍ និងអនុវត្តនូវគំនិតផ្តួចផ្តើម CCA<br>• ការចែកចាយព័ត៌មានដែលទាក់ទងនឹងគំនិតផ្តួចផ្តើមលើ វិស័យ CCA ដែលរួមបញ្ចូលការ វាយតម្លៃពីផលប៉ះពាល់បរិស្ថាននិងគម្រោងនានា<br>• ការគាំទ្រថវិការសម្រាប់បន្តប្រតិបត្តិការ | • ក្រុមអ្នកផ្តល់ទស្សនៈ និង សហសមាជិកអ្នកឯកទេស | • គ្រប់គម្រោងអភិវឌ្ឍន៍ CCA ទាំងអស់<br>• ក្រសួងនិងភ្នាក់ងារតាមខ្សែបណ្តាយទាំងអស់ ជាប់ទាក់ទងជាមួយការអភិវឌ្ឍជនបទ និងទីប្រជុំជន និងការធ្វើផែនការគ្រប់គ្រងគ្រោះមហន្តរាយ<br>• អង្គការមិនមែនរដ្ឋភិបាលអន្តរ ជាតិ<br>-សហគមន៍ អង្គការមិនមែនរដ្ឋភិបាលទាំងមូល<br>• សហគមន៍អ្នកផ្តល់ជំនួយ |
| | | |

ដំណើរការនៃការកសាងសមត្ថភាព:

